ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ


ក្រសួងសង្គមកិច្ច អតីតយុទ្ធជន
និងយុវនីតិសម្បទា


# ក្របខ័ណ្ឌត្រួតពិនិត្យកិច្ចការពារកុមារ ក្នុងប្រទេសកម្ពុជា

## ឯកសារណែនាំសម្រាប់បង្កើតប្រព័ន្ធ CPIMS ក្នុងប្រទេសកម្ពុជា

## សូចនាករ និងកម្រងទិន្នន័យសំខាន់ៗ

ខែកក្កដា ឆ្នាំ២០២០

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន
និងយុវនីតិសម្បទា

ក្រសួងមហាផ្ទៃ

ក្រសួងយុត្តិធម៌

ក្រសួងកិច្ចការនារី

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ក្រសួងអប់រំ យុវជន និងកីឡា

អាជ្ញាធរមីន

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ក្រសួងធម្មការ និងសាសនា

ក្រសួងសុខាភិបាល

វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ

គណៈកម្មាធិការជាតិសម្រាប់
ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
នៅថ្នាក់ក្រោមជាតិ

Together, building stronger child
protection systems

# អារម្ភកថា

ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ប្រទេសកម្ពុជាមានការអភិវឌ្ឍ និងរីកចម្រើនលើគ្រប់វិស័យ។ សេចក្តីប្រាថ្នា និងការខិតខំរបស់រាជរដ្ឋាភិបាល គឺប្រែក្លាយឋានៈរបស់កម្ពុជាឱ្យទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងទៅជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ អាទិភាពគោលនយោបាយចម្បងរបស់រាជរដ្ឋាភិបាលគឺការរក្សាសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់រឹងមាំ ដែលជាបុរេលក្ខខណ្ឌដ៏ចាំបាច់ដើម្បីសម្រេចបាននូវកំណើនសេដ្ឋកិច្ច កាត់បន្ថយអត្រាភាពក្រីក្រ ភាពរងគ្រោះ និងងាយរងគ្រោះរបស់ប្រជាជន ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជនគ្រប់វ័យ និងគ្រប់ស្រទាប់ ធ្វើឱ្យជីវភាពប្រជាជនមានភាពប្រសើរឡើង។

ដើម្បីរួមចំណែកសម្រេចឱ្យបានចក្ខុវិស័យរយៈពេលវែងរបស់រាជរដ្ឋាភិបាល និងទប់ស្កាត់ការរំលោភបំពាន ការកេងប្រវ័ញ្ច គ្រប់រូបភាព គ្រប់ទម្រង់លើជនរងគ្រោះនិងងាយរងគ្រោះ ជាពិសេសកុមារ ដែលជាទំពាំងស្នងឫស្សី ជាអ្នកបន្តវេនប្រកបដោយសក្តានុពលនាពេលអនាគត ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានបង្កើតក្របខ័ណ្ឌត្រួតពិនិត្យតាមដានកិច្ចការពារកុមារ។ គោលបំណងនៃការរៀបចំឯកសារក្របខ័ណ្ឌនេះ គឺដើម្បីប៉ាន់ប្រមាណប្រព័ន្ធកិច្ចការពារកុមារក្នុងប្រទេសកម្ពុជា កំណត់អំពីតួនាទី ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន និងអ្នកដែលមានចំណែកពាក់ព័ន្ធ ក្នុងការតាក់តែង ច្បាប់ គោលនយោបាយ ផែនការ ការបង្ការ ការការពារ ការអន្តរាគមន៍ និងការផ្តល់សេវាឆ្លើយតបនឹងតម្រូវការជាក់ស្តែងរបស់កុមារ។

ឯកសារក្របខ័ណ្ឌត្រួតពិនិត្យតាមដានកិច្ចការពារកុមារ ត្រូវបានដឹកនាំ និងសម្របសម្រួល ដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយក្រសួង ស្ថាប័ន និងអង្គការដៃគូពាក់ព័ន្ធ។ ក្នុងនាមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខ្ញុំមានកិត្តិយស និងមោទនភាព ដែលបានដឹកនាំសម្របសម្រួលក្នុងការបង្កើតឯកសារក្របខ័ណ្ឌនេះ និងសូមកោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការដៃគូ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ លះបង់ទាំងកម្លាំងកាយ កម្លាំងចិត្តយ៉ាងសស្រាក់សស្រាំមិនខ្លាចនឿយហត់ និងផ្តល់នូវពុទ្ធិល្អៗសម្រាប់រៀបចំឯកសារនេះឡើង។ ក្រសួងសូមថ្លែងអំណរគុណដល់អង្គការយូនីសេហ្វ (UNICEF) និងទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) សម្រាប់ការគាំទ្រផ្នែកបច្ចេកទេស និងថវិកា ជាមួយការប្តេជ្ញាចិត្តបន្តគាំទ្រដល់ការបង្កើតប្រព័ន្ធគ្រប់គ្រងព័ត៌មានកិច្ចការពារកុមារ (CPIMS) ក្នុងប្រទេសកម្ពុជា។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រួមជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការដៃគូ មានការតាំងចិត្តខ្ពស់ និងការប្តេជ្ញាចិត្តយ៉ាងមុតមាំធ្វើការជាដៃគូយ៉ាងជិតស្និទ្ធ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងឡាយ សំដៅ បង្ការ ទប់ស្កាត់ ការពារឧត្តមប្រយោជន៍របស់កុមារ និងលើកកម្ពស់សិទ្ធិរបស់កុមារ។

ខ្ញុំជឿជាក់ និងសង្ឃឹមយ៉ាងមុតមាំថា ឯកសារក្របខ័ណ្ឌនេះ នឹងចូលរួមលើកកម្ពស់កិច្ចការពារកុមារ និងគុណភាពជីវិតរបស់កុមារឱ្យកាន់តែប្រសើរឡើង។

ថ្ងៃ សុក្រ ២កើត ខែ បឋមាសាឍ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០២១

**រដ្ឋមន្ត្រី**

**វង សូត**

# មាតិកា


អក្សរកាត់ ១
សេចក្តីផ្តើម ២
ដំណើរការនៃការរៀបចំក្របខ័ណ្ឌការងារត្រួតពិនិត្យតាមដាន ៤
គោលការណ៍ស្នូលនៃក្របខ័ណ្ឌការងារត្រួតពិនិត្យតាមដានកិច្ចការពារកុមារក្នុងប្រទេសកម្ពុជា ៦
កម្រងទិន្នន័យនៃសូចនាករ និងភាពមានកម្រិត ៨
វិស័យទី១៖ ច្បាប់ គោលនយោបាយ និងផែនការ ២៣
វិស័យទី២៖ សមត្ថភាពនៃប្រព័ន្ធកិច្ចការពារកុមារ ៣៩
វិស័យទី៣៖ ការបង្ការ និងការពារ ៤៦
វិស័យទី៤៖ សេវាឆ្លើយតប និងគាំទ្រចំពោះកិច្ចការពារកុមារ ៦១
វិស័យទី៥៖ កម្រិតវិសាលភាពនៃបញ្ហា និង កត្តាហានិភ័យ ៧៦

# អក្សរកាត់

| | |
|---|---|
| CCWC | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ |
| CDHS | អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា |
| CMAA | អាជ្ញាធរមីនកម្ពុជា |
| CNCC | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ |
| CPIMS | ប្រព័ន្ធគ្រប់គ្រងព័ត៌មានកិច្ចការពារកុមារ |
| CSES | ការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា |
| CVACS | អង្កេតស្តីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា |
| DoSVY | មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| ERWs | សំណល់ជាតិផ្ទុះពីសង្គ្រាម |
| FCF | បណ្តាញអង្គការថែទាំកុមារក្នុងគ្រួសារជាអាទិភាពចម្បង |
| GDP | អគ្គនាយកដ្ឋានផែនការ |
| ILO | អង្គការពលកម្មអន្តរជាតិ |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MoCR | ក្រសួងធម្មការ និងសាសនា |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MoH | ក្រសួងសុខាភិបាល |
| MoI | ក្រសួងមហាផ្ទៃ |
| MoJ | ក្រសួងយុត្តិធម៌ |
| MoLVT | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MoP | ក្រសួងផែនការ |
| MoSVY | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| MoWA | ក្រសួងកិច្ចការនារី |
| NIS | វិទ្យាស្ថានជាតិស្ថិតិ |
| OSVY | ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្រុក |
| RCI | មណ្ឌលថែទាំកុមារ |
| SDGs | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| UNICEF | មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ |

# សេចក្តីផ្តើម

ឯកសារក្របខ័ណ្ឌត្រួតពិនិត្យកិច្ចការពារកុមារក្នុងប្រទេសកម្ពុជា ជាឯកសារដ៏មានសារៈសំខាន់ក្នុងការប៉ាន់ប្រមាណប្រព័ន្ធកិច្ចការពារកុមារក្នុងប្រទេសកម្ពុជា ដែលមានសូចនាករស្នូលចំនួន ៥០។ សេចក្តីព្រាងនៃឯកសារនេះត្រូវបានពិនិត្យ កែសម្រួលតាម រយៈសិក្ខាសាលាចំនួន ២ដង គឺសិក្ខាសាលាស្តីពីការបង្កើតប្រព័ន្ធគ្រប់គ្រងព័ត៌មានកិច្ចការពារកុមារ (CPIMS) ក្នុងប្រទេសកម្ពុជា កាលពីខែកញ្ញា ឆ្នាំ២០១៨ និងសិក្ខាសាលាកម្រិតបច្ចេកទេសដើម្បីពិនិត្យ និងកែសម្រួលលើសូចនាករប្រព័ន្ធកិច្ចការពារកុមារ ក្នុងខែមិថុនា ឆ្នាំ២០១៩ និងកិច្ចប្រជុំនានាទាំងកម្រិតបច្ចេកទេសនិងកម្រិតនយោបាយដើម្បីផ្តល់ការឯកភាពលើក្របខ័ណ្ឌត្រួតពិនិត្យនេះ ព្រមទាំងត្រូវបានពិនិត្យកែសម្រួលជាបន្តបន្ទាប់ដោយផ្អែកលើការផ្តល់មតិយោបល់ និងធាតុចូលពីអ្នកពាក់ព័ន្ធ។

គោលបំណងចម្បងនៃឯកសារនេះគឺ៖

- ប្រើប្រាស់ជាមគ្គុទ្ទេសក៍ណែនាំសម្រាប់បង្កលក្ខណៈឱ្យមានការបង្កើតប្រព័ន្ធគ្រប់គ្រងព័ត៌មានកិច្ចការពារកុមារជាពិសេសខណៈពេលដែលពុំទាន់មានក្របខ័ណ្ឌការងារតាមវិស័យដទៃទៀត ស្តីពីផែនការកិច្ចការពារកុមារ ឬសូចនាករត្រួតពិនិត្យសម្រាប់វិស័យកិច្ចការពារកុមារជារួមនៅក្នុងប្រទេសកម្ពុជា។
- ផ្តល់ក្របខ័ណ្ឌការងារមួយទាក់ទងនឹងការទទួលខុសត្រូវរាយការណ៍អំពីទិន្នន័យ ជាពិសេសផ្តល់នូវការណែនាំច្បាស់លាស់សម្រាប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ អំពីប្រភេទព័ត៌មានដែលគួរប្រមូល និងរាយការណ៍ដើម្បីធ្វើការពិនិត្យផ្ទៀងផ្ទាត់ និងវិភាគនៅថ្នាក់ជាតិ។
- ផ្តល់នូវក្របខ័ណ្ឌការងារច្បាស់លាស់មួយសម្រាប់ធ្វើការវិភាគជារួម និងរៀបចំរបាយការណ៍ដោយផ្អែកលើប្រព័ន្ធគ្រប់គ្រងព័ត៌មានកិច្ចការពារកុមារ (CPIMS)។
- ផ្តល់នូវបញ្ជីរាយនាមអំពីសូចនាករស្នូលសម្រាប់តំណាងឱ្យ វិស័យកិច្ចការពារកុមារ ប៉ុន្តែវាពុំមែនជាបញ្ជីរាយនាមគ្រប់ជ្រុងជ្រោយឡើយ។ ក្របខ័ណ្ឌការងារត្រួតពិនិត្យនេះ គប្បីទទួលបានការបំពេញបន្ថែមពីក្របខ័ណ្ឌត្រួតពិនិត្យប្រតិបត្តិ ដែលចាំបាច់សម្រាប់ការរៀបចំកម្មវិធីលម្អិតជាងនេះនៅកម្រិតប្រតិបត្តិការ។

ឯកសារក្របខ័ណ្ឌនេះជាឧបករណ៍ជាតិមួយ សម្រាប់តាមដានវឌ្ឍនភាពកិច្ចការពារកុមារ ជាពិសេសដោយធ្វើការរួមគ្នាជាពហុភាគីពាក់ព័ន្ធដែលនឹងអាចឆ្លើយនូវសំនួរចំនួន ២ខាងក្រោម៖

- តើកម្មវិធីកិច្ចការពារកុមារកំពុងតែដំណើរការទៅតាមគោលបំណង និងមានប្រសិទ្ធភាព និងប្រសិទ្ធផលដែរឬទេ ?
- តើកម្មវិធីកិច្ចការពារកុមារសម្រេចបាននូវលទ្ធផលដែលចង់បាន និងគោលបំណងរយៈពេលយូរអង្វែងដែរឬទេ ?

សូមកត់សម្គាល់ថា ក្របខ័ណ្ឌត្រួតពិនិត្យនេះមិនមានរាប់បញ្ចូលគោលដៅឡើយ។ ដូច្នេះទិន្នន័យដែលនឹងឆ្លងកាត់ក្របខ័ណ្ឌនេះ គឺត្រូវបានប្រើប្រាស់សំរាប់ការរៀបចំផែនការតាមវិស័យ ដើម្បីកំណត់គោលដៅ និងពេលវេលា។ ហេតុនេះក្របខ័ណ្ឌត្រួតពិនិត្យនេះត្រូវបានចាត់ទុកថាជាធាតុផ្សំ (សំខាន់) មួយនៃយុទ្ធសាស្ត្រត្រួតពិនិត្យ តាមដាន និងវាយតម្លៃទូលំទូលាយសម្រាប់វិស័យកិច្ចការពារកុមារ ដែលគប្បីអភិវឌ្ឍឱ្យមាននៅពេលអនាគត។ គោលបំណងនៃយុទ្ធសាស្ត្រត្រួតពិនិត្យតាមដាន និងវាយតម្លៃទៅលើកិច្ចការពារកុមារទូលំទូលាយ រួមមាន[៩]៖

- ផ្តល់នូវភស្តុតាងសុក្រឹត្យ និងគួរឱ្យជឿជាក់បាន ដែលបង្កលក្ខណៈឱ្យអ្នកធ្វើសេចក្តីសម្រេចចិត្ត អាចកែសម្រួលជាបន្តបន្ទាប់នូវការផ្តល់សេវាកិច្ចការពារកុមារ ការអនុវត្តសកម្មភាពរបស់ខ្លួន ធាតុចេញ យុទ្ធសាស្ត្រ និងដំណើរការ ក្នុងការសម្រេចឱ្យបាននូវលទ្ធផលការងារដែលចង់បាន និងដើម្បីបង្កើនកម្រិតវិសាលភាពដែលកម្ពុជាកំពុងខិតខំសម្រេចឱ្យបាននូវលទ្ធផលការងារផ្នែកកិច្ចការពារកុមារជាសកល ព្រមទាំងសម្របសម្រួលឱ្យមានការផ្លាស់ប្តូរការប្រព្រឹត្ត ឥរិយាបថ និងជំនឿរបស់តួអង្គសំខាន់ៗ។
- រាជរដ្ឋាភិបាលកម្ពុជាដឹកនាំតួអង្គពាក់ព័ន្ធព្រមទាំងវិស័យផ្សេងៗគ្នាដែលកំពុងចូលរួម អាចរៀនសូត្រថាតើសកម្មភាព លទ្ធផលរយៈពេលខ្លី លទ្ធផលរយៈពេលវែង យុទ្ធសាស្ត្រ និងដំណើរការណាខ្លះ ដែលទំនងនឹងមានឥទ្ធិពលធ្វើឱ្យមានភាពប្រសើរឡើងទៅលើសមិទ្ធិកម្ម និងសមធម៌នៃគោលបំណងកិច្ចការពារកុមារក្នុងប្រទេសកម្ពុជា ជារួមព្រមទាំងក្នុងនាមជាបុគ្គល ដោយមិនប្រកាន់អំពីយេនឌ័រ កម្រិតប្រាក់ចំណូល ទីតាំង និងពិការភាពឡើយ។
- បង្ហាញពីគណនេយ្យភាពក្នុងការអនុវត្តផែនការសកម្មភាព និងផែនការថវិកា។

[9] Shoobridge J & Khadka S, 2019, CPIMS កម្ពុជា៖ ការកំណត់ផែនទី និងជំហានបន្ទាប់, UNICEF, Cambodia

# ដំណើរការនៃការរៀបចំក្របខ័ណ្ឌការងារត្រួតពិនិត្យតាមដាន

សូមកត់សម្គាល់ថា ដោយសារតែគ្មានផែនការយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារ និងក្របខ័ណ្ឌលទ្ធផល ទើបនាំឱ្យក្របខ័ណ្ឌសូចនាករត្រូវបានរៀបចំឡើងដោយផ្អែកលើឯកសារជាតិជាក់លាក់ដែលមានស្រាប់ ដូចជាផែនការស្តីពីអំពើហិង្សាលើកុមារ ផែនការពង្រឹងការថែទាំកុមារ និងសមាហរណកម្មចំនួន ៣០% ពីមណ្ឌលថែទាំកុមារទៅកាន់គ្រួសារប្រកបដោយសុវត្ថិភាព ពីឆ្នាំ២០១៦ ទៅឆ្នាំ២០១៨ និងឯកសារអន្តរជាតិនានាដែលពាក់ព័ន្ធ ដូចជាក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG ២០១៥-២០៣០) និងយុទ្ធសាស្ត្រ INSPIRE។ ពេលដែលផែនការវិស័យកិច្ចការពារកុមារ ត្រូវបានរៀបចំបង្កើតឡើងសម្រាប់ប្រទេសកម្ពុជា ក្របខ័ណ្ឌសូចនាករ នឹងត្រូវបានកែសម្រួលដើម្បីបន្សុីទៅនឹងផែនការ និងយុទ្ធសាស្ត្រតាមវិស័យផងដែរ។

ក្របខ័ណ្ឌត្រួតពិនិត្យកិច្ចការពារកុមារ មានមូលដ្ឋានព័ត៌មានពីគោលការណ៍ណែនាំអន្តរជាតិ ក្របខ័ណ្ឌការងារ និងសៀវភៅណែនាំសម្រាប់ការអភិវឌ្ឍក្របខ័ណ្ឌត្រួតពិនិត្យតាមដាន និងវាយតម្លៃកិច្ចការពារកុមារ។ សេចក្តីព្រាងក្របខ័ណ្ឌសូចនាករកិច្ចការពារកុមារ ត្រូវបានពិនិត្យកែសម្រួលដោយភាគីពាក់ព័ន្ធនៅក្នុងសិក្ខាសាលាស្តីពីការបង្កើតប្រព័ន្ធគ្រប់គ្រងព័ត៌មានកិច្ចការពារកុមារ (CPIMS) ដែលបានធ្វើឡើងក្នុងខែកញ្ញា ឆ្នាំ២០១៨ និងសិក្ខាសាលាកម្រិតបច្ចេកទេសដើម្បីពិនិត្យ និងកែសម្រួលលើសូចនាករប្រព័ន្ធកិច្ចការពារកុមារដែលមានអ្នកចូលរួមមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានធ្វើឡើងក្នុងខែមិថុនា ឆ្នាំ២០១៩។ ឯកសារក្របខ័ណ្ឌនេះត្រូវបានឆ្លងការពិភាក្សា និងឯកភាពក្នុងកិច្ចប្រជុំកម្រិតនយោបាយរៀបចំដោយក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំក្រសួង ស្ថាប័ន និងអង្គការពាក់ព័ន្ធ មានក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ ក្រសួងផែនការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកិច្ចការនារី ក្រសួងធម្មការ និងសាសនា និងតំណាងអង្គការយូនីសេហ្វ (UNICEF) អង្គការFamily Care First/React (Save the Children) និងតំណាងកម្មវិធីភាពជាដៃគូដើម្បីកុមារ/អង្គការFriends International។ នៅក្នុងសិក្ខាសាលាកម្រិតបច្ចេកទេសមានអ្នកចូលរួមពីក្រសួង ស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាល និងយូនីសេហ្វ។ ឯកសារនេះត្រូវបានអនុម័តដោយភាគីពាក់ព័ន្ធភាគច្រើន។

ឯកសារខាងក្រោមត្រូវបានពិនិត្យឡើងវិញ៖

១. ផែនការសកម្មភាពដើម្បីបង្ការ និងឆ្លើយតបទៅនឹងអំពើហិង្សាលើកុមារ ២០១៧-២០២១ (ក្រសួង ស.អ.យ ២០១៧)
២. ផែនការពង្រឹងការថែទាំកុមារ និងសមាហរណកម្មចំនួន ៣០% ពីមណ្ឌលថែទាំកុមារ ឱ្យវិលត្រឡប់ទៅគ្រួសាររបស់ពួកគេវិញដោយសុវត្ថិភាព ឆ្នាំ២០១៦-២០១៨
៣. ស្ថិតិស្តីពីកិច្ចការពារកុមារនៅកម្ពុជា (យូនីសេហ្វ ២០១៨)
៤. សៀវភៅណែនាំ INSPIRE និងសេចក្តីណែនាំសម្រាប់ការរៀបចំសូចនាករ
៥. សូចនាករនៃគោលដៅអភិវឌ្ឍប្រកបដោយចីរភាព ដែលពាក់ព័ន្ធទៅនឹងកិច្ចការពារកុមារ
៦. របាយការណ៍សង្ខេបស្តីពីសូចនាករសិទ្ធិកុមារ និងក្របខ័ណ្ឌត្រួតពិនិត្យ (CNCC ២០១២)
៧. កញ្ចប់ធនធានកិច្ចការពារកុមារ៖ របៀបរៀបចំផែនការ ត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីកិច្ចការពារកុមារ (យូនីសេហ្វ ២០១៥/កែសម្រួលឡើងវិញក្នុងឆ្នាំ២០១៨)
៨. ផែនការយុទ្ធសាស្ត្ររបស់អង្គការយូនីសេហ្វ ២០១៨-២០២១៖ វិស័យគោលដៅទី៣ “កុមារគ្រប់រូបត្រូវបានការពារពីអំពើហិង្សា និងការកេងប្រវ័ញ្ច” សៀវភៅណែនាំអំពីសូចនាករ (យូនីសេហ្វ ២០១៨)
៩. ការកំណត់ផែនទីគ្រប់គ្រងព័ត៌មានកិច្ចការពារកុមារ៖ ឆ្ពោះទៅរកប្រព័ន្ធឃ្លាំមើលទិន្នន័យមួយក្នុងប្រទេសឥណ្ឌូនេស៊ី
១០. បទដ្ឋានតំបន់អាស៊ីប៉ូស៊ីហ្វិក (យូនីសេហ្វ ២០១២)

# គោលការណ៍ស្នូលនៃក្របខ័ណ្ឌការងារត្រួតពិនិត្យតាមដានកិច្ចការពារកុមារក្នុងប្រទេសកម្ពុជា

គោលការណ៍ស្នូលនៃក្របខ័ណ្ឌត្រួតពិនិត្យកិច្ចការពារកុមារក្នុងប្រទេសកម្ពុជា រួមមាន៖

- **ការទទួលខុសត្រូវ៖** ការត្រួតពិនិត្យតាមដាន និងវាយតម្លៃទៅលើកិច្ចការពារកុមារ គឺជាការទទួលខុសត្រូវពហុវិស័យ និងមានការពាក់ព័ន្ធដៃគូជាច្រើន។ វាគឺជាការទទួលខុសត្រូវរួមគ្នា រវាងក្រសួង ស.អ.យ (ក្នុងនាមជាតួអង្គនាំមុខ) និងក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធ។
- **ការធ្វើសុខដុមនីយកម្ម៖** ក្របខ័ណ្ឌត្រួតពិនិត្យគួរបន្សុំទៅនឹងក្របខ័ណ្ឌត្រួតពិនិត្យរបស់វិស័យ និងដៃគូនីមួយៗ។ ក្នុងករណីដែលអាចធ្វើទៅបាន ក្របខ័ណ្ឌត្រួតពិនិត្យកិច្ចការពារកុមារ ត្រូវប្រើប្រាស់រចនាសម្ព័ន្ធ ដំណើរការសូចនាករ និងព័ត៌មានត្រួតពិនិត្យតាមដាន និងវាយតម្លៃរបស់ដៃគូ និងទីភ្នាក់ងារនានា។ ក្នុងករណីដែលអាចធ្វើទៅបាន ត្រូវបន្សុំទៅនឹងសូចនាករអន្តរជាតិ ដូចជា SDGs និង INSPIRE។ ប្រទេសកម្ពុជាបានគាំទ្ររបៀបវារៈ SDG ២០១៥-២០៣០ ព្រមទាំងត្រួតពិនិត្យសូចនាករដែលពាក់ព័ន្ធ។
- **បទដ្ឋាន៖** ក្របខ័ណ្ឌត្រួតពិនិត្យកិច្ចការពារកុមារ នឹងឆ្លុះបញ្ចាំងអំពីបទដ្ឋានរបស់វិស័យនីមួយៗដែលទទួលខុសត្រូវក្នុងការផ្តល់សេវាកិច្ចការពារកុមារ (ទាំងវិស័យដែលត្រូវបានកំណត់អាណត្តិការងារស្នូល និងវិស័យគាំទ្រ) ព្រមទាំងវិស័យដែលត្រួតពិនិត្យ និងផ្តល់សេវាទាំងនេះ។
- **ការចែករំលែកចំណេះដឹង៖** ព័ត៌មានពីការត្រួតពិនិត្យតាមដាន និងវាយតម្លៃជួយគាំទ្រដល់ការបន្តរៀនសូត្រតាមរយៈការផ្តល់ព័ត៌មានដែលសុក្រឹត្យ គួរឱ្យជឿជាក់បាន និងទាន់ពេលវេលា ដល់អ្នកធ្វើសេចក្តីសម្រេចចិត្ត និងអ្នកពាក់ព័ន្ធនានា។ ក្របខ័ណ្ឌត្រួតពិនិត្យកិច្ចការពារកុមារ គាំទ្រដល់ការផ្តល់ជូនអ្នកពាក់ព័ន្ធផ្សេងៗគ្នានូវចំណេះដឹងពាក់ព័ន្ធនឹងលទ្ធផលកិច្ចការពារកុមារ ដែលគាំទ្រដល់ការធ្វើសេចក្តីសម្រេចចិត្តក្រោមមូលដ្ឋាននៃភស្តុតាង ទាក់ទងនឹងការអភិវឌ្ឍ បច្ចុប្បន្ន និងអនាគត ដែលនឹងមានឥទ្ធិពលទៅលើកិច្ចការពារកុមារនៅក្នុងប្រទេសកម្ពុជា។ ចំណេះដឹងនេះរួមមានភស្តុតាងទាក់ទងនឹងលទ្ធផលរយៈពេលវែង/ផលប៉ះពាល់ ដែលបណ្តាលពីកិច្ចការពារកុមារ ប្រសិទ្ធផលនៃការសម្រេចបានលទ្ធផលរយៈពេលវែង/ផលប៉ះពាល់ និងកម្រិតវិសាលភាពដែលលទ្ធផលរយៈពេលវែង/ផលប៉ះពាល់មានសង្គតិភាពទៅនឹងអាទិភាពជាតិ។
- **កិច្ចគាំទ្រសម្រាប់ការសម្រេចចិត្តផ្អែកលើភស្តុតាង៖** ការត្រួតពិនិត្យតាមដាន និងវាយតម្លៃ ត្រូវវាស់ស្ទង់ទៅលើកម្រិតវិសាលភាពនៃវឌ្ឍនភាពក្នុងការសម្រេចនូវលទ្ធផលដែលគេចង់បាន (សំដៅចំពោះចំណុច "អ្វី" ដូចមានកំណត់នៅក្នុងក្របខ័ណ្ឌការងារជាក់ស្តែង) និងយុទ្ធសាស្ត្រ និងដំណើរការនានាដែលកំពុងត្រូវបានប្រើប្រាស់ មានប្រសិទ្ធភាព និងប្រសិទ្ធផលកម្រិតណា ក្នុងការគាំទ្រឱ្យសម្រេចបាននូវលទ្ធផលរយៈពេលវែង (ចំណុចទាក់ទងនឹង "ដោយរបៀបណា" ដូចមានកំណត់នៅក្នុងយុទ្ធសាស្ត្រអនុវត្តកម្មវិធីរបស់ទីភ្នាក់ងារនីមួយៗ)។

- **ការធានាឱ្យមានការកែលម្អកម្មវិធីៈ** ក្របខ័ណ្ឌត្រួតពិនិត្យកិច្ចការពារកុមារ ជំរុញឱ្យមាននូវការផ្តល់មតិយោបល់ត្រឡប់ជូនដល់ប្រធានគ្រប់គ្រងគម្រោងកម្មវិធី និងអ្នកពាក់ព័ន្ធដទៃទៀត ព្រមទាំងការរៀនសូត្រដែលអាចជួយកែលម្អដល់ការរៀបចំកម្មវិធីនាពេលបច្ចុប្បន្ន និងអនាគត។
- **ការធានាឱ្យមានគណនេយ្យភាពៈ** ក្របខ័ណ្ឌត្រួតពិនិត្យកិច្ចការពារកុមារ បង្កលក្ខណៈឱ្យមានការផ្តល់ជូនដល់អ្នកពាក់ព័ន្ធ ម្ចាស់ជំនួយ និងភាគីដទៃទៀតដែលមានចំណាប់អារម្មណ៍ នូវគំហើញដែលមានមូលដ្ឋានផ្អែកលើភស្តុតាង ទាំងវិជ្ជមាន និងអវិជ្ជមាន ទាក់ទងនឹងគម្រោងកម្មវិធីរបស់រដ្ឋាភិបាល។
- **ការបញ្ជាក់អំពីតួនាទី និងការទទួលខុសត្រូវៈ** ក្របខ័ណ្ឌត្រួតពិនិត្យកិច្ចការពារកុមារ ផ្តល់ការបញ្ជាក់អំពីតួនាទី និងការទទួលខុសត្រូវសម្រាប់ត្រួតពិនិត្យកិច្ចការពារកុមារ ចំពោះគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់។
- **ការធានាឱ្យមានការវាយតម្លៃៈ** រាល់គម្រោងកម្មវិធីទាំងអស់ ដែលអនុវត្តដោយអង្គភាពដូចមានរៀបរាប់ខាងលើ និងមានកិច្ចគាំទ្រពីមូលនិធិក្នុងស្រុក និងបរទេស ត្រូវមានការវាយតម្លៃឱ្យបានញឹកញាប់ទៅតាមភាពចាំបាច់។ ក្នុងនោះរួមមានគម្រោងកម្មវិធី ដែលអនុវត្តដោយអង្គការសង្គមស៊ីវិល និងភាគីទីបីដទៃទៀតក្រោមកិច្ចសន្យារបស់ស្ថាប័នអនុវត្តរបស់រដ្ឋាភិបាល។
- **កិច្ចសហការៈ** ក្របខ័ណ្ឌត្រួតពិនិត្យកិច្ចការពារកុមារ គប្បីលើកទឹកចិត្តឱ្យមានកិច្ចសហការ និងកិច្ចសន្ទនារវាងតួអង្គ និងអ្នកពាក់ព័ន្ធសំខាន់ ព្រមទាំងលើកទឹកចិត្តឱ្យមានការប្រើប្រាស់ព័ត៌មាន និងការវិភាគការងារត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីផ្តល់នូវមូលដ្ឋានព័ត៌មានជារួមសម្រាប់ការរៀបចំផែនការ និងការអនុវត្តឡើងវិញ។

# កម្រងទិន្នន័យនៃសូចនាករ និងភាពមានកម្រិត

ផ្នែកនេះផ្តល់នូវកម្រងទិន្នន័យ សម្រាប់សូចនាករស្នូលដែលត្រូវបានកំណត់សម្រាប់តាមដាន នៅកម្រិតថ្នាក់ជាតិតាមរយៈ CPIMS។ ការប្រមូលទិន្នន័យសម្រាប់សូចនាករទាំងនេះមានលក្ខណៈស្មុគស្មាញ អាស្រ័យដោយស្ថាប័នផ្សេងៗគ្នាមានប្រព័ន្ធព័ត៌មានឯករាជ្យ ដែលតម្រូវឱ្យមានការសម្របសម្រួល ដើម្បីជួយបង្កើតឱ្យមានរូបភាពគ្រប់ជ្រុងជ្រោយមួយអំពីកិច្ចការពារកុមារក្នុងប្រទេសកម្ពុជា។ បន្ថែមពីនេះទៀត ទិន្នន័យជាច្រើនមានលក្ខណៈរសើបខ្លាំង ដែលតម្រូវឱ្យរក្សាការសម្ងាត់ខ្ពស់។ កម្រងទិន្នន័យនេះត្រូវបានបង្កើតឡើងដើម្បីផ្តល់នូវវេទិកាមួយសម្រាប់ការធ្វើសុខដុមនីយកម្មលក្ខណៈវិនិច្ឆ័យជាក់លាក់មួយចំនួន។ ខណៈពេលដែលដំណើរការមានការវិវឌ្ឍន៍ ចំណុចនេះគប្បីធ្វើការកែលម្អបន្ថែម និងគប្បីបន្ថែមលក្ខណៈវិនិច្ឆ័យដែលបានជួបប្រទះ ដើម្បីធានាថាបញ្ហាដែលបានរកឃើញនៅក្នុងដំណាក់កាលទី១នៃការប្រមូលទិន្នន័យ ត្រូវបានដោះស្រាយ និងកែសម្រួល។ ក្នុងលក្ខណៈជាផ្នែកមួយនៃដំណើការប្រមូលទិន្នន័យ គប្បីបង្កើតឱ្យមានទម្រង់ជាក់លាក់សម្រាប់ប្រមូល និងផ្ទេរទិន្នន័យ និងកំណត់វកពិធីសារវិធីសាស្រ្តពិនិត្យផ្ទៀងផ្ទាត់ និងភាពគ្រប់ជ្រុងជ្រោយ ព្រមទាំងគុណភាពនៃទិន្នន័យ។ បច្ចុប្បន្នលក្ខណៈវិនិច្ឆ័យខាងក្រោមកំពុងត្រូវបានពិចារណា និងកំណត់យក៖

១. ឈ្មោះសូចនាករ
២. និយមន័យ
៣. លទ្ធផលរំពឹងទុក
៤. វិធីសាស្រ្តគណនា
៥. ប្រភពទិន្នន័យ
៦. កម្រិតភាពញឹកញាប់
៧. កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ
៨. ស្ថាប័នទទួលខុសត្រូវសម្រាប់ការរាយការណ៍អំពីទិន្នន័យ
៩. ឯកសារយោង (ប្រសិនបើមាន)
១០. កំណត់សម្គាល់ (ប្រសិនបើមាន)
១១. តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ (ប្រសិនបើមាន)

## សូចនាករទាំង ៥០ នេះត្រូវបានរៀបចំទៅតាមវិស័យស្នូលចំនួន៥ នៃកិច្ចការពារកុមារ ដូចខាងក្រោម៖



| ទិដ្ឋភាព | សូចនាករ | ស្ថាប័នដឹកនាំ | ប្រភពទិន្នន័យ |
|---|---|---|---|
| **វិស័យទី១៖ ច្បាប់ គោលនយោបាយ និងផែនការ**<br>គោលបំណង៖ ដើម្បីធានាថាមានច្បាប់ គោលនយោបាយ និងផែនការពាក់ព័ន្ធ សម្រាប់ធានាថាកុមារត្រូវបានការពារពីគ្រប់ទម្រង់ទាំងអស់នៃអំពើហិង្សា និងទទួលបានកិច្ចគាំទ្រនៅពេលដែលត្រូវការ។<br>ធានាឱ្យបាននូវការអនុវត្ត និងការពង្រឹងច្បាប់ ដើម្បីបង្ការអាកប្បកិរិយាហិង្សា កាត់បន្ថយការប្រើប្រាស់គ្រឿងស្រវឹងហួសប្រមាណ និងរឹតបន្តឹងលទ្ធភាពរបស់យុវជនក្នុងការទទួលបានកាំភ្លើង និងអាវុធដទៃទៀត (យុទ្ធសាស្ត្រទី១របស់ INSPIRE៖ ការអនុវត្ត និងការពង្រឹងច្បាប់) | | | |
| ច្បាប់ គោលនយោបាយ និងបទដ្ឋាន នីតិវិធីប្រតិបត្តិការ (SOPs) ទាក់ទងនឹងការឆ្លើយតបរបស់ស្ថាប័ន និងការឆ្លើយតបរបស់អ្នកមានភារកិច្ចចំពោះ កិច្ចការពារកុមារ | ១.១ ច្បាប់ស្តីពីកិច្ចការពារកុមារត្រូវបានបង្កើត | CNCC | ច្បាប់ស្តីពីកិច្ចការពារកុមារ និងរបាយការណ៍ |
| | ១.២ ច្បាប់នានាដែលការពារកុមារពីការទទួលរងទណ្ឌកម្មលើរាងកាយ និងទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារត្រូវបានពិនិត្យ និងធ្វើវិសោធនកម្ម ដើម្បីហាមឃាត់ការប្រើទណ្ឌកម្មលើរាងកាយកុមារនៅក្នុងគ្រប់បរិបទទាំងអស់ សម្រាប់គោលបំណងណាមួយ រួមទាំងឪពុកម្ដាយ និងអាណាព្យាបាល ដោយអនុលោមតាមបទដ្ឋានអន្តរជាតិ | MoJ-ក្រសួងយុត្តិធម៌ (នាយកដ្ឋានកិច្ចការរដ្ឋបាលនៃសាលាជម្រះក្ដី)<br>MoWA-អំពើហិង្សាក្នុងគ្រួសារ (នាយកដ្ឋានការពារផ្លូវច្បាប់)<br>MoEYS-បរិបទអប់រំ (នាយកដ្ឋានគោលនយោបាយ) | ក្រសួងយុត្តិធម៌ ច្បាប់ស្តីពីអប់រំ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ និងរបាយការណ៍ពី ក្រសួងយុត្តិធម៌ ក្រសួងកិច្ចការនារី និងក្រសួងអប់រំ យុវជន និងកីឡា |

| | | | |
|---|---|---|---|
| | ១.៣ បទដ្ឋាននីតិវិធីប្រតិបត្តិការសម្រាប់ការឆ្លើយតបចំពោះសេវាកិច្ចការពារកុមារត្រូវបានរៀបចំ | MoSVY (នាយកដ្ឋានសុខុមាលភាពកុមារ) | ច្បាប់ គោលការណ៍ជាតិ និងបទដ្ឋាននីតិវិធីប្រតិបត្តិការ (SOPs) |
| | ១.៤ ប្រព័ន្ធធានាគុណភាពសម្រាប់ការងារសេវាសង្គមត្រូវបានដំណើរការ | MoSVY (នាយកដ្ឋានសុខុមាលភាពសង្គម) | ឯកសារពាក់ព័ន្ធ |
| | ១.៥ គោលនយោបាយថែទាំជំនួសចំពោះកុមារ មានសង្គតភាពទៅនឹងគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិឆ្នាំ២០០៩ សម្រាប់ការថែទាំជំនួសចំពោះកុមារ | MoSVY (នាយកដ្ឋានសុខុមាលភាពកុមារ) | គោលនយោបាយពាក់ព័ន្ធ |
| | ១.៦ ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយស្តីពីពលកម្មកុមារ រួមទាំងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ អនុលោមតាមបទដ្ឋានអន្តរជាតិ | MoLVT (នាយកដ្ឋានការងារកុមារ) | ក្របខ័ណ្ឌ និងគោលនយោបាយពាក់ព័ន្ធ |
| ផែនការ និងយុទ្ធសាស្ត្រ | ១.៧ ផែនការតាមវិស័យ និងអន្តរវិស័យស្តីពីកិច្ចការពារកុមារត្រូវបានរៀបចំ | MoSVY, MoI, MoJ, MoEYS, MoH, MoLVT, MoCR, CNCC, CMAA, MoWA | ឯកសារផែនការ |

| ទិដ្ឋភាព | សូចនាករ | ស្ថាប័នដឹកនាំ | ប្រភពទិន្នន័យ |
|---|---|---|---|
| **វិស័យទី២៖ សមត្ថភាពនៃប្រព័ន្ធកិច្ចការពារកុមារ**<br>គោលបំណង៖ គៀងគរធនធានមនុស្ស និងធនធានហិរញ្ញវត្ថុដែលចាំបាច់ ដើម្បីធ្វើប្រតិបត្តិការប្រព័ន្ធកិច្ចការពារកុមារ។<br>Inspire: យុទ្ធសាស្ត្រដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា/ការត្រួតពិនិត្យតាមដាន និងវាយតម្លៃ | | | |
| សមត្ថភាពស្ថាប័ន | ២.១ ចំនួនបុគ្គលិកកម្លាំងសេវាសង្គម (បុគ្គលិករបស់រដ្ឋ និងបុគ្គលិករបស់អង្គការមិនមែនរដ្ឋាភិបាល ដែលផ្តល់សេវាសង្គម និងសេវាកិច្ចការពារកុមារ) | MoSVY<br>(នាយកដ្ឋានសុខុមាលភាពសង្គម) | ឯកសាររដ្ឋបាល |
| | ២.២ ចំនួនកន្លែងថែទាំកុមារនៅក្នុងប្រទេស | MoSVY<br>(នាយកដ្ឋានសុខុមាលភាពកុមារ) | ប្រព័ន្ធអធិការកិច្ច កន្លែងថែទាំជំនួស |
| | ២.៣ ចំនួនកន្លែងថែទាំកុមារតាមគ្រួសារក្នុងប្រទេស (គ្រួសារសាច់ញាតិជាផ្លូវការ និងគ្រួសារធម៌) | MoSVY<br>(នាយកដ្ឋានសុខុមាលភាពកុមារ) | ឯកសាររដ្ឋបាល |
| សមត្ថភាពផ្នែកហិរញ្ញវត្ថុ | ២.៤ ភាគរយនៃថវិការដ្ឋសម្រាប់កិច្ចការពារកុមារ (ថវិកាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) | ថវិកាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ<br>MEF-នាយកដ្ឋាន ថវិកា<br>នីយកម្មនៃអគ្គនាយកដ្ឋានថវិកា,<br>អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ,<br>នាយកដ្ឋានចំណាយថវិកានៃអគ្គនាយកដ្ឋានរតនាគារជាតិ<br>ថវិកាថ្នាក់ក្រោមជាតិ<br>MoI/NCDD(គណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ) | ថវិកា និងរបាយការណ៍<br>iSAF Database របស់ NCDD |

| | | | |
|---|---|---|---|
| | ២.៥ ភាគរយនៃមូលនិធិខាងក្រៅសម្រាប់កិច្ចការពារកុមារ (ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល) | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា-គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា (CDC-CRDB) | Cambodia ODA Database |

| ទិដ្ឋភាព | សូចនាករ | ស្ថាប័នដឹកនាំ | ប្រភពទិន្នន័យ |
|---|---|---|---|
| **វិស័យទី៣៖ ការបង្ការ និងកិច្ចការពារ (រាប់បញ្ចូលការដោះស្រាយកត្តាហានិភ័យ)**<br>គោលបំណង៖ ដើម្បីបង្កើនសមត្ថភាពគ្រួសារ និង សហគមន៍ លើផ្នែកសេដ្ឋកិច្ច និយាម និងគុណតម្លៃ ក្នុងការថែទាំកុមារ នៅក្នុងបរិយាកាសមួយដែលផ្ដល់ការចិញ្ចឹមបីបាច់ និងមានសុវត្ថិភាពចំពោះកុមារ។<br>(យុទ្ធសាស្ត្រទី២របស់ INSPIRE៖ និយាម និងគុណតម្លៃ; យុទ្ធសាស្ត្រទី៣របស់ INSPIRE៖ បរិយាកាសប្រកបដោយសុវត្ថិភាព ពោលគឺ ក្រៅពីផ្ទះ និងសាលារៀន; យុទ្ធសាស្ត្រទី៤របស់ INSPIRE៖ កិច្ចគាំទ្រពីឪពុកម្ដាយ និងអ្នកថែទាំ, យុទ្ធសាស្ត្រទី៥របស់ INSPIRE៖ ការពង្រឹងប្រាក់ចំណូល និងសេដ្ឋកិច្ច; យុទ្ធសាស្ត្រទី៧របស់ INSPIRE៖ ការអប់រំ និងបំណិនជីវិត) | | | |
| ការចុះបញ្ជីកំណើត | ៣.១ សមាមាត្រនៃកុមារដែលមានអាយុក្រោម ៥ឆ្នាំបានចុះបញ្ជីកំណើតនៅរដ្ឋបាលឃុំ សង្កាត់ | MoI/នាយកដ្ឋានអត្រានុកូលដ្ឋាននៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម<br>NCDD, MoP/NIS | កំណត់ហេតុរដ្ឋបាល,<br>CDB, CDHS |
| និយាម និងគុណតម្លៃ | ៣.២. ភាគរយនៃអ្នកថែទាំដែលយល់ស្របទៅនឹងភាពចាំបាច់ក្នុងការប្រើហិង្សាលើរាងកាយ សម្រាប់ការចិញ្ចឹមកុមារ | MoP/NIS | ការអង្កេតជាទៀងទាត់,<br>ការអង្កេត(PROTECT) |
| កិច្ចគាំទ្រពីឪពុកម្ដាយ និងអ្នកថែទាំ | ៣.៣. ភាគរយនៃកុមារី និងកុមារាអាយុចន្លោះពី ១-១៧ឆ្នាំ ដែលបានទទួលបទពិសោធន៍នៃការដាក់វិន័យអហិង្សាណាមួយពីសំណាក់អ្នកថែទាំក្នុងរយៈពេល១ខែចុងក្រោយ | MoP/NIS<br>UNICEF | ការអង្កេតជាក់លាក់និងរបាយការណ៍,<br>ការអង្កេត(PROTECT) |
| | ៣.៤. ចំនួនម្ដាយ ឪពុក អាណាព្យាបាលនិងអ្នកថែទាំ ដែលបានទទួលការអប់រំពីកម្មវិធីចិញ្ចឹមកូនបែបវិជ្ជមាន (កម្រិត១ កម្រិត២ កម្រិត៣) | MoWA | កំណត់ហេតុរដ្ឋបាល និងរបាយការណ៍<br>កម្មវិធី |

| | | | |
|---|---|---|---|
| សន្តិសុខផ្នែកសេដ្ឋកិច្ចរបស់គ្រួសារ | ៣.៥. ចំនួនកុមារដែលទទួលបានការឧបត្ថម្ភពីកម្មវិធីជាតិជំនួយសង្គម<br>៣.៥.ក ចំនួនកុមារពិការក្រីក្រតាមសហគមន៍ទទួលបានប្រាក់ឧបត្ថម្ភពីរបបគោលនយោបាយចំពោះជនពិការក្រីក្រតាមសហគមន៍<br>៣.៥.ខ ចំនួនកុមារអាយុក្រោម ២ឆ្នាំទទួលបានប្រាក់ឧបត្ថម្ភពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ<br>៣.៥.គ ចំនួនកុមារទទួលបានអាហារូបករណ៍ជាសាច់ប្រាក់ពីកម្មវិធីអាហារូបករណ៍សម្រាប់សិស្សក្រីក្រថ្នាក់បឋមសិក្សា និងមធ្យមសិក្សា<br>៣.៥.ឃ ចំនួនកុមារទទួលបានការឧបត្ថម្ភពីកម្មវិធីផ្តល់អាហារតាមសាលារៀន ដោយប្រើប្រាស់កសិផលក្នុងសហគមន៍ | MoSVY (នាយកដ្ឋានសុខុមាលភាពសង្គម, នាយកដ្ឋានសុខុមាលភាពជនពិការ), MoEYS (ការិយាល័យអាហារូបករណ៍នៃនាយកដ្ឋានបឋមសិក្សា នឹងការិយាល័យអាហារូបករណ៍នៃនាយកដ្ឋានមធ្យមសិក្សាទូទៅ) | កំណត់ហេតុរដ្ឋបាល |
| ផ្លូវច្បាប់ និងបរិយាកាសដទៃទៀតមានសុវត្ថិភាព | ៣.៦ ចំនួនកន្លែងថែទាំកុមារដែលគោរពតាមបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារ<br>ក) ភាគរយនៃកន្លែងថែទាំកុមារត្រូវបានធ្វើអធិការកិច្ច ដោយអនុលោមទៅតាមបទដ្ឋានអប្បបរមាដែលកំណត់ដោយក្រសួង ស.អ.យ<br>ខ) ភាគរយនៃកន្លែងថែទាំតាមគ្រួសារ (គ្រួសារសាច់ញាតិជាផ្លូវការ និងគ្រួសារធម៌) ត្រូវបានធ្វើអធិការកិច្ច ដោយអនុលោមទៅតាមបទដ្ឋានអប្បបរមាដែលកំណត់ដោយក្រសួង ស.អ.យ | MoSVY<br>(នាយកដ្ឋានសុខុមាលភាពកុមារ) | តារាងអធិការកិច្ច<br>(Inspection dashboard)<br>កំណត់ហេតុរដ្ឋបាល |
| កិច្ចការពារពីសាលារៀន | ៣.៧ ចំនួននាយកសាលា និងគ្រូបង្រៀនបានទទួលការអភិវឌ្ឍសមត្ថភាព ស្តីពីការអប់រំវិន័យបែបវិជ្ជមាន និងការគ្រប់គ្រងថ្នាក់រៀនមានប្រសិទ្ធភាព | MoEYS<br>(នាយកដ្ឋានអប់រំបឋម សិក្សា)<br>UNICEF | ការអង្កេតជាក់លាក់និងរបាយការណ៍ |
| | ៣.៨ ចំនួនសាលារៀនទទួលបានការផ្សព្វផ្សាយ ដើម្បីអនុវត្តការណែនាំប្រតិបត្តិ ស្តីពីកិច្ចការពារកុមារ នៅក្នុងសាលារៀន | MoEYS<br>(នាយកដ្ឋានអប់រំបឋម សិក្សា)<br>UNICEF All DP | ការអង្កេតជាក់លាក់និងរបាយការណ៍ |

| ទិដ្ឋភាព | សូចនាករ | ស្ថាប័នដឹកនាំ | ប្រភពទិន្នន័យ |
|---|---|---|---|
| **វិស័យទី៤៖ សេវាឆ្លើយតប និង សេវាគាំទ្រចំពោះកិច្ចការពារកុមារ (រាប់បញ្ចូលសម្រាប់រាយការណ៍អំពីអំពើហិង្សា និងយុត្តិធម៌)** គោលបំណង៖ ដើម្បីផ្តល់លទ្ធភាពក្នុងការរាយការណ៍/ជូនដំណឹង ផ្តល់សេវាបញ្ជូននៅពេលបញ្ហាកង្វល់ទាក់ទងនឹងកិច្ចការពារកុមារត្រូវបានកំណត់រកឃើញ និងផ្តល់សេវាកិច្ចការពារកុមារជូនកុមាររងគ្រោះ និងគ្រួសាររបស់ពួកគេដែលមានទំនាក់ទំនងជាមួយប្រព័ន្ធកិច្ចការពារកុមារ (យុទ្ធសាស្ត្រ INSPIRE ទី៦៖ សេវាឆ្លើយតប និងសេវាគាំទ្រ; គោលបំណង៖ ដើម្បីកែលម្អលទ្ធភាពក្នុងការទទួលបានសេវាសុខាភិបាល សុខុមាលភាពសង្គម និងកិច្ចគាំទ្រផ្នែកយុត្តិធម៌ព្រហ្មទណ្ឌដែលមានគុណភាពល្អ សម្រាប់កុមារគ្រប់រូបដែលត្រូវការសេវាទាំងនេះ រួមទាំងការរាយការណ៍អំពីអំពើហិង្សា ដើម្បីកាត់បន្ថយផលប៉ះពាល់រយៈពេលវែងនៃអំពើហិង្សា។ | | | |
| ការស្វែងរកជំនួយសម្រាប់អំពើហិង្សាក្នុងវ័យកុមារ | ៤.១ ភាគរយនៃកុមារអាយុចន្លោះពី ១៣-១៧ឆ្នាំ ដែលបានស្វែងរកជំនួយពីស្ថាប័ន ឬ ពីអ្នកវិជ្ជាជីវៈ សម្រាប់ការទទួលរងអំពើហិង្សាផ្លូវកាយ ឬផ្លូវភេទ (ឥរិយាបថស្វែងរកជំនួយក្នុងវ័យកុមារ) (ទិន្នន័យមានក្នុងCDHS: ភាគរយនៃស្ត្រីអាយុចន្លោះពី ១៥-៤៩ឆ្នាំ ដែលធ្លាប់ទទួលរងអំពើហិង្សាផ្លូវកាយ ឬផ្លូវភេទ ទៅតាមឥរិយាបថស្វែងរកជំនួយ បែងចែកតាមប្រភេទអំពើហិង្សា និងសាវតា) | MoP/NIS | CDHS |
| សេវាសម្រាប់កុមារគ្រប់រូបដែលមានទំនាក់ទំនងជាមួយប្រព័ន្ធកិច្ចការពារកុមារ | ៤.២ ភាគរយនៃកុមារី និងកុមារាអាយុក្រោម១៨ឆ្នាំ ដែលមានទំនាក់ទំនងជាមួយប្រព័ន្ធយុត្តិធម៌ និងអាជ្ញាធររដ្ឋបាលក្នុងឆ្នាំកន្លងទៅ ដែលបានទទួល ក)កិច្ចគាំទ្រឯកទេស ខ) កិច្ចគាំទ្រពី ការបង្វែរការជាប់ឃុំ ឬស្តារឡើងវិញ ជំនួសឱ្យការឃុំខ្លួន | MoJ (នាយកដ្ឋានកិច្ចការរដ្ឋបាលនៃសាលាជម្រះក្តី) | កំណត់ហេតុរដ្ឋបាលប្រព័ន្ធទិន្នន័យតុលាការ |
| | ៤.៣ ចំនួនជនល្មើសដែលត្រូវបានចាប់ខ្លួន និងបញ្ជូនទៅតុលាការពីបទល្មើសលើកុមារ | MoI-អគ្គស្នងការ នគរបាលជាតិ/នាយកដ្ឋានប្រឆាំង ការជួញដូរមនុស្សនិងការពារអនីតិជន | ទិន្នន័យរបស់អគ្គស្នងការនគរបាលជាតិ និងប្រព័ន្ធគ្រប់គ្រងទិន្នន័យនៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារ អនីតិជន |

| | | | |
|---|---|---|---|
| | ៤.៤ ចំនួនបុគ្គលដែលត្រូវបានកាត់ទោសពីបទល្មើសលើកុមារ | MoJ<br>(នាយកដ្ឋានកិច្ចការរដ្ឋបាលនៃសាលាជម្រះក្តី) | កំណត់ហេតុរដ្ឋបាល |
| | ៤.៥ ចំនួនកុមារកំពុងរស់នៅកន្លែងថែទាំកុមារ | MoSVY<br>(នាយកដ្ឋានសុខុមាលភាពកុមារ) | ប្រព័ន្ធអធិការកិច្ចកន្លែងថែទាំជំនួស |
| | ៤.៦ ចំនួនកុមារស្ថិតក្រោមការថែទាំតាមគ្រួសារក្នុងប្រទេស (គ្រួសារសាច់ញាតិជាផ្លូវការ និងគ្រួសារធម៌) | MoSVY<br>(នាយកដ្ឋានសុខុមាលភាពកុមារ ) | កំណត់ហេតុរដ្ឋបាល |
| | ៤.៧ ភាគរយនៃកុមារស្ថិតក្រោមការថែទាំពីគ្រួសារសាច់ញាតិជាផ្លូវការ និងក្រៅផ្លូវការ ឬគ្រួសារធម៌ ដែលរកឃើញតាមការអង្កេត | MoP/NIS | CDHS |
| | ៤.៨ ចំនួនកុមារដែលបានបង្រួបបង្រួមគ្រួសារ ឬ ទុកដាក់ជាមួយគ្រួសារសាច់ញាតិ គ្រួសារធម៌ ឬសហគមន៍ | MoSVY<br>(នាយកដ្ឋានសុខុមាលភាពកុមារ) | Primero<br>OSCaR |
| | ៤.៩ ចំនួនកុមារដែលត្រូវបានស្វែងរកគ្រួសារល្អសម្រាប់សុំកូនក្នុងប្រទេស | MoSVY<br>(នាយកដ្ឋានសុខុមាលភាពកុមារ) | កំណត់ហេតុរដ្ឋបាល |
| | ៤.១០ ចំនួនកុមារដែលត្រូវបានស្វែងរកគ្រួសារល្អសម្រាប់សុំកូនអន្តរប្រទេស | MoSVY<br>(រដ្ឋបាលសុំកូនអន្តរប្រទេស) | កំណត់ហេតុរដ្ឋបាល |

| | | | |
|---|---|---|---|
| | ៤.១១ ចំនួនកុមារដែលមានទំនាក់ទំនងជាមួយប្រព័ន្ធកិច្ចការពារកុមារបានទទួលសេវា កិច្ចការពារកុមារ និង/ឬសេវាសង្គម<br>៤.១១.ក ចំនួនកុមារទទួលបានសេវាគ្រប់គ្រងករណីនៅក្នុងកំណត់ត្រាប្រព័ន្ធ Primero<br>៤.១១.ខ  ចំនួនកុមារអនាថាទទួលបានសេវាគាំពារ (ប្រឹក្សា និងសមាហរណកម្ម)<br>៤.១១.គ ចំនួនអនីតិជនទំនាស់នឹងច្បាប់ទទួលបានសេវា (ស្តារនីតិសម្បទា សមាហរណកម្ម បង្វែរទៅសហគមន៍)<br>៤.១១.ឃ  ចំនួនកុមាររងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ទទួលបានសេវា (សេវាគាំពារ ស្តារនីតិសម្បទា សមាហរណកម្មទៅសហគមន៍)<br>៤.១១.ង ចំនួនកុមារទទួលបានសេវាយុត្តិធម៌<br>៤.១១.ច  ចំនួនកុមាររស់រានមានជីវិតពីគ្រោះថ្នាក់ដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម ទទួលសេវាគាំទ្រ (សេវាថែទាំផ្នែកវេជ្ជសាស្ត្រ ផ្លូវចិត្ត និងស្តារលទ្ធភាពពលកម្មកាយសម្បទា)<br>៤.១១.ឆ ចំនួនកុមាររងគ្រោះដោយអំពើហិង្សាទទួលបានសេវាព្យាបាល<br>៤.១១.ជ ចំនួនកុមារទទួលបានសេវាសង្គមពីបណ្តាញអង្គការ 3PC<br>៤.១១.ឈ ចំនួនកុមារទទួលបានសេវាតាមរយៈបណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា<br>៤.១១.ញ ចំនួនកុមារពិការទទួលបានសេវាស្តារ | MoSVY-នាយកដ្ឋានបច្ចេកទេសទាំងអស់<br>, MoI, MoJ, NGOs, Save the Children/FCF, React, MoH, MoCR, MoEYS,  CMAA<br>មូលនិធិជនពិការ | Primero<br>កំណត់ហេតុរដ្ឋបាល |

| ទិដ្ឋភាព | សូចនាករ | ស្ថាប័នដឹកនាំ | ប្រភពទិន្នន័យ |
|---|---|---|---|
| **វិស័យទី៥៖ កម្រិតវិសាលភាពនៃបញ្ហាកិច្ចការពារកុមារ និងកត្តាហានិភ័យ (ប្រេវ៉ាឡង់នៃករណី)**<br>គោលបំណង៖ ដើម្បីវាស់ស្ទង់ទៅលើវឌ្ឍនភាពធៀបនឹងបញ្ហាកិច្ចការពារកុមារសំខាន់ៗ (ផលប៉ះពាល់/លទ្ធផលរយៈពេលវែងកម្រិតខ្ពស់ជាងមុន) | | | |
| កុមារពិការ | ៥.១.ក ភាគរយនៃកុមារពិការ<br>៥.១.ខ ចំនួនកុមារមានពិការភាពដែលបានកំណត់អត្តសញ្ញាណកម្ម ប្រភេទ និងកម្រិតពិការភាពនៅតាមមណ្ឌលរបស់រដ្ឋ និងអង្គការ | ក) MoP/NIS<br>ខ) MoSVY<br>(នាយកដ្ឋានសុខុមាលភាពជនពិការ) | ក) CDHS ការអង្កេត<br>ខ) MoSVY |
| និយាម និងគុណតម្លៃ | ៥.២. ភាគរយនៃស្ត្រី និងបុរសអាយុចន្លោះពី ១៥-៤៩ឆ្នាំ ដែលយល់ស្របថាការដែលប្ដី/ដៃគូវាយដំប្រពន្ធរបស់ខ្លួន (ដៃគូរបស់ខ្លួន) គឺជារឿងត្រឹមត្រូវ កុមារដែលរស់នៅក្នុងគ្រួសារដែលស្ថិតនៅក្រោមបន្ទាត់ភាពក្រីក្ររបស់ជាតិ | MoP/NIS | CDHS |
| ភាពក្រីក្រ | ៥.៣. កុមារដែលរស់នៅក្នុងគ្រួសារស្ថិតនៅក្រោមបន្ទាត់ភាពក្រីក្ររបស់ជាតិ | MoP/NIS/GDP | CSES/Child Poverty Profile |
| | ៥.៤. ការប៉ាន់ប្រមាណចំនួនកុមារកំពុងរស់នៅក្នុងគ្រួសារក្នុងចំណាត់ថ្នាក់ក្រីក្រកម្រិត១ និងក្រីក្រកម្រិត២ | MoP/GDP | ID Poor Database |
| ជួញដូរកុមារ | ៥.៥. ចំនួនកុមារដែលត្រូវបានជួញដូរទៅក្នុងទម្រង់ផ្សេងៗគ្នា (សូចនាករ SDG ១៦.២.២ ចំនួនជនរងគ្រោះដោយសារការជួញដូរមនុស្ស ក្នុងប្រជាជន ១០០.០០០នាក់ បែងចែកតាមភេទ និងអាយុ និងទម្រង់នៃការកេងប្រវ័ញ្ច) | MoI/នាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន | កំណត់ហេតុរដ្ឋបាល |
| កុមារដែលគ្មានការថែទាំពីឪពុក ម្ដាយ | ៥.៦. ភាគរយនៃកុមារអាយុក្រោម១៨ឆ្នាំ ដែលមិនរស់នៅជាមួយឪពុកម្ដាយបង្កើតរបស់ពួកគេ បើទោះបីយ៉ាងហោចណាស់មានឪពុក ឬម្ដាយម្នាក់ដែលនៅរស់ក៏ដោយ | MoP/NIS | CDHS |

| | | | |
|---|---|---|---|
| | ៥.៧. ចំនួនកុមារកំពុងរស់នៅ ឬ ធ្វើការតាមចិញ្ចើមថ្នល់ | MoSVY (នាយកដ្ឋានសុខុមាលភាពសង្គម), Friends International | ការអង្កេតជាក់លាក់ |
| អំពើហិង្សាផ្លូវកាយ និងឬផ្លូវចិត្ត | ៥.៨. ភាគរយនៃកុមារដែលទទួលរងអំពើហិង្សាផ្លូវកាយ និង ឬ ផ្លូវចិត្ត ពីសំណាក់អ្នកថែទាំក្នុងរយៈពេល១ខែចុងក្រោយ<br>(សូចនាករ SDG ១៦.២.១: ភាគរយនៃកុមារអាយុ១-១៧ឆ្នាំដែលទទួលរងអំពើហិង្សាផ្លូវកាយ និងឬ ផ្លូវចិត្ត ពីសំណាក់អ្នកថែទាំក្នុងរយៈពេល១ខែចុងក្រោយ<br>ទិន្នន័យមានក្នុងCDHS: ភាគរយនៃស្ត្រីអាយុចន្លោះពី ១៥-៤៩ឆ្នាំ ដែលធ្លាប់ទទួលរងអំពើហិង្សាផ្លូវកាយ ចាប់ពីអាយុ១៥ឆ្នាំ និងភាគរយនៃស្ត្រីអាយុចន្លោះពី ១៥-៤៩ឆ្នាំ ដែលធ្លាប់ទទួលរងអំពើហិង្សាផ្លូវកាយក្នុងរយៈពេល១២ខែចុងក្រោយ) | MoP/NIS | CDHS |
| | ៥.៩. ករណីទណ្ឌកម្មលើរាងកាយ ដែលប្រព្រឹត្តដោយគ្រូបង្រៀនក្នុងរយៈពេល១ឆ្នាំកន្លងមក | MoP/NIS | CDHS |
| អំពើហិង្សាផ្លូវភេទលើកុមារ | ៥.១០. ភាគរយនៃស្ត្រី និងកុមារីអាយុចាប់ពី១៥ឆ្នាំឡើងទៅ ដែលធ្លាប់មានដៃគូបានទទួលរងអំពើហិង្សាផ្លូវភេទ ពីសំណាក់មនុស្សផ្សេងទៀតដែលមិនមែនជាដៃគូស្និទ្ធស្នាល ក្នុងរយៈពេល១២ខែចុងក្រោយ បែងចែកតាមអាយុ និងកន្លែងដែលអំពើហិង្សាកើតមានឡើង<br>(សូចនាករ SDG ៥.២.២ ; ទិន្នន័យមានក្នុងCDHS កុមារី និងស្ត្រីអាយុ១៥-៤៩ឆ្នាំ) | MoP/NIS | CDHS |

| | | | |
|---|---|---|---|
| | ៥.១១. ភាគរយនៃស្ត្រី អាយុ១៨ ទៅ ២៩ឆ្នាំដែលទទួលរងអំពើហិង្សាផ្លូវភេទត្រឹមអាយុ១៨ឆ្នាំ<br>(សូចនាករ SDG ១៦.២.៣ ភាគរយនៃស្ត្រី និងបុរសវ័យក្មេងអាយុ១៨ទៅ២៩ឆ្នាំដែលទទួលរងអំពើហិង្សាផ្លូវភេទត្រឹមអាយុ១៨ឆ្នាំ; ទិន្នន័យមានក្នុងCDHS ស្ត្រីអាយុ១៨-២៩ឆ្នាំ) | MoP/NIS | CDHS |
| អំពើហិង្សាដែលប្រព្រឹត្តដោយដៃគូស្និទ្ធស្នាល - អំពើហិង្សាផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទ | ៥.១២. ភាគរយនៃស្ត្រី និងកុមារីអាយុចាប់ពី១៥ឆ្នាំឡើងទៅ ដែលធ្លាប់មានដៃគូ បានទទួលរងអំពើហិង្សាផ្លូវកាយ និង/ឬ ផ្លូវភេទ ពីសំណាក់ដៃគូបច្ចុប្បន្ន ឬ ដៃគូអតីត ក្នុងរយៈពេល១២ខែចុងក្រោយ<br>(សូចនាករ SDG ៥.២.១ ; ទិន្នន័យមានក្នុងCDHS ស្ត្រី និងកុមារីអាយុ១៥-៤៩ឆ្នាំដែលរៀបការហើយ ធ្លាប់ទទួលរងអំពើហិង្សាផ្លូវកាយ ផ្លូវភេទ និងផ្លូវចិត្ត កន្លងមក និងក្នុងរយៈពេល១២ខែចុងក្រោយ) | MoP/NIS | CDHS |
| អាពាហ៍ពិពាហ៍ក្នុងវ័យកុមារ | ៥.១៣. ភាគរយនៃស្ត្រីដែលបានរៀបអាពាហ៍ពិពាហ៍ក្នុងវ័យកុមារ<br>ក) ភាគរយនៃស្ត្រីអាយុចន្លោះពី២០-២៥ឆ្នាំ ដែលបានរៀបការដំបូង ឬរួមរស់ជាមួយដៃគូ មុនអាយុ ១៨ឆ្នាំ និង<br>ខ) ភាគរយនៃស្ត្រីអាយុចន្លោះពី២០-២៥ឆ្នាំ ដែលបានរៀបការដំបូង ឬរួមរស់ជាមួយដៃគូ មុនអាយុ ១៥ឆ្នាំ | MoP/NIS | CDHS/ជំរឿនប្រជាជន |
| ពលកម្មកុមារ | ៥.១៤. ភាគរយនៃកុមារអាយុចន្លោះពី ៥-១៧ឆ្នាំ ដែលកំពុងធ្វើពលកម្មកុមារ រាប់បញ្ចូលពលកម្មក្នុងទម្រង់គ្រោះថ្នាក់ផងដែរ (សូចនាករ SDG ៨.៧.១) | MoP/NIS<br>MoLVT | CSES,<br>កំណត់ហេតុរដ្ឋបាល |
| កុមារទំនាស់នឹងច្បាប់ | ៥.១៥. ចំនួនកុមារកំពុងជាប់ឃុំក្នុងពន្ធនាគារ ក្នុងចំណោមកុមារ ១០០.០០០នាក់ រាប់បញ្ចូលទាំងកុមារជាប់ឃុំបណ្តោះអាសន្នផងដែរ | MoI/អគ្គនាយកដ្ឋានពន្ធនាគារ | ប្រព័ន្ធទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធនាគារ |

| | | | |
|---|---|---|---|
| | ៥.១៦. ចំនួនកូននៅជាមួយឪពុកម្ដាយក្នុងពន្ធនាគារ | MoI/អគ្គនាយកដ្ឋានពន្ធនាគារ | ប្រព័ន្ធទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធនាគារ |
| រងរបួស និង មរណភាព | ៥.១៧. ចំនួនកុមារដែលរងរបួស ពិការ ឬ ស្លាប់ដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម( ERW ) | អាជ្ញាធរមីន ( CMAA ) | ទិន្នន័យអាជ្ញាធរមីន ( CMVIS ) |
| | ៥.១៨. ចំនួនកុមាររងគ្រោះដោយមនុស្សឃាតដោយចេតនា ក្នុងចំណោមកុមារ ១០០.០០០នាក់ (អត្រាមនុស្សឃាត ) ( ទាក់ទងនឹងសូចនាករ SDG ១៦.១.១ ចំនួនជនរងគ្រោះដោយសារការធ្វើឃាតដោយចេតនា ក្នុងចំណោមប្រជាជន ១០០.០០០នាក់ បែងចែកតាម ភេទ និងអាយុ; មានទិន្នន័យកុមារ និងក្មេងជំទង់០-១៩ ឆ្នាំ ក្នុងរបាយការណ៍WHO,២០១៦/CP Profile ) | MoI/ នាយកដ្ឋានព្រហ្មទណ្ឌ | ប្រព័ន្ធទិន្នន័យអគ្គស្នង ការនគរបាលជាតិ នាយកដ្ឋានព្រហ្មទណ្ឌ |
| ការប្រព្រឹត្តផ្នែកសុខភាពផ្លូវភេទ និងសុខភាពបន្តពូជរបស់ក្មេងជំទង់ | ៥.១៩. ភាគរយនៃស្ត្រីនិងកុមារីដែលមានកូនក្នុងវ័យកុមារ<br>ក ) ភាគរយនៃស្ត្រីនិងកុមារីអាយុចន្លោះ១៥-១៩ឆ្នាំដែលបានសំរាលកូន<br>ខ ) ភាគរយនៃស្ត្រីអាយុចន្លោះ២០-២៤ឆ្នាំដែលបានសំរាលកូនមុនអាយុ ១៨ឆ្នាំ | MoP/NIS | CDHS |

# វិស័យទី១៖ ច្បាប់ គោលនយោបាយ និងផែនការ

| ឈ្មោះសូចនាករ | ១.១ ច្បាប់ស្តីពីកិច្ចការពារកុមារត្រូវបានបង្កើត |
|---|---|
| និយមន័យ | ច្បាប់ស្តីពីកិច្ចការពារកុមារសំដៅទៅច្បាប់ដែលឆ្លើយតបទៅនឹងគ្រប់ទម្រង់នៃបញ្ហាកិច្ចការពារកុមារ។ |
| លទ្ធផលរំពឹងទុក (លទ្ធផលរយៈពេលខ្លី) | ក្របខ័ណ្ឌច្បាប់ត្រូវបានឆ្លើយតបទៅនឹងបញ្ហាកង្វល់នានាទាក់ទងនឹងកិច្ចការពារកុមារ |
| វិធីសាស្ត្រគណនា | ពិនិត្យទៅលើឯកសារច្បាប់ដើម្បីវាយតម្លៃថាតើប្រទេសមាន ឬ គ្មានច្បាប់ស្តីពីកិច្ចការពារកុមារដែលបញ្ចូលរាល់ទិដ្ឋភាពផ្នែកច្បាប់សំខាន់ៗដើម្បីការពារកុមារនិងធ្វើការបែងចែកដូចខាងក្រោម<br>• មានច្បាប់<br>• ក្នុងដំណើរការបង្កើត<br>• មិនទាន់មានគម្រោងបង្កើត<br>ពិនិត្យមើលគុណភាពរបស់ច្បាប់ស្តីពីកិច្ចការពារកុមារ នៅពេលដែលច្បាប់បានបង្កើតហើយ |
| ប្រភពទិន្នន័យ | ច្បាប់ស្តីពីកិច្ចការពារកុមារ និងរបាយការណ៍ |
| កម្រិតភាពញឹកញាប់ | ៥ឆ្នាំ |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ទៅតាមដំណើរការនៃការបង្កើតច្បាប់ |
| ទីភ្នាក់ងារផ្តល់របាយការណ៍ | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (CNCC)<br>MoSVY |
| ឯកសារយោង | សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារកុមារ |
| កំណត់សម្គាល់ | |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | |

| ឈ្មោះសូចនាករ | ១.២ ច្បាប់នានាដែលការពារកុមារពីការទទួលរងទណ្ឌកម្មលើរាងកាយ និងទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារត្រូវបានពិនិត្យ និងធ្វើវិសោធនកម្មដើម្បីហាមឃាត់ការប្រើទណ្ឌកម្មលើរាងកាយ កុមារនៅក្នុងគ្រប់បរិបទទាំងអស់ សម្រាប់គោលបំណងណាមួយ រួមទាំងឪពុក ម្ដាយ និងអាណាព្យាបាល ដោយអនុលោមតាមបទដ្ឋានអន្តរជាតិ |
|---|---|
| និយមន័យ | ច្បាប់ត្រូវហាមឃាត់ការដាក់ទណ្ឌកម្មលើរាងកាយកុមារនៅក្នុងគ្រប់បរិបទទាំងអស់ រួមទាំងការដាក់ពិន័យទៅលើការប្រើអំពើហិង្សា ឬទណ្ឌកម្មលើរាងកាយកុមារនៅតាមសាលារៀន និងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ចាត់ទុកថាអំពើហិង្សាលើកុមារនៅក្នុងគ្រួសារគឺជាការខុសច្បាប់ (មាត្រា៨ បានចែងថា ការប្រើប្រាស់អំពើហិង្សាក្នុងគ្រួសារសម្រាប់ស្តីប្រដៅកូនក្នុងគោលបំណងអប់រំមិនចាត់ទុកថាអំពើហិង្សា)<br><br>ចំណុចខាងក្រោមនេះត្រូវបានផែនការសកម្មភាពស្តីពីការទប់ស្កាត់ និងឆ្លើយតបអំពើហិង្សាលើកុមារកំណត់រកឃើញពិនិត្យ និងធ្វើវិសោធនកម្ម មាត្រា ១០៤៥ (ឪពុកម្តាយ) និងមាត្រា ១០៧៩(អាណាព្យាបាល) នៃក្រមរដ្ឋប្បវេណី ដើម្បីកំណត់ថា ទណ្ឌកម្មលើរាងកាយកុមារ គឺជាការខុសច្បាប់ (មាត្រាទាំងនេះបានចែងថារាល់ការដាក់ទណ្ឌកម្មដោយឪពុកម្តាយត្រូវបានអនុញ្ញាតតាមតែអាចធ្វើបាន)<br><br>ទណ្ឌកម្មលើរាងកាយកុមារនៅតាមសាលារៀនត្រូវបានហាមឃាត់ ប៉ុន្តែមិនមានការដាក់ពិន័យដល់គ្រូដែលប្រព្រឹត្តអំពើនេះ។ ច្បាប់ស្តីពីការអប់រំ (មាត្រា ៣៥) ផ្តល់សិទ្ធិដល់សិស្ស ក្នុងថ្នាក់ សិទ្ធិទទួលបានការគោរព និងថែទាំជាពិសេសទាក់ទងនឹងសិទ្ធិមនុស្ស សេចក្តីថ្លៃថ្នូ សិទ្ធិមិនទទួលរងទណ្ឌកម្មលើរាងកាយ និងផ្លូវចិត្ត ឬទទួលរងទារុណកម្ម។ |
| លទ្ធផលរំពឹងទុក (លទ្ធផល រយៈពេលខ្លី) | កិច្ចការពារពីទណ្ឌកម្មលើរាងកាយ និងអំពើហិង្សាក្នុងគ្រួសារ |
| វិធីសាស្ត្រគណនា | ការពិនិត្យឡើងវិញទៅលើក្រមរដ្ឋប្បវេណី។ ច្បាប់ស្តីពីការអប់រំ និងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ |
| ប្រភពទិន្នន័យ | ក្រមរដ្ឋប្បវេណី ច្បាប់ស្តីពីអប់រំ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ និងរបាយការណ៍ពី ក្រសួងយុត្តិធម៌ ក្រសួងកិច្ចការនារី និងក្រសួងអប់រំ យុវជន និងកីឡា |
| កម្រិតភាពញឹកញាប់ | ជារៀងរាល់ឆ្នាំ |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ទៅតាមជំហាននៃការបង្កើតច្បាប់ |

| | |
|---|---|
| ទីភ្នាក់ងារផ្តល់របាយការណ៍ | MoJ-ក្រមរដ្ឋប្បវេណី (នាយកដ្ឋានកិច្ចការរដ្ឋបាលនៃសាលាជម្រះក្តី)<br>MoWA-ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ (នាយកដ្ឋានការពារផ្លូវច្បាប់)<br>MoEYS-បរិបទអប់រំ (នាយកដ្ឋានគោលនយោបាយ) |
| ឯកសារយោង | ផែនការសកម្មភាពស្តីពីអំពើហិង្សាលើកុមារ វិស័យយុទ្ធសាស្ត្រទី៤៖ ការបង្កើតច្បាប់ និងគោលនយោបាយ សូចនាករលទ្ធផល Inspire |
| កំណត់សម្គាល់ | ការតម្រូវឱ្យធ្វើវិសោធនកម្មលើច្បាប់ទាំងអស់នេះក៏មានចែងក្នុងរបាយការណ៍របស់គណៈកម្មាធិការអនុសញ្ញាសិទ្ធិកុមារ ដូច្នេះក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ គួរចូលរួមក្នុងការងារនេះ។ |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | |

| ឈ្មោះសូចនាករ | ១.៣ បទដ្ឋាននីតិវិធីប្រតិបត្តិការសម្រាប់ការឆ្លើយតបចំពោះសេវាកិច្ចការពារកុមារត្រូវបានរៀបចំ |
|---|---|
| និយមន័យ | បទដ្ឋានស្តីពីនីតិវិធីប្រតិបត្តិការសំដៅលើពិធីសារផ្លូវការ ដើម្បីកំណត់ពីតួនាទីផ្លូវច្បាប់ និងភារៈកិច្ចច្បាស់លាស់សម្រាប់ស្ថាប័នមានភារកិច្ច និងអ្នកផ្តល់សេវាអនុវត្តនៅពេលមានស្ថានភាពកិច្ចការពារកុមារកើតឡើង រួមមានយន្តការផ្តល់ដំណឹង ដំណើរការបញ្ជូន និងឆ្លើយតប។ |
| លទ្ធផលរំពឹងទុក (លទ្ធផលរយៈពេលខ្លី) | ច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធកិច្ចការពារកុមារត្រូវបានពិនិត្យឡើងវិញ និងពង្រឹងការអនុវត្តយ៉ាងមានប្រសិទ្ធភាព |
| វិធីសាស្រ្តគណនា | ការពិនិត្យឡើងវិញទៅលើក្រមច្បាប់ គោលនយោបាយ គោលការណ៍ណែនាំជាតិ ពិធីសារ ឬ SOPs។ គោលការណ៍ណែនាំខាងក្រោមរបស់អង្គការសហប្រជាជាតិ អាចត្រូវបានយកមកប្រើប្រាស់៖<br>• គោលការណ៍ណែនាំទាំងនេះដោះស្រាយបញ្ហាបញ្ជូនករណីរវាងវិស័យផ្សេងៗគ្នា ពោលគឺរវាងសេវាសង្គម និងសុខាភិបាល , សេវាសង្គម និងយុត្តិធម៌ និងសុខាភិបាល និងយុត្តិធម៌។<br>• ដំណើរការបញ្ជូនមានលក្ខណៈបទដ្ឋានរវាងវិស័យទាំងបី ៖ ការងារសង្គម សុខាភិបាល និងយុត្តិធម៌ (ទោះបីជាមានការចែងលំអិតពីដំណើរការនៅក្នុង SOPs/ ឯកសារដោយឡែកក៏ដោយ)។<br>• គោលការណ៍ណែនាំទាំងនេះត្រូវបានវិស័យនីមួយៗអនុម័តជាផ្លូវការ។<br>• ការបញ្ជូនត្រូវបានធ្វើឡើងដោយយោងទៅតាមគោលការណ៍ណែនាំទាំងនេះ។ |
| ប្រភពទិន្នន័យ | ច្បាប់ គោលការណ៍ជាតិ និងបទដ្ឋាននីតិវិធីប្រតិបត្តិការ (SOPs) |
| កម្រិតភាពញឹកញាប់ | រៀងរាល់ឆ្នាំ |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ទៅតាមចំនួន និងប្រភេទនៃលក្ខណៈវិនិច្ឆ័យ (ដូចមានរៀបរាប់ខាងលើ) ថាច្បាប់មានលក្ខខណ្ឌស្រប ឬ មិនស្របទៅនឹងលក្ខណៈវិនិច្ឆ័យ (ក្នុងករណីសមស្រប) ទៅតាមខេត្ត ឬ រដ្ឋ ប្រសិនបើច្បាប់មានលក្ខណៈខុសគ្នានៅកម្រិតថ្នាក់ក្រោមជាតិ។ |
| ទីភ្នាក់ងារផ្តល់របាយការណ៍ | MoSVY- Child Welfare Development |

| | |
|---|---|
| ឯកសារយោង | ផែនការសកម្មភាពស្តីពីអំពើហិង្សាលើកុមារ និង សូចនាករ INSPIRE ៣.៤ ច្បាប់ និងគោលនយោបាយទាក់ទងនឹងការឆ្លើយតបរបស់ស្ថាប័ន និងអ្នកមានភារកិច្ច ចំពោះអំពើហិង្សាលើកុមារ។ សេចក្តីណែនាំសម្រាប់សូចនាករ INSPIRE ( ៨.១២ សម្រាប់គោលការណ៍ណែនាំវិស័យសុខាភិបាល ស្តីពីអំពើហិង្សាផ្លូវភេទ និងសូចនាករ ៨.១១ ស្តីពីការធ្វើបាបកុមារ ) |
| កំណត់សម្គាល់ | យន្តការបញ្ជូនគប្បីកំណត់បែងចែកឱ្យបានច្បាស់រវាងទីភ្នាក់ងារផ្សេងៗគ្នា ជាពិសេសគឺរវាងវិស័យសុខុមាលភាពកុមារ/កិច្ចការពារកុមារ សុខាភិបាល និងយុត្តិធម៌។<br>Inspire ផ្តល់អនុសាសន៍ចំណុចជាក់លាក់ខាងក្រោមចំពោះបញ្ហាអំពើហិង្សា៖<br>បទដ្ឋាន នីតិវិធី និងពិធីសារជាតិ ដើម្បីផ្តល់មគ្គុទ្ទេសក៍ណែនាំដល់អ្នកប្រកបវិជ្ជាជីវៈ និងអ្នកមានភារៈកិច្ចនៅក្នុងវិស័យនីមួយៗ អំពីរបៀបឆ្លើយតបដោយប្រុងប្រយ័ត្នចំពោះកុមាររងគ្រោះនៃអំពើហិង្សា។ |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | ព័ត៌មានមួយចំនួនសម្រាប់សូចនាករនេះ អាចរកបាននៅក្នុងរបាយការណ៍ខួបរបស់រដ្ឋភាគីសម្រាប់ដាក់ជូនទៅគណៈកម្មាធិការស្តីពីសិទ្ធិកុមារ<br>( www.ohchr.org/EN/HRBodies/CRC/Pages/CRCIntro.aspx ). |

| ឈ្មោះសូចនាករ | ១.៤ ប្រព័ន្ធធានាគុណភាពសម្រាប់ការងារសេវាសង្គមត្រូវបានដំណើរការ |
|---|---|
| និយមន័យ | សំដៅដល់ប្រព័ន្ធមួយដែលបានបំពេញលក្ខណៈវិនិច្ឆ័យទាំង៤ខាងក្រោម៖<br>លក្ខណៈវិនិច្ឆ័យទី១៖ ការមានក្របខ័ណ្ឌលិខិតបទដ្ឋានគតិយុត្តិមួយ ដែលគូសវាស/កំណត់មុខងារ (តួនាទី និងការទទួលខុសត្រូវ) សម្រាប់បុគ្គលសេវាសង្គម និងនីតិវិធីការងារនៅកម្រិតថ្នាក់ជាតិ និង/ឬ ថ្នាក់ក្រោមជាតិ។<br>លក្ខណៈវិនិច្ឆ័យទី២៖ ការមានប្រព័ន្ធត្រួតពិនិត្យ និងគាំទ្រផ្លូវការមួយ សម្រាប់កម្លាំងការងារសេវាសង្គម។<br>លក្ខណៈវិនិច្ឆ័យទី៣៖ ការមានប្រព័ន្ធមួយសម្រាប់ផ្ដល់អាជ្ញាប័ណ្ណ ឬ ការទទួលស្គាល់ការងារសង្គមកិច្ច។<br>លក្ខណៈវិនិច្ឆ័យទី៤៖ ការមានប្រព័ន្ធទិន្នន័យទូទាំងប្រទេសសម្រាប់ប្រព័ន្ធព័ត៌មានធនធានមនុស្ស (HRI) នៃកម្លាំងការងារសេវាសង្គម។ |
| លទ្ធផលរំពឹងទុក (លទ្ធផលរយៈពេលខ្លី) | បណ្ដាប្រទេសនានាបានពង្រឹងក្របខ័ណ្ឌលិខិតបទដ្ឋានគតិយុត្តិ និងក្របខ័ណ្ឌប្រតិបត្តិការលើកម្លាំងការងារសេវាសង្គម។ |
| វិធីសាស្ត្រគណនា | ការពិនិត្យឡើងវិញសម្រាប់លក្ខណៈវិនិច្ឆ័យនីមួយៗ ចន្លោះពីពិន្ទុ ១-៤ ដោយពិន្ទុ ៤ សំដៅចំពោះការមានទាំងស្រុង និងពិន្ទុ ១ សំដៅចំពោះការដែលមិនទាន់បានចាប់ផ្ដើមការងារអ្វីទាំងអស់នៅក្នុងវិស័យការងារជាក់លាក់នេះ។ ផ្អែកលើអ្វីទាំងអស់នេះ ចូរគណនាពិន្ទុសរុប។ សូមមើលខាងក្រោម ៖ |

| | |
|---|---|
| | **លក្ខណៈវិនិច្ឆ័យទី១). ក្របខ័ណ្ឌលិខិតបទដ្ឋានគតិយុត្តិ** |
| | ពិន្ទុ៤៖ ក្របខ័ណ្ឌរួចរាល់ជាស្ថាពរ និងកំពុងប្រើប្រាស់។ |
| | ពិន្ទុ៣៖ ក្របខ័ណ្ឌកំពុងស្ថិតនៅដំណាក់កាលសេចក្តីព្រាងចុងក្រោយ។ |
| | ពិន្ទុ២៖ ក្របខ័ណ្ឌកំពុងស្ថិតនៅដំណាក់កាលសេចក្តីព្រាងបឋម។ |
| | ពិន្ទុ១៖ គ្មានក្របខ័ណ្ឌលិខិតបទដ្ឋានគតិយុត្តិ។ |
| | **លក្ខណៈវិនិច្ឆ័យទី២). ប្រព័ន្ធត្រួតពិនិត្យ និងគាំទ្រ** |
| | ពិន្ទុ៤៖ ប្រព័ន្ធរួចរាល់ជាស្ថាពរ និងកំពុងប្រើប្រាស់យ៉ាងទូលំទូលាយ។ |
| | ពិន្ទុ៣៖ ប្រព័ន្ធកំពុងស្ថិតនៅដំណាក់កាលសេចក្តីព្រាងចុងក្រោយ ឬចាប់ផ្តើមដាក់ឱ្យប្រើប្រាស់បឋម។ |
| | ពិន្ទុ២៖ ប្រព័ន្ធកំពុងស្ថិតនៅក្នុងដំណាក់កាលអភិវឌ្ឍបឋម រាប់បញ្ចូលការអនុវត្តសាកល្បង។ |
| | ពិន្ទុ១៖ មិនទាន់បានចាប់ផ្តើមការងារដើម្បីកំណត់និយមន័យប្រព័ន្ធនៅឡើយ។ |
| | **លក្ខណៈវិនិច្ឆ័យទី៣). ប្រព័ន្ធសម្រាប់ផ្តល់អាជ្ញាប័ណ្ណ/ផ្តល់ការទទួលស្គាល់ការងារសង្គមកិច្ច** |
| | ពិន្ទុ៤៖ ប្រព័ន្ធរួចរាល់ជាស្ថាពរ និងកំពុងប្រើប្រាស់ទូទាំងប្រទេស។ |
| | ពិន្ទុ៣៖ ប្រព័ន្ធកំពុងស្ថិតនៅដំណាក់កាលអភិវឌ្ឍចុងក្រោយ ឬចាប់ផ្តើមដាក់ឱ្យប្រើប្រាស់បឋម។ |
| | ពិន្ទុ២៖ ប្រព័ន្ធកំពុងស្ថិតនៅដំណាក់កាលសេចក្តីព្រាងបឋម រាប់បញ្ចូលការអនុវត្តសាកល្បង។ |
| | ពិន្ទុ១៖ គ្មានប្រព័ន្ធ។ |
| | **លក្ខណៈវិនិច្ឆ័យទី៤). ប្រព័ន្ធប្រមូលទិន្នន័យ** |
| | ពិន្ទុ៤៖ ប្រព័ន្ធកំពុងត្រូវបានប្រើប្រាស់ទូទាំងប្រទេស។ |
| | ពិន្ទុ៣៖ ប្រព័ន្ធកំពុងស្ថិតនៅដំណាក់កាលអភិវឌ្ឍចុងក្រោយ ឬចាប់ផ្តើមដាក់ឱ្យប្រើប្រាស់បឋម។ |
| | ពិន្ទុ២៖ ប្រព័ន្ធកំពុងត្រូវបានអភិវឌ្ឍ រាប់បញ្ចូលការអនុវត្តសាកល្បង។ |
| | ពិន្ទុ១៖ គ្មានប្រព័ន្ធ។ |

| | |
|---|---|
| | **បន្ទាប់ពីបានដាក់ពិន្ទុសម្រាប់លក្ខណៈវិនិច្ឆ័យទាំង៤រួចរាល់ ចូរគណនាពិន្ទុចុងក្រោយ**<br>ពិន្ទុ ១៣-១៦៖ មានការអភិវឌ្ឍល្អ<br>ពិន្ទុ ៩-១២៖ មានការអភិវឌ្ឍកម្រិតមធ្យម<br>ពិន្ទុ ៥-៨៖ មានការអភិវឌ្ឍបឋម<br>ពិន្ទុ ៤៖ គ្មានការអភិវឌ្ឍ |
| ប្រភពទិន្នន័យ | ឯកសារពាក់ព័ន្ធ |
| កម្រិតភាពញឹកញាប់ | រៀងរាល់ឆ្នាំ |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ទៅតាមកម្រិតនៃការបញ្ចប់៖ គ្មានប្រព័ន្ធ ដំណាក់កាលសេចក្តីព្រាងបឋម (រាប់បញ្ចូលការអនុវត្តសាកល្បង) ការអនុវត្តបឋម ការសម្រេចស្ថាពរ និងដាក់ឱ្យប្រើប្រាស់ទូទាំងប្រទេស |
| ទីភ្នាក់ងារផ្តល់របាយការណ៍ | MoSVY (នាយកដ្ឋានសុខុមាលភាពសង្គម) |
| ឯកសារយោង | សៀវភៅណែនាំអំពីសូចនាករកិច្ចការពារកុមាររបស់អង្គការយូនីសេហ្វ ឆ្នាំ២០១៨ |
| កំណត់សម្គាល់ | |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | |

| ឈ្មោះសូចនាករ | ១.៥ គោលនយោបាយថែទាំជំនួសចំពោះកុមារ មានសង្គតភាពទៅនឹងគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិឆ្នាំ២០០៩ សម្រាប់ការថែទាំជំនួសចំពោះកុមារ |
|---|---|
| និយមន័យ | សំដៅដល់ គោលនយោបាយថែទាំជំនួសចំពោះកុមារ ត្រូវមានភាពស្របគ្នាទៅនឹងគោលការណ៍ណែនាំ ឆ្នាំ២០០៩ របស់អង្គការសហប្រជាជាតិ សម្រាប់ការថែទាំជំនួសចំពោះកុមារ ដែលមានធាតុផ្សំខាងក្រោម៖<br>• មានកម្រងសេវាដែលបង្ការការបំបែកកុមារពីគ្រួសារ<br>• យន្តការត្រួតពិនិត្យឡើងវិញ (ដែលពិចារណាទៅលើទស្សនៈរបស់កុមារ) ដែលធានាថាកុមារត្រូវបានបំបែកពីគ្រួសាររបស់ពួកគេតែក្នុងករណីចាំបាច់ប៉ុណ្ណោះ<br>• កម្រងជម្រើសនៃការថែទាំជំនួស (ឧ. ការថែទាំតាមគ្រួសារ ការថែទាំដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងគ្រួសារ ផ្ទះស្នាក់នៅជាក្រុមតូចៗ ការថែទាំតាមមណ្ឌល ការរៀបចំរស់នៅដោយឯករាជ្យក្រោមការត្រួតពិនិត្យ។ល។) ដើម្បីឱ្យស្របទៅតាមសេចក្តីត្រូវការរបស់កុមារនីមួយៗ<br>• យន្តការត្រួតពិនិត្យឡើងវិញ ដើម្បីធានាថាសេចក្តីត្រូវការរបស់កុមារដែលកំពុងរស់នៅក្រោមការថែទាំជំនួសបន្ត ត្រូវបានផ្តល់ជូន និងស្វែងរកដំណោះស្រាយដែលកាន់តែមាននិរន្តរភាពទៅតាមភាពសមស្រប<br>• យន្តការត្រួតពិនិត្យ និងអធិការកិច្ចសម្រាប់បុគ្គល និងកន្លែងផ្តល់សេវាថែទាំជំនួស |
| លទ្ធផលរំពឹងទុក (លទ្ធផលរយៈពេលខ្លី) | បណ្តាប្រទេសនានាបានពង្រឹងការអនុវត្តច្បាប់ និងគោលនយោបាយការពារកុមារ។ ការឆ្លើយតបបែបនេះគឺជាផ្នែកមួយនៃការកែលម្អការអនុវត្តច្បាប់នានាដែលការពារកុមារពីគ្រោះថ្នាក់។ |
| វិធីសាស្រ្តគណនា | ការពិនិត្យឡើងវិញដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យប៉ាន់ប្រមាណ សម្រាប់ធាតុផ្សំដែលមានផ្តល់ជូននៅក្នុងនិយមន័យ។ |
| ប្រភពទិន្នន័យ | គោលនយោបាយពាក់ព័ន្ធ |
| កម្រិតភាពញឹកញាប់ | រៀងរាល់ឆ្នាំ |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ទៅតាមធាតុផ្សំដែលមានផ្តល់ជូននៅក្នុងនិយមន័យ |
| ទីភ្នាក់ងារផ្តល់របាយការណ៍ | MoSVY-CWD |
| ឯកសារយោង | សៀវភៅណែនាំអំពីសូចនាករកិច្ចការពារកុមាររបស់អង្គការយូនីសេហ្វ ឆ្នាំ២០១៨ |

| | |
|---|---|
| កំណត់សម្គាល់ | គោលការណ៍ណែនាំទាំងនេះត្រូវបានតាក់តែងឡើងដើម្បីផ្តល់សេចក្តីណែនាំបន្ថែមទៀតទាក់ទងនឹងនិយមន័យនៃទំនាក់ទំនងរវាងការថែទាំដោយឪពុកម្តាយ និងបរិយាកាសគ្រួសាររបស់កុមារ គោលដៅសម្រាប់ការថែទាំជំនួស និងលក្ខណៈវិនិច្ឆ័យសម្រាប់ការសម្រេចចិត្តទុកដាក់ក្រោមការថែទាំជំនួស។ គោលការណ៍ណែនាំកំណត់គោលដៅទាំងគោលនយោបាយ និងការអនុវត្ត ដោយមានទំនាក់ទំនងជាក់លាក់ទៅនឹងកិច្ចការពារ និងសុខុមាលភាពកុមារដែលបាត់បង់ការថែទាំពីឪពុកម្តាយ ឬ ដែលមានការប្រឈមបែបនេះ។ គោលការណ៍ណែនាំសម្រាប់ការថែទាំជំនួសចំពោះកុមារ បានទទួលការស្វាគមន៍ពីមហាសន្និបាតអង្គការសហប្រជាជាតិ ដែលប្រារព្ធធ្វើឡើងនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩ ទាក់ទងនឹងខួបលើកទី២០ នៃអនុសញ្ញាសហប្រជាជាតិស្តីពីសិទ្ធិកុមារ។ |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | |

| ឈ្មោះសូចនាករ | ១.៦ ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយស្តីពីពលកម្មកុមារ រួមទាំងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ អនុលោមតាមបទដ្ឋានអន្តរជាតិ |
| --- | --- |
| និយមន័យ | សូចនាករនេះតាមដាន ប្រទេសបានរៀបចំក្របខ័ណ្ឌច្បាប់ និងក្របខ័ណ្ឌគោលនយោបាយល្អ ដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យទាំង៥ ផ្អែកលើអនុសញ្ញាអង្គការ ILO លេខ ១៨២ ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ អនុសញ្ញាលេខ ១៣៨ ស្តីពីការកម្រិតអាយុអប្បបរមាសម្រាប់ការចូលធ្វើការងារ និងអនុសញ្ញាលេខ ២៩ ស្តីពីការងារដោយបង្ខំ ឬជាកាតព្វកិច្ច។ |
| | **ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ**<br>ផ្អែកលើអនុសញ្ញាអង្គការ ILO លេខ ១៨២ ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមាររួមមាន៖<br>• គ្រប់ទម្រង់នៃទាសភាព ឬ ការអនុវត្តស្រដៀងគ្នានឹងទាសភាព ដូចជាការលក់ និង ការជួញដូរកុមារ ចំណងបំណុល និង ភាពជាខ្ញុំបម្រើ និង ពលកម្មដោយបង្ខំរាប់បញ្ចូលការជ្រើសរើសកុមារដោយបង្ខំសម្រាប់ប្រើប្រាស់នៅក្នុងជម្លោះប្រដាប់អាវុធផងដែរ។<br>• ការប្រើប្រាស់ សញ្ជរកម្ម ឬ ការផ្តល់កុមារសម្រាប់ពេស្យាចារ សម្រាប់ការផលិតរូបភាពអាសអាភាស ឬ សម្រាប់ការសម្តែងអាសអាភាស [ការកេងប្រវ័ញ្ចផ្លូវភេទកុមារ]<br>• ការប្រើប្រាស់ សញ្ជរកម្ម ឬ ការផ្តល់កុមារសម្រាប់សកម្មភាពខុសច្បាប់ ជាពិសេស សម្រាប់ការផលិត និងការជួញដូរគ្រឿងញៀន ដូចមានកំណត់នៅក្នុងសន្ធិសញ្ញាអន្តរជាតិពាក់ព័ន្ធ<br>• ការងារដែលតាមរយៈចរិកលក្ខណៈ ឬ ស្ថានភាពនៃការអនុវត្តការងារទាំងនោះ ទំនងនឹងបង្កគ្រោះថ្នាក់ចំពោះសុខភាព សុវត្ថិភាព ឬ សីលធម៌របស់កុមារ [ពលកម្មកុមារ ប្រកបដោយគ្រោះថ្នាក់]<br>ទម្រង់ទាំងនេះត្រូវហាមឃាត់ ចំពោះកុមារគ្រប់រូបអាយុក្រោម១៨ឆ្នាំ។ |

| | |
|---|---|
| | **'ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ'**<br>ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយពេញលេញមួយ ដើម្បីលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារទាមទារឱ្យមាន៖<br>• ការផ្តល់សច្ចាប័ន CRC, ILO C ១៣៨, ILO C ១៨២ ដោយគ្មានឧបមុ្រង<br>• ភាពអនុលោមនៃអាយុស្របច្បាប់អប្បបរមារបស់ប្រទេស សម្រាប់ធ្វើការងារ ជាមួយនឹងបទដ្ឋានអាយុអប្បបរមា ( ILO C ១៣៨ )<br>• ការហាមឃាត់ជាក់លាក់នៅក្នុងច្បាប់ជាតិ អំពីទាសភាព និងពលកម្មដោយបង្ខំ អំពើជួញដូរកុមារ និងអំពើកេងប្រវ័ញ្ចផ្លូវភេទ<br>• ការហាមឃាត់ជាក់លាក់នៅក្នុងច្បាប់ជាតិ អំពីការងារគ្រោះថ្នាក់សម្រាប់កុមារ និងអ្នកបម្រើការងារវ័យក្មេង<br>• កម្មវិធីរដ្ឋាភិបាលដែលមានការកំណត់គោលដៅ (រាប់បញ្ចូលផែនការសកម្មភាពថ្នាក់ជាតិ/ក្រោមជាតិ ) ដើម្បីបង្ការទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។<br>មិនគប្បីមានបម្រុងចំពោះការផ្តល់សច្ចាប័នទៅលើ ILO ១៣៨ ឬ ១៨២ ឡើយ ឧទាហរណ៍ការមិនរាប់បញ្ចូលការងារកសិកម្មពីវិសាលភាពនៃអនុសញ្ញា។ |
| លទ្ធផលរំពឹងទុក ( លទ្ធផលរយៈពេលខ្លី ) | បណ្តាប្រទេសនានាបានពង្រឹងការអនុវត្តច្បាប់ និងគោលនយោបាយការពារកុមារ។ ការឆ្លើយតបបែបនេះគឺជាផ្នែកមួយនៃការកែលម្អការអនុវត្តច្បាប់ដែលការពារកុមារពីគ្រោះថ្នាក់។ |

| | |
|---|---|
| វិធីសាស្ត្រគណនា | ចូរប្រើប្រាស់លក្ខណៈវិនិច្ឆ័យខាងក្រោមសម្រាប់ធ្វើការប៉ាន់ប្រមាណៈ |

| | | | ពិន្ទុ |
|---|---|---|---|
| ប្រទេសបានផ្តល់សច្ចាប័ន CRC | បាទ/ចាស ទេ | ឆ្នាំនៃការផ្តល់សច្ចាប័ន | |
| ប្រទេសបានផ្តល់សច្ចាប័ន ILO C១៣៨ ដោយគ្មានឧបម្រុង ឧ. ការងារកសិកម្ម | បាទ/ចាស ទេ | ឆ្នាំនៃការផ្តល់សច្ចាប័ន | |
| ប្រទេសបានផ្តល់សច្ចាប័ន ILO C១៨២ ដោយគ្មានឧបម្រុង ឧ. ការងារកសិកម្ម | បាទ/ចាស ទេ | ឆ្នាំនៃការផ្តល់សច្ចាប័ន | |
| ប្រទេសបានផ្តល់សច្ចាប័ន CRC, ILO C១៣៨ និងILO C១៨២ | បាទ/ចាស ទេ | | បើឆ្លើយ បាទ/ចាសៈ ពិន្ទុ ១ |
| តើប្រទេសបានផ្តល់សច្ចាប័នអនុសញ្ញាអ្វីខ្លះទៀត ដែលទាក់ទងនឹងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ? | | | |
| តើអាយុអប្បបរមាស្របច្បាប់របស់ប្រទេសសម្រាប់ធ្វើការងារ មានលក្ខណៈស្របគ្នាទៅនឹងបទដ្ឋានអាយុអប្បបរមា ( ILO C១៣៨ ) ដែរឬទេ ? | បាទ/ចាស ទេ | ភស្តុតាង | បើឆ្លើយ បាទ/ចាសៈ ពិន្ទុ ១ |
| តើច្បាប់ជាតិមានកំណត់ហាមឃាត់ជាក់លាក់ចំពោះអំពើទាសភាព និងពលកម្មដោយបង្ខំ អំពើជួញដូរកុមារ និងអំពើធ្វើអាជីវកម្មផ្លូវភេទកុមារ ដែរឬទេ ? | បាទ/ចាស ទេ | ភស្តុតាង | បើឆ្លើយ បាទ/ចាសៈ ពិន្ទុ ១ |
| តើច្បាប់ជាតិមានកំណត់ហាមឃាត់ជាក់លាក់ចំពោះការងារគ្រោះថ្នាក់សម្រាប់កុមារ និងអ្នកបម្រើការងារវ័យក្មេង ដែរឬទេ ? | បាទ/ចាស ទេ | ភស្តុតាង | បើឆ្លើយ បាទ/ចាសៈ ពិន្ទុ ១ |
| តើប្រទេសមានកម្មវិធីរដ្ឋាភិបាលដែលកំណត់គោលដៅជាក់លាក់ រួមមានដូចជាផែនការសកម្មភាពជាតិ ដើម្បីបង្ការទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារដែរឬទេ ? | បាទ/ចាស ទេ | ភស្តុតាង | បើឆ្លើយ បាទ/ចាសៈ ពិន្ទុ ១ |

ពិន្ទុសរុបៈ
**៥ពិន្ទុៈ** ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ**មានគុណភាពល្អ**
**៣-៤ពិន្ទុៈ** ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ**ត្រូវការកែលម្អ**

| | |
|---|---|
| | **០-២ពិន្ទុ៖** ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ**ខ្វះគុណភាព**<br>គឺបានស្របជាមួយស្តង់ដារអន្តរជាតិ និងកំពុងអនុវត្តន៍<br>ផ្តល់ការប៉ាន់ប្រមាណយោងតាមរបាយការណ៍សវនកម្មទៅលើការអនុវត្តច្បាប់ |
| ប្រភពទិន្នន័យ | ក្របខ័ណ្ឌ និងគោលនយោបាយពាក់ព័ន្ធ |
| កម្រិតភាពញឹកញាប់ | រៀងរាល់ឆ្នាំ |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ភូមិសាស្ត្រ |
| ទីភ្នាក់ងារផ្តល់របាយការណ៍ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ( MoLVT ) ( នាយកដ្ឋានការងារកុមារ ) |
| ឯកសារយោង | សៀវភៅណែនាំអំពីសូចនាករកិច្ចការពារកុមាររបស់អង្គការយូនីសេហ្វ ឆ្នាំ២០១៨ |
| កំណត់សម្គាល់ | |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | |

| ឈ្មោះសូចនាករ | ១.៧ ផែនការតាមវិស័យ និងអនុវិស័យស្តីពីកិច្ចការពារកុមារត្រូវបានរៀបចំ |
|---|---|
| និយមន័យ | ផែនការតាមវិស័យឬផែនការយុទ្ធសាស្ត្រស្តីពីកិច្ចការពារកុមារ ជាផែនការយុទ្ធសាស្ត្រកម្រិតម៉ាក្រូ។ ផែនការនេះមានផែនការអនុវិស័យជាក់លាក់ដទៃទៀត ដូចជាផែនការ ស្តីពីការទប់ស្កាត់ និងឆ្លើយតបអំពើហិង្សាលើកុមារ ការថែទាំជំនួស យុត្តិធម៌អនីតិជន។ល។ ដែលបានបង្កលក្ខណៈ ឱ្យក្រសួងដឹកនាំកិច្ចការពារកុមារ។ |
| លទ្ធផលរំពឹងទុក (លទ្ធផលរយៈពេលខ្លី) | ពង្រឹងចំណាត់ការ និងការសម្របសម្រួលពហុវិស័យជាមួយពហុភាគីអ្នកពាក់ព័ន្ធ ដើម្បីបង្ការ និងឆ្លើយតបទៅនឹងបញ្ហាកិច្ចការពារកុមារ។ |
| វិធីសាស្ត្រគណនា | មាន ឬ គ្មានផែនការ ឬ យុទ្ធសាស្ត្រដែលស្របទៅនឹងធាតុផ្សំសំខាន់ៗដូចមាននៅក្នុងកំណត់សម្គាល់។ ស្ថានភាពនៃផែនការត្រូវបានកំណត់ប្រភេទដូចជា៖ កំពុងអភិវឌ្ឍ ត្រូវបានអនុម័ត មានការគណនាថ្លៃចំណាយ បានទទួលមូលនិធិ ឬ ត្រូវបានអនុវត្ត។ |
| ប្រភពទិន្នន័យ | ឯកសារផែនការ |
| កម្រិតភាពញឹកញាប់ | រៀងរាល់ឆ្នាំ |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ទៅតាមកម្មវិធីស្នូលដែលគ្មានផែនការ និងលក្ខណៈវិនិច្ឆ័យ |
| ទីភ្នាក់ងារផ្តល់របាយការណ៍ | MoSVY |
| ឯកសារយោង | ផែនការស្តីពីការទប់ស្កាត់ និងឆ្លើយតបអំពើហិង្សាលើកុមារ និងសេចក្តីណែនាំអំពីសូចនាករ INSPIRE  សេចក្តីណែនាំអំពីសូចនាករកិច្ចការពារកុមាររបស់អង្គការយូនីសេហ្វ |
| សូចនាករពាក់ព័ន្ធ | សូចនាករស្នូលរបស់ Inspire ១០.១ |
| កំណត់សម្គាល់ | |

| | |
|---|---|
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | ប្រទេសកម្ពុជាមានផែនការកិច្ចការពារកុមារជាច្រើន រួមមាននៅតាមក្រសួង និងស្ថាប័ននានា ដែលបានបញ្ចូលកិច្ចការពារកុមារជាផ្នែកមួយនៃផែនការសកម្មភាពរបស់ខ្លួន។ ទោះជាយ៉ាងនោះក្តី ប្រទេសកម្ពុជាមិនទាន់មានការវិភាគលើកិច្ចការពារកុមារគ្រប់វិស័យ ឬមានផែនការ និងក្របខ័ណ្ឌជារួមមួយស្តីពីកិច្ចការពារកុមារ ដើម្បីកំណត់ហិរញ្ញប្បទាន និងត្រួតពិនិត្យតាមដានពីវឌ្ឍនភាពនៃកិច្ចការពារកុមារនៅឡើយទេ ដែលជាមូលហេតុធ្វើឱ្យមានការលំបាកសម្រាប់ក្រសួង ស្ថាប័ននានា ក្នុងការដឹកនាំការងារផ្នែកការពារកុមារ។ ផែនការយុទ្ធសាស្ត្រស្តីពីកិច្ចការពារកុមារ នឹងមិនត្រូវបានបង្កើតឡើងដើម្បីជំនួសឱ្យផែនការតាមវិស័យនានាទេ អាស្រ័យដោយផែនការទាំងនោះនៅតែមានសារៈសំខាន់។ ផែនការយុទ្ធសាស្ត្រស្តីពីកិច្ចការពារកុមារ នឹងជួយបំពេញបន្ថែមនូវគុណតម្លៃរបស់ផែនការតាមវិស័យនានា តាមរយៈការប្រមូលផ្តុំរាល់អាទិភាពសំខាន់ៗចូលក្នុងផែនការរួមមួយ ហើយបញ្ចូលធាតុផ្សំសំខាន់ៗពីផែនការតាមវិស័យ និងពង្រឹងការបំពេញការងារ តាមរយៈការបង្កើនសង្គតភាព និងការបំពេញឱ្យគ្នាទៅវិញទៅមកនៃកិច្ចអន្តរាគមន៍ ដើម្បីគាំទ្រដល់ក្របខ័ណ្ឌការងាររួមស្តីពីកិច្ចការពារកុមារ។<br>ប្រទេសនានាអាចមានផែនការ ឬយុទ្ធសាស្ត្រច្រើន ប្រសិនបើផែនការ និងយុទ្ធសាស្ត្រទាំងនោះ រួមគ្នាបង្កើតបានជាអភិក្រមគ្រប់ជ្រុងជ្រោយមួយ។ លក្ខណៈវិនិច្ឆ័យសំខាន់ៗសម្រាប់គុណភាពនឹងទទួលបាន នៅពេលដែលផែនការដោះស្រាយបញ្ហា៖ (១) ភស្តុតាងទិន្នន័យដើមគ្រាពីការសិក្សា ប្រេវ៉ាឡង់ដែលមានមូលដ្ឋានផ្អែកលើប្រជាជនជាមួយនឹងគោលដៅ (២) ទិន្នន័យពីប្រភពរដ្ឋបាល (៣) ប្រភេទសំខាន់ៗនៃអំពើហិង្សាលើកុមារ និងក្មេងជំទង់ (ការអនុវត្តដាក់ពិន័យបែបហិង្សា អំពើហិង្សាផ្លូវភេទលើកុមារ និងក្មេងជំទង់ អំពើហិង្សានៅក្នុងនិងជុំវិញសាលារៀន ដូចជាការសម្លុតគំរាមកំហែង និងការវាយតប់គ្នា និងអំពើហិង្សាពីដៃគូស្និទ្ធស្នាលទៅលើក្មេងជំទង់ (៤) ការបង្ការ និងការឆ្លើយតប (៥) សមធម៌/សមភាពយេនឌ័រ (៦) សេចក្តីត្រូវការរបស់ក្រុមជនងាយរងគ្រោះ (៧) យុទ្ធសាស្ត្រសម្រាប់ការសម្របសម្រួលរវាងវិស័យនានា (ការផ្តល់សេវា និងការចែករំលែកទិន្នន័យ) (៨) ភាពគ្រប់ជ្រុងជ្រោយនៃការឆ្លើយតបផ្តល់សេវា (៩)អភិក្រមពហុវិស័យ (ក្នុងកម្រិតអប្បបរមា៖ យុត្តិធម៌ សុខាភិបាល សេវាសង្គម និងអប់រំ) (១០) ការចូលរួមពីពហុភាគីអ្នកពាក់ព័ន្ធរាប់បញ្ចូលសង្គមស៊ីវិល (១១) ការចូលរួមរបស់កុមារ និងក្មេងជំទង់ និង(១២) យុទ្ធសាស្ត្រដែលមានមូលដ្ឋានផ្អែកលើភស្តុតាងរាប់បញ្ចូលយុទ្ធសាស្ត្រ INSPIRE (សូចនាករ INSPIRE ១០.១)។ |

# វិស័យទី២៖ សមត្ថភាពនៃប្រព័ន្ធកិច្ចការពារកុមារ

| ឈ្មោះសូចនាករ | ២.១ ចំនួនបុគ្គលិកកម្លាំងសេវាសង្គម (បុគ្គលិករបស់រដ្ឋ និងបុគ្គលិករបស់អង្គការមិនមែនរដ្ឋាភិបាល ដែលផ្តល់សេវាសង្គម និងសេវាកិច្ចការពារកុមារ) |
|---|---|
| និយមន័យ | សម្ព័ន្ធសកលនៃកម្លាំងសេវាសង្គម (GSWA) កំណត់និយមន័យថាកម្លាំងសេវាសង្គមជាបុគ្គលិកដែលធ្វើការទាំងមានប្រាក់ខែឬគ្មានប្រាក់ខែ ជាបុគ្គលិករដ្ឋ ឬបុគ្គលិកអង្គការដែលបំពីការងារឱ្យប្រព័ន្ធសេវាសង្គម និងរួមចំណែកដល់ការថែទាំ ការគាំទ្រ និងការលើកកម្ពស់សិទ្ធិ និងផ្តល់អំណាចដល់ប្រជាជនដែលរងគ្រោះដែលត្រូវបានបម្រើដោយប្រព័ន្ធសេវាសង្គម។<br>ជំនាញវិជ្ជាជីវៈសង្គមកិច្ចជាផ្នែកមួយដ៏ទូលំទូលាយនៃកម្លាំងសេវាសង្គម |
| លទ្ធផលរំពឹងទុក (លទ្ធផលរយៈពេលខ្លី) | ពង្រឹងសមត្ថភាពវិជ្ជាជីវៈដើម្បីឆ្លើយតបនឹងតម្រូវការការពារកុមារ |
| វិធីសាស្ត្រគណនា | រាប់ចំនួនមន្ត្រីរបស់រដ្ឋ និងមន្ត្រីអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ ដែលបំពីការងារសេវាសង្គម និងចំនួនមន្ត្រីដែលផ្តល់សេវាការពារកុមារ |
| ប្រភពទិន្នន័យ | ឯកសាររដ្ឋបាល |
| កម្រិតភាពញឹកញាប់ | រៀងរាល់ឆ្នាំ |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | តាមប្រភេទនៃការបណ្តុះបណ្តាល តាមក្រសួង ឬទីភ្នាក់ងារ កម្រិតជាតិ ក្រោមជាតិ ភេទ |
| ទីភ្នាក់ងារទទួលខុសត្រូវរាយការណ៍អំពីទិន្នន័យ | MoSVY (នាយកដ្ឋានសុខុមាលភាពសង្គម) |
| ឯកសារយោង | |
| កំណត់សម្គាល់ | |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | |

| ឈ្មោះសូចនាករ | ២.២ ចំនួនកន្លែងថែទាំកុមារនៅក្នុងប្រទេស |
|---|---|
| និយមន័យ | កន្លែងថែទាំកុមារមានពីរប្រភេទ៖ មណ្ឌល និងសហគមន៍ (ការថែទាំតាមវត្តអារាម ផ្ទះស្នាក់នៅជាក្រុម ផ្ទះស្នាក់នៅបណ្ដោះអាសន្ន អន្តេវាសិកដ្ឋាន) (យោងគោលនយោបាយថែទាំជំនួសចំពោះកុមារឆ្នាំ២០០៦)។<br>ក្នុងបរិបទកម្ពុជា ចំនួនអ្នកផ្ដល់សេវាថែទាំរួមមានដូចខាងក្រោម៖<br>• មណ្ឌលថែទាំកុមារ៖ កន្លែងថែទាំកុមារមួយប្រភេទដែលផ្ដល់សេវាជូនដល់កុមារគ្រប់ប្រភេទ ដែលត្រូវបានបោះបង់ចោល ឬមិនអាចរស់នៅជាមួយគ្រួសារបង្កើតឬសាច់ញាតិនៅក្នុងសហគមន៍បាន និងដែលមានលក្ខខណ្ឌ ស្របទៅនឹងនិយមន័យបទដ្ឋានរបស់មណ្ឌលថែទាំកុមារដូចមានចែងនៅក្នុងបទដ្ឋានអប្បបរមាស្ដីពីការថែទាំជំនួសចំពោះកុមារ។ ជាទូទៅ កន្លែងថែទាំកុមារទាំងនេះផ្ដល់ការថែទាំក្នុងបរិយាកាសមួយដែលមិនមែនជាគ្រួសារនិងមានការរៀបចំរចនាសម្ព័ន្ធសម្រាប់កុមារជាច្រើននាក់។<br>• ការថែទាំតាមវត្តអារាម និងកន្លែងសាសនា៖ ការថែទាំដែលផ្ដល់ជូនកុមារដោយព្រះសង្ឃ ដូនជី អាចារ្យ និងស្ថាប័នសាសនាដែលជួយដោះស្រាយសេចក្ដីត្រូវការជាមូលដ្ឋានរបស់កុមារនៅក្នុងវត្តនិងកន្លែងសាសនាដទៃទៀត។<br>• ផ្ទះស្នាក់នៅជាក្រុម៖ ការថែទាំដែលផ្ដល់ជូនកុមារក្នុងចំនួនកំណត់ណាមួយនៅក្នុងបរិយាកាសមួយដែលដូចគ្នាទៅនឹងគ្រួសារក្រោមការត្រួតពិនិត្យពីអ្នកថែទាំមួយក្រុមតូច ដែលមិនមែនជាសាច់ញាតិរបស់កុមារ។ ជាទូទៅ យ៉ាងហោចណាស់ មានអ្នកថែទាំ១នាក់ដែលបានទទួលការបណ្ដុះបណ្ដាល និងបម្រើការងារផ្ដល់ការថែទាំដែលមិនពាក់ព័ន្ធនឹងវេជ្ជសាស្ត្រ និងគ្រប់គ្រងកុមាររយៈពេល២៤ម៉ោងនៅក្នុងបរិយាកាសមួយដែលមានរចនាសម្ព័ន្ធត្រឹមត្រូវ។<br>• ផ្ទះស្នាក់នៅបណ្ដោះអាសន្ន/ផ្ទះសំចត៖ ជាទម្រង់មួយនៃការថែទាំដែលមានកំណត់រយៈពេលស្នាក់នៅសម្រាប់កុមារ ដែលនៅក្នុងដំណើរការធ្វើផែនការគ្រួសារអចិន្ត្រៃយ៍ឬ កុមារដែលគ្រួសារកំពុងជួបប្រទះវិបត្តិធ្ងន់ធ្ងរនិងទាមទារឱ្យកូនរបស់ពួកគេស្នាក់នៅបណ្ដោះអាសន្នដើម្បីឱ្យបរិយាកាសគ្រួសារមានស្ថិរភាពឡើងវិញ។ បើទោះបីជាផ្ទះស្នាក់នៅបណ្ដោះអាសន្ន និងកន្លែងស្នាក់នៅបន្ទាន់បណ្ដោះអាសន្នអាចធ្វើការបែងចែកបន្ថែមទៀតក៏ដោយ ប៉ុន្តែរបាយការណ៍នេះប្រើប្រាស់ពាក្យទាំងពីរនេះរួមគ្នាតែមួយ។<br>• អន្តេវាសិកដ្ឋាន៖ ការរៀបចំលំនៅដ្ឋានសម្រាប់កុមារស្នាក់នៅរយៈពេលសិក្សាមួយវគ្គ ឬ ច្រើនវគ្គដើម្បីទទួលការអប់រំនៅឆ្ងាយពីផ្ទះ។ អន្តេវាសិកដ្ឋានត្រូវបានបញ្ចូលទៅក្នុងការកំណត់ទីតាំងកន្លែងថែទាំកុមារដោយសារតែមានក្ដីបារម្ភថាសាលារៀនមួយចំនួនការពិតអាចជាមណ្ឌលថែទាំកុមារ។ |

| | |
|---|---|
| លទ្ធផលរំពឹងទុក (លទ្ធផល រយៈពេលខ្លី) | សេវាសម្រាប់កុមារដែលគ្មានការថែទាំពីឪពុកម្ដាយត្រូវបានពង្រឹង |
| វិធីសាស្រ្តគណនា | ចំនួនសរុបតាមរយៈការចុះធ្វើអធិការកិច្ចជាក់ស្ដែង និងយោងបទដ្ឋានអប្បបរមាស្ដីពីការថែទាំជំនួសចំពោះកុមារ |
| ប្រភពទិន្នន័យ | ប្រព័ន្ធអធិការកិច្ច កន្លែងថែទាំជំនួស |
| កម្រិតភាពញឹកញាប់ | រៀងរាល់ឆ្នាំ/ម្ដងក្នុង១ឆ្នាំ |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ប្រភេទនៃការផ្ដល់សេវាតាមមណ្ឌល និងសហគមន៍ |
| ទីភ្នាក់ងារទទួលខុសត្រូវរាយការណ៍អំពីទិន្នន័យ | MoSVY-Child Welfare Development |
| ឯកសារយោង | |
| កំណត់សម្គាល់ | |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | |

| ឈ្មោះសូចនាករ | ២.៣ ចំនួនកន្លែងថែទាំកុមារតាមគ្រួសារក្នុងប្រទេស (គ្រួសារសាច់ញាតិជាផ្លូវការ និងគ្រួសារធម៌) |
|---|---|
| និយមន័យ | ការថែទាំដោយសាច់ញាតិ ៖ ការថែទាំតាមគ្រួសារសាច់ញាតិរបស់កុមារមានលក្ខណៈផ្លូវការ។<br>ការថែទាំដោយឪពុកម្តាយធម៌ ៖ ស្ថានភាពដែលកុមារត្រូវបានអាជ្ញាធរមានសមត្ថកិច្ចមួយធ្វើការទុកដាក់ សម្រាប់គោលបំណងថែទាំជំនួសនៅក្នុងបរិយាកាសគ្រួសារមួយដែលមិនមែនជាគ្រួសារបង្កើតរបស់កុមារ ដោយគ្រួសារនោះត្រូវបានជ្រើសរើសមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ បានទទួលការអនុម័តយល់ព្រម និងស្ថិតក្រោមការត្រួតពិនិត្យសម្រាប់ការផ្តល់ការថែទាំបែបនេះ។ |
| លទ្ធផលរំពឹងទុក (លទ្ធផលរយៈពេលខ្លី) | សេវាសម្រាប់កុមារដែលគ្មានការថែទាំពីឪពុកម្តាយត្រូវបានពង្រឹង |
| វិធីសាស្រ្តគណនា | ចំនួនសរុប |
| ប្រភពទិន្នន័យ | កំណត់ហេតុរដ្ឋបាល |
| កម្រិតភាពញឹកញាប់ | ត្រីមាស ឆមាស និងប្រចាំឆ្នាំ |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ប្រភេទនៃអ្នកផ្តល់សេវា ទំហំ ខេត្ត អាយុ ភេទ |
| ទីភ្នាក់ងារទទួលខុសត្រូវរាយការណ៍អំពីទិន្នន័យ | MoSVY (នាយកដ្ឋានសុខុមាលភាពកុមារ) |
| ឯកសារយោង | |
| កំណត់សម្គាល់ | |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | |

| ឈ្មោះសូចនាករ | ២.៤ ភាគរយនៃថវិការដ្ឋសម្រាប់កិច្ចការពារកុមារ (ថវិកាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) |
|---|---|
| និយមន័យ | ថវិកាទាក់ទងនឹងកិច្ចការពារកុមារនៅតាមបណ្តាក្រសួង ស្ថាប័ននានា ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងលក្ខណៈជាភាគរយនៃថវិកាជាតិសរុបសម្រាប់ឆ្នាំហិរញ្ញវត្ថុកន្លងមក។ នេះរួមមានចំណុចដូចខាងក្រោម៖<br>• រាល់សកម្មភាពទាក់ទងនឹងកិច្ចការពារកុមារក្រោមក្រសួង សអយ (រាល់សកម្មភាពរបស់នាយកដ្ឋានសុខុមាលភាពកុមារ និងសកម្មភាពពាក់ព័ន្ធរបស់នាយកដ្ឋានដទៃទៀត)<br>• សកម្មភាពទាក់ទងនឹងពលកម្មកុមារ ក្រោមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>• សកម្មភាពទាក់ទងនឹងយុត្តិធម៌អនីតិជន ក្រោមក្រសួងយុត្តិធម៌<br>• សកម្មភាពទាក់ទងនឹងកុមារ ក្រោមក្រសួងមហាផ្ទៃ<br>• ផែនការថវិកាសម្រាប់ការអនុវត្តសកម្មភាពសេវាសង្គមឃុំ សង្កាត់ ដែលអនុវត្តដោយផ្ទាល់របស់ គ.ក.ន.ក.<br>• ថវិកាពាក់ព័ន្ធដទៃទៀត<br>ចំនួនថវិកាប្រចាំឆ្នាំ ដែលរដ្ឋបាលសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ បានបែងចែក សម្រាប់អនុវត្តសកម្មភាពសេវាសង្គម (រាប់បញ្ចូលទាំងកិច្ចការពារកុមារ) ធៀបនឹងចំនួនថវិកា របស់រដ្ឋបាលសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់សរុប |
| លទ្ធផលរំពឹងទុក (លទ្ធផល រយៈពេលខ្លី) | សមត្ថភាពហិរញ្ញវត្ថុត្រូវបានពង្រឹងដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការកិច្ចការពារកុមារ |

| | |
|---|---|
| វិធីសាស្ត្រគណនា | ថវិកាសរុបសំរាប់កិច្ចការពារកុមារ /ថវិកាសរុប មេគុណ ១០០ (ថ្នាក់ជាតិ)<br>ចំនួនថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់សម្រាប់អនុវត្តសកម្មភាពសេវាសង្គម/ ចំនួនថវិកាឃុំ សង្កាត់សរុប មេគុណ ១០០ (ថ្នាក់ក្រោមជាតិ) |
| ប្រភពទិន្នន័យ | ថវិកាជាតិ របាយការណ៍ថវិកាឃុំ សង្កាត់ ក្នុង iSAF Database របស់ NCDD |
| កម្រិតភាពញឹកញាប់ | រៀងរាល់ឆ្នាំ |
| កម្រិតនៃការប៉ាន់ប្រមាណ/ ការបំបែកទិន្នន័យ | ទៅតាមក្រសួង ស្ថាប័ននានា ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ប្រភេទនៃកិច្ចការពារកុមារ |
| ទីភ្នាក់ងារទទួលខុសត្រូវរាយការណ៍អំពីទិន្នន័យ | ថវិកាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ: MEF-នាយកដ្ឋានថវិកានីយកម្ម នៃអគ្គនាយកដ្ឋានថវិកា<br>អគ្គនាយកដ្ឋានហិរិញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ នាយកដ្ឋានចំណាយ<br>ថវិកានៃអគ្គនាយកដ្ឋានរតនាគារជាតិ<br>ថវិកាថ្នាក់ក្រោមជាតិ: MoI/NCDD(គណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ) |
| ឯកសារយោង | សៀវភៅណែនាំស្តីពីការអនុវត្តសកម្មភាពសេវាសង្គមឃុំ សង្កាត់ (អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ)<br>សៀវភៅណែនាំស្តីពីការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ឃុំ សង្កាត់ (អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ)<br>សៀវភៅណែនាំស្តីពីកិច្ចការពារកុមារ សម្រាប់ឃុំ សង្កាត់ (អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ) |
| កំណត់សម្គាល់ | |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | តំណទៅកាន់ ថវិកាឃុំ សង្កាត់សម្រាប់អនុវត្តសកម្មភាពសេវាសង្គម iSAF Database of NCDD<br>http://mis.ncdd.gov.kh/isaf |

| ឈ្មោះសូចនាករ | ២.៥ ភាគរយនៃមូលនិធិខាងក្រៅសម្រាប់កិច្ចការពារកុមារ (ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល) |
|---|---|
| និយមន័យ | ភាគរយនៃថវិកាសម្រាប់កិច្ចការពារកុមារ ពីម្ចាស់ជំនួយក្នុងចំណែកថវិកាសរុបរបស់ម្ចាស់ជំនួយ<br>ភាគរយនៃថវិកាសម្រាប់កិច្ចការពារកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល ក្នុងចំណែកថវិកាសរុបរបស់អង្គការមិនមែនរដ្ឋាភិបាល |
| លទ្ធផលរំពឹងទុក (លទ្ធផលរយៈពេលខ្លី) | បង្កើនជំនួយថវិកាខាងក្រៅសម្រាប់កិច្ចការពារកុមារ |
| វិធីសាស្ត្រគណនា | ធនធានសរុបសម្រាប់កិច្ចការពារកុមាររបស់ដៃគូអភិវឌ្ឍន៍/ធនធានសរុបរបស់ដៃគូអភិវឌ្ឍន៍ មេគុណ ១០០<br>ធនធានសរុបសម្រាប់កិច្ចការពារកុមារ របស់អង្គការមិនមែនរដ្ឋាភិបាល/ធនធានសរុបរបស់អង្គការមិនមែនរដ្ឋាភិបាល មេគុណ ១០០ |
| ប្រភពទិន្នន័យ | Cambodia ODA Database |
| កម្រិតភាពញឹកញាប់ | រៀងរាល់ឆ្នាំ |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ទៅតាមប្រភេទសកម្មភាព និងម្ចាស់ជំនួយ |
| ទីភ្នាក់ងារទទួលខុសត្រូវរាយការណ៍អំពីទិន្នន័យ | គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ.ជ.នា/ ក.អ.ក) |
| ឯកសារយោង | |
| កំណត់សម្គាល់ | |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | The Cambodia ODA Database<br>http://odacambodia.com/ngo/report/listing_by_sector.asp#none |

# វិស័យទី៣៖ ការបង្ការ និងកិច្ចការពារ

| ឈ្មោះសូចនាករ | ៣.១ សមាមាត្រនៃកុមារដែលមានអាយុក្រោម ៥ឆ្នាំបានចុះបញ្ជីកំណើតនៅរដ្ឋបាលឃុំ សង្កាត់ |
|---|---|
| និយមន័យ | ភាគរយនៃកុមារអាយុក្រោម៥ឆ្នាំ ដែលបានចុះបញ្ជីកំណើតនៅរដ្ឋបាលឃុំ សង្កាត់។ ចំណុចនេះសំដៅចំពោះភាគរយនៃកុមារអាយុក្រោម៥ឆ្នាំ ( ០ខែ ទៅ ៥៩ខែ ) ដែលមានសំបុត្រកំណើត ឬ កំណើតរបស់កុមារត្រូវបានរាយការណ៍ថាបានចុះបញ្ជីនៅរដ្ឋបាលឃុំ សង្កាត់ ដោយអ្នកថែទាំបឋម គិតត្រឹមពេលធ្វើការអង្កេតនេះ។<br>ការចុះបញ្ជីកំណើតគឺជាការកត់ត្រាជាបន្តបន្ទាប់ អចិន្ត្រៃយ៍ និងមានលក្ខណៈជាសកលនៅក្នុងបញ្ជីអត្រានុកូលដ្ឋាន អំពីការកើត និងលក្ខណៈនៃកំណើត ស្របតាមលក្ខខណ្ឌតម្រូវផ្នែកច្បាប់របស់ប្រទេសមួយ។ |
| លទ្ធផលរំពឹងទុក | ការចុះបញ្ជីកំណើតរបស់កុមារ គឺជាជំហានដំបូងក្នុងការធានាឱ្យមានការទទួលស្គាល់ពួកគេនៅចំពោះមុខច្បាប់ ការពារសិទ្ធិរបស់ពួកគេ និងធានាថាការរំលោភបំពានទៅលើសិទ្ធិទាំងនេះមិនត្រូវបានព្រងើយកន្តើយ។ ដើម្បីធានាថាកុមារគ្រប់រូបមានឯកសារចាំបាច់ដើម្បីទទួលសេវា ( សេវាថែទាំសុខភាព អប់រំ និងការពារ ) ត្រូវគណនាអត្រាមរណៈរបស់ទារក។ |
| វិធីសាស្ត្រគណនា | ភាគយក៖ កុមារដែលត្រូវបានរាយការណ៍ថាបានចុះបញ្ជីកំណើត ជាមួយអាជ្ញាធរអត្រានុកូលដ្ឋាន គិតត្រឹមពេលធ្វើការអង្កេតនេះ។<br>ភាគបែង៖ កុមារគ្រប់រូបអាយុក្រោម៥ឆ្នាំ<br>មេគុណ៖ ១០០ |
| ប្រភពទិន្នន័យ | ការអង្កេតគ្រួសារដែលមានមូលដ្ឋានផ្អែកលើចំនួនប្រជាជន ៖ CDHS<br>កំណត់ហេតុរដ្ឋបាល<br>ប្រព័ន្ធទិន្នន័យឃុំ ( CDB ) |
| កម្រិតភាពញឹកញាប់ | រៀងរាល់៥ឆ្នាំម្តង CDHS<br>រៀងរាល់ឆ្នាំ MoI ( នាយកដ្ឋានអត្រានុកូលដ្ឋាននៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ), Commune Database ( CDB ) |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ភេទ អាយុ កម្រិតទ្រព្យសម្បត្តិ ទីប្រជុំជន ឬទីជនបទ |

| | |
|---|---|
| ទីភ្នាក់ងារទទួលខុសត្រូវរាយការណ៍អំពីទិន្នន័យ | MoP/NIS -CDHS<br>MoI/នាយកដ្ឋានអត្រានុកូលដ្ឋាននៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម<br>NCDD-Commune Database ( CDB ) |
| ឯកសារយោង | សូចនាករ SDG ១៦.៩.១<br>សៀវភៅណែនាំអំពីសូចនាករកិច្ចការពារកុមាររបស់អង្គការយូនីសេហ្វ សូចនាករ ៣.៧ |
| កំណត់សម្គាល់ | ស្វែងរកព័ត៌មានសារតា ថាតើមានសេវាចុះបញ្ជីកំណើតដោយឥតគិតថ្លៃជាសកលនៅក្នុងការចុះបញ្ជីអត្រានុកូលដ្ឋាន ដោយយោងទៅតាមលក្ខខណ្ឌតម្រូវរបស់ច្បាប់ជាតិ ដែរឬទេ (សៀវភៅណែនាំអំពីសូចនាករកិច្ចការពារកុមាររបស់អង្គការយូនីសេហ្វ ) |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | |

| ឈ្មោះសូចនាករ | ៣.២ ភាគរយនៃអ្នកថែទាំដែលយល់ស្របទៅនឹងភាពចាំបាច់ក្នុងការប្រើហិង្សាលើរាងកាយសម្រាប់ការចិញ្ចឹមកុមារ |
|---|---|
| និយមន័យ | សមាមាត្រនៃអ្នកថែទាំដែលរាយការណ៍ថា ពួកគេមិនយល់ស្របថាទណ្ឌកម្មលើរាងកាយមានភាពចាំបាច់ក្នុងការចិញ្ចឹមកូន គិតត្រឹមពេលធ្វើការអង្កេត។<br>ចំនួនអ្នកផ្តល់ចម្លើយជាមនុស្សពេញវ័យ ឬ ជាក្មេងជំទង់ដែលយល់ស្របថាដើម្បីចិញ្ចឹម (ចិញ្ចឹម អប់រំ) កូនម្នាក់ឱ្យបានត្រឹមត្រូវ ឪពុកម្តាយ ឬ អ្នកថែទាំត្រូវប្រើទណ្ឌកម្មលើរាងកាយ ដោយបង្ហាញជាភាគរយនៃមនុស្សពេញវ័យ ឬ ក្មេងជំទង់គ្រប់រូបដែលត្រូវបានសួរអំពីការយល់ស្របរបស់ពួកគេទៅនឹងភាពចាំបាច់នៃការប្រើប្រាស់ទណ្ឌកម្មលើរាងកាយ។ ចន្លោះអាយុរបស់អ្នកផ្តល់ចម្លើយ គឺអាស្រ័យលើអ្វីដែលមានភាពពាក់ព័ន្ធ ក្រមសីលធម៌ លទ្ធភាពអាចទៅរួច/អ្វីដែលមាន សម្រាប់ប្រទេស។ |
| លទ្ធផលរំពឹងទុក (លទ្ធផលរយៈពេលវែង) | និយាម និងគុណតម្លៃរបស់ក្រុមសំខាន់ៗ គាំទ្រដល់ទំនាក់ទំនងអហិង្សា ផ្តល់ការគោរព អំណោយផលដល់ការចិញ្ចឹមបីបាច់ និងមានសមភាពយេនឌ័រ សម្រាប់កុមារ និងក្មេងជំទង់គ្រប់រូប។ ការកាត់បន្ថយសមាមាត្រនៃមនុស្សពេញវ័យ និងក្មេងជំទង់ដែលជឿថាទណ្ឌកម្មលើរាងកាយមានភាពចាំបាច់សម្រាប់ការចិញ្ចឹមកូន គឺជាលទ្ធផលរំពឹងទុកមួយរបស់យុទ្ធសាស្ត្រ INSPIRE យ៉ាងហោចណាស់ចំនួនពីរ ក្នុងនោះរួមមាននិយាម និងគុណតម្លៃ និង កិច្ចគាំទ្រពីឪពុកម្តាយ និងអ្នកថែទាំ (Inspire)។ |
| វិធីសាស្ត្រគណនា | ភាគយក៖ ចំនួនក្មេងជំទង់ ឬ មនុស្សពេញវ័យស្រីប្រុស ដែលយល់ស្របថាទណ្ឌកម្មលើរាងកាយមានភាពចាំបាច់សម្រាប់ចិញ្ចឹមបីបាច់/អប់រំកូនម្នាក់ឱ្យបានសមស្រប។<br>ភាគបែង៖ ចំនួនក្មេងជំទង់ ឬ មនុស្សពេញវ័យស្រីប្រុសសរុប ដែលត្រូវបានសួរអំពីការយល់ស្របចំពោះភាពចាំបាច់នៃការប្រើប្រាស់ទណ្ឌកម្មលើរាងកាយ។<br>មេគុណ៖ ១០០ |
| ប្រភពទិន្នន័យ | ការអង្កេតជាទៀងទាត់<br>ការអង្កេតPROTECT |
| កម្រិតភាពញឹកញាប់ | រៀងរាល់ ៣-៥ឆ្នាំម្តង (ការអង្កេតជាទៀងទាត់ ការអង្កេតPROTECT) |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ទៅតាមភេទ និងចន្លោះអាយុរបស់អ្នកផ្តល់ចម្លើយ លំនៅដ្ឋាន (ជនបទ/ទីក្រុង) ទ្រព្យសម្បត្តិគ្រួសារ កម្រិតនៃការអប់រំ |
| ទីភ្នាក់ងារទទួលខុសត្រូវ | MoP/NIS |

| | |
|---|---|
| ឯកសារយោង | សូចនាករ Inspire ៤.១<br>សូចនាករ៣.២ ស្តីពីកិច្ចការពារកុមាររបស់អង្គការយូនីសេហ្វ |
| កំណត់សម្គាល់ | សូចនាករ Inspire សាកសួរអំពី "ការយល់ស្រប" ដោយឡែកសូចនាករត្រង់ចំណុចនេះផ្តោតលើ "ការមិនយល់ស្រប"។ ដោយសារវាគឺជាភាគរយសាមញ្ញ ដូច្នេះការកំណត់ទាំងពីរនេះអាចយកមកគណនាបានយ៉ាងងាយប្រសិនបើត្រូវការ។<br>សូមពិនិត្យមើលថាតើគេអាចដាក់បញ្ចូលទៅក្នុង DHS បានដែរឬទេ។ |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | ការប៉ាន់ប្រមាណនៅកម្រិតថ្នាក់ជាតិសម្រាប់ស្ទើរតែគ្រប់ប្រទេសទាំងអស់ដែលមានការអង្កេត MICS អាចរកបានពី MICS ( http://mics.unicef.org/surveys )។ ទិន្នន័យពីប្រទេសចំនួន៧៥ អាចរកបានពីការវិភាគរបស់អង្គការយូនីសេហ្វ ឆ្នាំ២០១៧ នៅក្នុងឯកសារដែលមានឈ្មោះថា មុខដែលធ្លាប់ស្គាល់៖ អំពើហិង្សានៅក្នុងជីវិតរបស់កុមារ និងក្មេងជំទង់<br>( A Familiar Face: Violence in the lives of children and adolescents ) |

| ឈ្មោះសូចនាករ | ៣.៣ ភាគរយនៃកុមារី និងកុមារាអាយុចន្លោះពី ១-១៧ឆ្នាំ ដែលបានទទួលបទពិសោធន៍នៃការដាក់ វិន័យអហិង្សាណាមួយពីសំណាក់អ្នកថែទាំក្នុងរយៈពេល១ខែចុងក្រោយ |
|---|---|
| | សមាមាត្រនៃអ្នកថែទាំដែលរាយការណ៍ថាពួកគេបានប្រើប្រាស់វិធីសាស្រ្តដាក់ទណ្ឌកម្មបែបអហិង្សាក្នុងខែកន្លងមក។<br><br>ចំនួនកុមារី និងកុមារាអាយុចន្លោះពី ១-១៧ឆ្នាំ ដែលបានទទួលបទពិសោធន៍នៃការប្រើប្រាស់វិធីសាស្រ្តអនុវត្តដាក់ពិន័យបែបអហិង្សា ក្នុងខែកន្លងមក ពីអ្នកថែទាំនៅក្នុងផ្ទះ ដោយបង្ហាញតាមរយៈភាគរយនៃកុមារី និងកុមារាគ្រប់រូបអាយុចន្លោះពី ១-១៧ឆ្នាំ។ ចន្លោះអាយុរបស់អ្នកផ្តល់ចម្លើយ គឺអាស្រ័យលើអ្វីដែលមានភាពពាក់ព័ន្ធ ក្រមសីលធម៌ លទ្ធភាពអាចទៅរួច/ការមាន សម្រាប់ប្រទេស។ ការអង្កេត MICS សួរម្តាយ ឬ អ្នកថែទាំបឋម ថាតើកុមារី ឬ កុមារាម្នាក់អាយុចន្លោះពី ១-១៤ឆ្នាំ ដែលត្រូវបានជ្រើសរើសដោយចៃដន្យនៅក្នុងគ្រួសារ បានទទួលបទពិសោធន៍នូវបញ្ជីរាយនាមសកម្មភាពជាក់លាក់ទាក់ទងនឹងអាកប្បកិរិយា ក្នុងខែកន្លងមកដែរឬទេ។ សូចនាករនេះក៏អាចត្រូវបានវាស់វែងតាមរយៈការសួរអ្នកផ្តល់ចម្លើយជាក្មេងជំទង់ |
| និយមន័យ | ថាតើពួកគេបានទទួលបទពិសោធន៍នូវសកម្មភាពអនុវត្តការដាក់ពិន័យបែបអហិង្សាពីអ្នកថែទាំ ក្នុងខែកន្លងទៅ ឬ ឆ្នាំកន្លងទៅដែរឬទេ។ **ការអនុវត្តដាក់ពិន័យបែបអហិង្សា** រួមមានសកម្មភាពអនុវត្តដាក់ពិន័យដែលគ្មានភាពកោងកាចទៅលើរាងកាយ ឬ ពាក្យសម្តី ដូចជាការពន្យល់ទៅកុមារថាហេតុអ្វីបានជាការប្រព្រឹត្តណាមួយមិនត្រឹមត្រូវ ការដកហូតបុព្វសិទ្ធិ ការមិនអនុញ្ញាតឱ្យកុមារចាកចេញពីផ្ទះ ឬ ការផ្តល់ឱ្យកុមារធ្វើអ្វីផ្សេង។ ( Inspire )<br><br>Save the Children អាចផ្តល់របាយការណ៍ ចំនួន និង%នៃឪពុកម្តាយនិងអាណាព្យាបាល និងសមាជិកក្រុមឪពុកម្តាយក្នុងឃុំគោលដៅប្រើការអប់រំកូនបែបវិជ្ជមាន។<br><br>តែ Save the Childrenកំណត់និយមន័យការដាក់វិន័យមិនប្រើហិង្សាផ្សេង ដោយការដកបុព្វសិទ្ធិកុមារ ឬមិនឱ្យកុមារធ្វើអ្វីមួយជាបណ្តោះអាសន្ន មិនចាត់ជាការមិនប្រើហិង្សាទេ។ |
| លទ្ធផលរំពឹងទុក ( លទ្ធផលរយៈពេលវែង ) | ឪពុកម្តាយ និងអ្នកថែទាំពង្រឹងការអនុវត្តចិញ្ចឹមកូនបែបវិជ្ជមាន និងបង្កើតទំនាក់ទំនងចិញ្ចឹមបីបាច់ និងផ្តល់ការគាំទ្ររវាងឪពុកម្តាយនិងកូនឱ្យកាន់តែប្រសើរ។ |

| | |
|---|---|
| វិធីសាស្ត្រគណនា | ភាគយក៖ ចំនួនកុមារី និងកុមារាអាយុចន្លោះពី ១-១៧ឆ្នាំ ដែលបានទទួលបទពិសោធន៍ការអនុវត្តដាក់ពិន័យបែបអហិង្សា ក្នុងខែកន្លងមក។<br>ភាគបែង៖ ចំនួនកុមារី និងកុមារាសរុប អាយុចន្លោះពី ១-១៧ឆ្នាំ<br>មេគុណ៖ ១០០ |
| ប្រភពទិន្នន័យ | ការអង្កេត និងរបាយការណ៍ជាក់លាក់ ការអង្កេត PROTECT |
| កម្រិតភាពញឹកញាប់ | រៀងរាល់ ៣-៥ឆ្នាំម្តង |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ទៅតាមភេទរបស់កុមារ ចន្លោះអាយុរបស់កុមារ ទ្រព្យសម្បត្តិគ្រួសារ លំនៅដ្ឋាន (ជនបទ/ទីក្រុង) ពិការភាព ប្រសិនបើមានទិន្នន័យ និងលក្ខណៈសង្គមប្រជាសាស្ត្រដទៃទៀត ដែលទាក់ទងទៅនឹងបរិបទ។ |
| ទីភ្នាក់ងារទទួលខុសត្រូវរាយការណ៍អំពីទិន្នន័យ | MoP/NIS, UNICEF |
| ឯកសារយោង | សូចនាករ Inspire ៦.១(កិច្ចគាំទ្រពីឪពុកម្តាយ និងអ្នកថែទាំ) |
| កំណត់សម្គាល់ | |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | ការប៉ាន់ប្រមាណថ្នាក់ជាតិសម្រាប់ប្រទេសជាង១០០ ដែលរបាយការណ៍អង្កេត MICS ដែលបានបោះពុម្ពផ្សាយរួចរាល់ អាចរកបានពីអង្គការយូនីសេហ្វ (http://mics.unicef.org/surveys)។ ទិន្នន័យ VACS អាចរកបានពី CDC (www.cdc.gov/violenceprevention/childabuseandneglect/vacs/index.html)។ |

| ឈ្មោះសូចនាករ | ៣.៤ ចំនួនម្ដាយ ឪពុក អាណាព្យាបាលនិងអ្នកថែទាំ ដែលបានទទួលការអប់រំពីកម្មវិធីចិញ្ចឹមកូនបែបវិជ្ជមាន (កម្រិត១ កម្រិត២ កម្រិត៣) |
|---|---|
| និយមន័យ | ម្ដាយ ឪពុក អាណាព្យាបាលនិងអ្នកថែទាំ ដែលបានទទួលការបណ្ដុះបណ្ដាលនៅក្នុងវគ្គបណ្ដុះបណ្ដាលស្ដីពីការចិញ្ចឹមកូនបែបវិជ្ជមាន ដែលត្រូវបានរចនាដោយរាជរដ្ឋាភិបាលកម្ពុជា ៖<br><br>កម្មវិធីចិញ្ចឹមកូនបែបវិជ្ជមានកម្រិត១ , ២ ឬ ៣ ឬ កម្មវិធីចិញ្ចឹមកូនដទៃទៀត ដែលស្រដៀងគ្នាទៅនឹងកម្មវិធីទាំងនេះ។ សម្រាប់ការសំដៅយោងចំពោះកម្មវិធីដទៃទៀត សូមមើលសេចក្ដីពណ៌នាខាងក្រោម៖<br><br>កម្មវិធីអប់រំអំពីការចិញ្ចឹមកូនបែបវិជ្ជមាន មានគោលបំណងបង្ការអំពើហិង្សាផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទ ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវការប្រាស្រ័យទាក់ទងរវាងឪពុកម្ដាយនិងកូន។ កម្មវិធីទាំងនេះអាចត្រូវបានផ្ដល់ជូនក្នុងបរិបទជាច្រើនយ៉ាងទូលំទូលាយ និងត្រូវបានរចនាឡើងដើម្បីអភិវឌ្ឍអភិក្រមនៃការអនុវត្តដាក់ពិន័យបែបវិជ្ជមាន បង្កើនចំណេះដឹងអំពីការអភិវឌ្ឍកុមារ និងលើកកម្ពស់ការប្រាស្រ័យទាក់ទងបែបវិជ្ជមានរវាងឪពុកម្ដាយ និងកូន និង ការប្រាស្រ័យទាក់ទងរវាងឪពុកម្ដាយ និងកូន។ កម្មវិធីទាំងនេះ រមែងតែងត្រូវបានអនុវត្តន៍និងអាចកំណត់គោលដៅចំពោះសហគមន៍ទាំងមូល ឬ ក្រុមប្រជាជនគោលដៅណាមួយ។ (សៀវភៅណែនាំអំពីសូចនាករកិច្ចការពារកុមាររបស់អង្គការយូនីសេហ្វ ឆ្នាំ២០១៨)<br><br>**'ការចិញ្ចឹមកូន'**៖ មានវិស័យការងារចម្បងៗចំនួន៥នៃការចិញ្ចឹមកូន៖ ក) ការថែទាំ (សុខភាព អនាម័យ និងការអនុវត្តទាក់ទងនឹងអាហារូបត្ថម្ភ) ខ) ការជំរុញ (ការប្រាស្រ័យទាក់ទង សកម្មភាពរៀនសូត្រ ការធ្វើជាគំរូ) គ) កិច្ចគាំទ្រ និងការឆ្លើយតប (ការជឿទុកចិត្ត មនោសញ្ចេតនា ការមានអារម្មណ៍ថាមានសន្តិសុខសុវត្ថិភាព) ឃ) រចនាសម្ព័ន្ធ (ទម្លាប់ វិន័យ ការត្រួតពិនិត្យ កិច្ចការពារពីគ្រោះថ្នាក់) និង ង) ការចូលរួមសកម្មភាពនៅក្នុងសង្គម។ ប្រសិនបើរួមបញ្ចូលគ្នា វិស័យចម្បងៗនៃការចិញ្ចឹមកូននេះ ជួយលើកកម្ពស់ការថែទាំចិញ្ចឹមបីបាច់កូន ដែលចាំបាច់សម្រាប់សុខភាព ការលូតលាស់ ការអភិវឌ្ឍ ការរៀនសូត្រ កិច្ចការពារ និងសុខុមាលភាពរបស់កូន។ (សៀវភៅណែនាំអំពីសូចនាករកិច្ចការពារកុមាររបស់អង្គការយូនីសេហ្វ ឆ្នាំ២០១៨)<br><br>**'កម្មវិធីចិញ្ចឹមកូន'**៖ កម្មវិធីចិញ្ចឹមកូនអាចជួយបង្ការអំពើហិង្សាផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទ និងកំណត់គោលដៅឪពុកម្ដាយរបស់កូនដែលមានអាយុចន្លោះពី 0-១៨ឆ្នាំ។ កម្មវិធីចិញ្ចឹមកូន គប្បីបង្កលក្ខណៈឱ្យមានការចូលរួមពីឪពុកម្ដាយ និងអ្នកថែទាំគ្រប់រូបដែលបំពេញមុខងារចិញ្ចឹមកូន ដើម្បីឱ្យការផ្ដល់សារ និងមុខងារនៃការចិញ្ចឹមកូនមានសង្គតភាព និងមានភាពសមស្របនៅក្នុងគ្រួសារ។ សកម្មភាពទូទៅរួមមានការបណ្ដុះបណ្ដាលបុគ្គលិកសង្គមកិច្ច ការត្រួតពិនិត្យកត្តារាំងស្ទះ និងការរៀបចំផែនការសកម្មភាព នៅកម្រិតថ្នាក់ស្រុក ការស្រាវជ្រាវអំពីការអនុវត្តនៅថ្នាក់ក្រោមជាតិ ដើម្បីកែលម្អកម្មវិធី ការពង្រឹងយន្តការត្រួតពិនិត្យ ឬ អន្តរាគមន៍ដោយផ្ទាល់ដទៃទៀត |

| | |
|---|---|
| | តាមរយៈស្ថាប័នរដ្ឋាភិបាល ឬ អង្គការសង្គមស៊ីវិល (CSOs). (សៀវភៅណែនាំអំពីសូចនាករកិច្ចការពារកុមាររបស់អង្គការយូនីសេហ្វ ឆ្នាំ២០១៨) |
| លទ្ធផលរំពឹងទុក (លទ្ធផលរយៈពេលខ្លី/វែង) | បរិយាកាសនៅផ្ទះដែលអំណោយផលដល់ការចិញ្ចឹមបីបាច់សម្រាប់កុមារគ្រប់រូប |
| វិធីសាស្ត្រគណនា | រាប់បុគ្គលគ្រប់រូបដែលបានទទួលការបណ្តុះបណ្តាល |
| ប្រភពទិន្នន័យ | កំណត់ហេតុរដ្ឋបាល |
| កម្រិតភាពញឹកញាប់ | រៀងរាល់ឆ្នាំ |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ខេត្ត , ភេទ ដោយបំបែកទៅតាមម្តាយ ឪពុក ឬ អ្នកថែទាំ, បំបែកទៅតាមម្តាយ ឪពុក និងអ្នកថែទាំដែលមានកូនអាយុក្រោម៥ឆ្នាំ។ |
| ទីភ្នាក់ងារផ្តល់របាយការណ៍ | MoWA |
| ឯកសារយោង | សូចនាករ ៣.៣a ស្តីពីកិច្ចការពារកុមាររបស់អង្គការយូនីសេហ្វ<br>ផែនការសកម្មភាពស្តីពីអំពើហិង្សាលើកុមារ, កម្រងមេរៀនអំពីការចិញ្ចឹមកូនបែបវិជ្ជមានរបស់ MoWA, |
| កំណត់សម្គាល់ | |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | |

| ឈ្មោះសូចនាករ | ៣.៥ ចំនួនកុមារដែលទទួលបានការឧបត្ថម្ភពីកម្មវិធីជាតិជំនួយសង្គម |
|---|---|
| និយមន័យ | សំដៅដល់កុមារក្រីក្រដែលទទួលបានការឧបត្ថម្ភពីកម្មវិធីជាតិជំនួយសង្គម រួមមាន<br>កុមារពិការក្រីក្រតាមសហគមន៍ដែលទទួលបានប្រាក់ឧបត្ថម្ភពីរបប គោលនយោបាយចំពោះជនពិការក្រីក្រតាមសហគមន៍ (ក្រីក្រកម្រិត១ និងកម្រិត២)<br>កុមារបានទទួលអាហារូបករណ៍ជាសាច់ប្រាក់ពីកម្មវិធីអាហារូបករណ៍សម្រាប់សិស្សក្រីក្រថ្នាក់បឋមសិក្សា និងមធ្យមសិក្សាពីក្រសួងអប់រំ<br>កុមារអាយុក្រោម ២ឆ្នាំដែលទទួលបានប្រាក់ឧបត្ថមពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ<br>កុមារទទួលបានការឧបត្ថម្ភពីកម្មវិធីផ្តល់អាហារតាមសាលារៀន ដោយប្រើប្រាស់កសិផលក្នុងសហគមន៍ |
| លទ្ធផលរំពឹងទុក (លទ្ធផល រយៈពេលវែង) | ដើម្បីជួយសម្រួលកម្រិតជីវភាពរបស់កុមារនៅក្នុងគ្រួសារ ដើម្បីបង្ការបញ្ហាកិច្ចការពារកុមារ។ |
| វិធីសាស្ត្រគណនា | រាប់ចំនួនកុមារី និងកុមារា អាយុចន្លោះពី ០-១៧ឆ្នាំ ដែលទទួលបានការឧបត្ថម្ភពីកម្មវិធីជាតិជំនួយសង្គមកាលពីឆ្នាំកន្លងទៅ |
| ប្រភពទិន្នន័យ | កំណត់ហេតុរដ្ឋបាល |
| កម្រិតភាពញឹកញាប់ | រៀងរាល់ឆ្នាំ |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ភេទ អាយុ (ទីក្រុង/ជនបទ) តំបន់ភូមិសាស្ត្រនៅថ្នាក់ក្រោមជាតិ (ខេត្ត) កម្រិតទ្រព្យសម្បត្តិ ទីក្រុង-ជនបទ ទៅតាមចំនួនកុមារក្រីក្រដែលបានរាប់ដោយប្រព័ន្ធអត្តសញ្ញាណកម្មគ្រួសារក្រីក្រ |
| ទីភ្នាក់ងារទទួលខុសត្រូវរាយការណ៍អំពីទិន្នន័យ | MoSVY (នាយកដ្ឋានសុខុមាលភាពសង្គម, នាយកដ្ឋានសុខុមាលជនពិការ), MoEYS (ការិយាល័យអាហារូបករណ៍ នៃនាយកដ្ឋានបឋមសិក្សា នឹងការិយាល័យអាហារូបករណ៍ នៃនាយកដ្ឋានមធ្យមសិក្សាទូទៅ) |

| | |
|---|---|
| ឯកសារយោង | ១ អនុក្រឹត្យលេខ ១៣៧ អនក្រ. បក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១ ស្តីពីរបប គោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍។<br>-អនុក្រឹត្យលេខ ២០៩ ស.អ.យ. ប្រ.ក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យប្រើប្រាស់នូវគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍។<br>២ អនុក្រឹត្យលេខ ២៤៥ អនក្រ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ។<br>-សៀវភៅប្រតិបត្តិគោលស្តីពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ។ |
| កំណត់សម្គាល់ | |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | |

| ឈ្មោះសូចនាករ | ៣.៦. ចំនួនកន្លែងថែទាំកុមារដែលគោរពតាមបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារ<br>ក ) ភាគរយនៃកន្លែងថែទាំកុមារត្រូវបានធ្វើអធិការកិច្ច ដោយអនុលោមទៅតាមបទដ្ឋានអប្បបរមាដែលកំណត់ដោយក្រសួង ស.អ.យ<br>ខ ) ភាគរយនៃកន្លែងថែទាំតាមគ្រួសារ ( គ្រួសារសាច់ញាតិជាផ្លូវការ និងគ្រួសារធម៌ ) ត្រូវបានធ្វើអធិការកិច្ច ដោយអនុលោមទៅតាមបទដ្ឋានអប្បបរមាដែលកំណត់ដោយក្រសួង ស.អ.យ |
|---|---|
| និយមន័យ | ការថែទាំជំនួសចំពោះកុមារ គឺជាការថែទាំទាំងឡាយណាដែលមិនស្ថិតក្រោមការថែទាំរបស់ឪពុកម្តាយបង្កើត។ កន្លែងថែទាំជំនួសចំពោះកុមារមានពីរប្រភេទ៖ ការថែទាំតាមមណ្ឌល និងការថែទាំតាមសហគមន៍។ ( និយមន័យការថែទាំតាមមណ្ឌល និងការថែទាំតាមសហគមន៍សូមពិនិត្យមើលគោលនយោបាយថែទាំជំនួសចំពោះកុមារ ឆ្នាំ២០០៦ ) |
| លទ្ធផលរំពឹងទុក | បរិយាកាសប្រកបដោយសុវត្ថិភាពសម្រាប់កុមារចម្រើនវ័យនៅក្នុងកន្លែងថែទាំជំនួស |
| វិធីសាស្ត្រគណនា | ក ) ការថែទាំតាមមណ្ឌល៖ ពិន្ទុ ១៨០-២០២ អនុវត្តស្របតាមបទដ្ឋាន, ពិន្ទុ ១៦០-១៧៩ អនុវត្តមិនស្របតាមបទដ្ឋាន, ពិន្ទុ ០-១៥៩ អនុវត្តក្រោមបទដ្ឋានធ្ងន់ធ្ងរ<br>ខ ) ការថែទាំតាមសហគមន៍៖ អាស្រ័យការដាក់ពិន្ទុទៅតាមប្រភេទនៃកន្លែងថែទាំ ( យោងកម្រងសំណួរនៃការធ្វើអធិការកិច្ច ) |
| ប្រភពទិន្នន័យ | តារាងអធិការកិច្ច ( Inspection dashboard ) |
| កម្រិតភាពញឹកញាប់ | រៀងរាល់ឆ្នាំ/ម្តងក្នុង១ឆ្នាំ |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ខេត្ត , ប្រភេទកន្លែងផ្តល់ការថែទាំកុមារបទដ្ឋានអប្បបរមា លក្ខខ័ណ្ឌផ្សេងៗ មានកិច្ចព្រមព្រៀងគម្រោងដែលមានសុពលភាព និងលិខិតទទួលស្គាល់ពីក្រសួង ស.អ.យ |
| ទីភ្នាក់ងារផ្តល់របាយការណ៍ | MoSVY ( នាយកដ្ឋានសុខុមាលភាពកុមារ ) |
| ឯកសារយោង | |
| កំណត់សម្គាល់ | |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | តំណភ្ជាប់សាធារណៈកំពុងត្រូវបានអភិវឌ្ឍ |

| ឈ្មោះសូចនាករ | ៣.៧. ចំនួននាយកសាលា និងគ្រូបង្រៀនទទួលបានការអភិវឌ្ឍសមត្ថភាព ស្តីពីការអប់រំវិន័យបែបវិជ្ជមាន និងការគ្រប់គ្រងថ្នាក់រៀនមានប្រសិទ្ធភាព |
|---|---|
| និយមន័យ | កម្មវិធីការអប់រំវិន័យបែបវិជ្ជមាន និងការគ្រប់គ្រងថ្នាក់រៀនមានប្រសិទ្ធភាព ត្រូវបានរៀបចំឡើង សម្រាប់នាយកសាលា និងគ្រូបង្រៀន ដែលវាបានអធិប្បាយអំពីបញ្ហាប្រចាំថ្ងៃ ដែលកើតមានឡើងនៅក្នុងសាលារៀន និងមានគោលដៅគាំទ្រការគ្រប់គ្រងសាលារៀន និងថ្នាក់រៀន ដើម្បីទប់ស្កាត់អំពើហិង្សាចំពោះកុមារនៅតាមសាលារៀន ព្រមទាំងលើកកម្ពស់ទំនាក់ទំនងវិជ្ជមាន អហិង្សា និងទំនាក់ទំនងកុមារមេត្រីរវាងគ្រូ និងសិស្ស។<br>កម្មវិធីអប់រំវិន័យបែបវិជ្ជមាន និងការគ្រប់គ្រងថ្នាក់រៀនមានប្រសិទ្ធភាព រួមមាន៖<br>• ការយល់ដឹងអំពីអំពើហិង្សាចំពោះកុមារ និងទណ្ឌកម្មលើរាងកាយ និងផ្នែកស្មារតី ព្រមទាំងផលវិបាកនានា<br>• សាលារៀនបែបណាដែលមានសុវត្ថិភាព<br>• ការការពារកុមារនៅតាមសាលារៀន<br>• ការបង្កើតទំនាក់ទំនងវិជ្ជមានរវាងគ្រូ និងសិស្ស<br>• ការរម្ងាប់កំហឹង<br>• ការដាក់វិន័យបែបវិជ្ជមាន<br>• ការគ្រប់គ្រងថ្នាក់រៀនឱ្យមានប្រសិទ្ធភាព<br>• ការបង្កើតគោលការណ៍សាលារៀន និងថ្នាក់រៀន។<br>(សៀវភៅណែនាំសម្រាប់នាយកសាលា គ្រូបង្រៀន អ្នកសម្របសម្រួល និងសៀវភៅគាំទ្រ ប្រតិបត្តិការអនុវត្តកម្មវិធីសាលាកុមារមេត្រី សមាសភាគទី៣) |
| លទ្ធផលរំពឹងទុក (លទ្ធផលរយៈពេលខ្លី/វែង) | កុមារទទួលបានបរិយាកាសសិក្សារៀនសូត្រក្នុងថ្នាក់ដែលគ្មានអំពើហិង្សា និងលើកទឹកចិត្តឱ្យ លទ្ធផលសិក្សាកាន់តែបានល្អប្រសើរ |
| វិធីសាស្ត្រគណនា | រាប់បុគ្គលគ្រប់រូបដែលបានទទួលការបំប៉ន |
| ប្រភពទិន្នន័យ | កំណត់ហេតុរដ្ឋបាល |
| កម្រិតភាពញឹកញាប់ | រៀងរាល់ឆ្នាំ |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ខេត្ត , ស្រុក, សាលា, ចំនួននាយកសាលា និងគ្រូបង្រៀន ដោយបញ្ជាក់អំពីភេទផងដែរ។ |

| | |
|---|---|
| ទីភ្នាក់ងារផ្តល់របាយការណ៍ | MoEYS |
| ឯកសារយោង | សូចនាករ 3.3a ស្តីពីកិច្ចការពារកុមាររបស់អង្គការយូនីសេហ្វ ,<br>ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ក្រសួងអប់រំ យុវជន និងកីឡា។ |
| កំណត់សម្គាល់ | ដៃគូអភិវឌ្ឍមួយចំនួនក៏យកឯកសារនេះជាគោល ក្នុងការគាំទ្រដល់សាលារៀនផងដែរ។ |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | |

| ឈ្មោះសូចនាករ | ៣.៨. ចំនួនសាលារៀនទទួលបានការផ្សព្វផ្សាយ ដើម្បីអនុវត្តការណែនាំប្រតិបត្តិ ស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀន |
|---|---|
| និយមន័យ | ការណែនាំប្រតិបត្តិ ស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀន មានគោលបំណងឱ្យកុមារគ្រប់រូប ទទួលបានបរិយាកាសរៀនសូត្រដែលជួយដល់ការអភិវឌ្ឍទាំងផ្លូវកាយ ផ្លូវចិត្ត បញ្ញា ស្មារតី ដោយគ្មានអំពើហិង្សា និងការកេងប្រវ័ញ្ចគ្រប់ទម្រង់នៅក្នុងសាលារៀន ដើម្បីក្លាយជាមូលធន មនុស្សសម្រាប់អភិវឌ្ឍប្រទេសប្រកបដោយចីរភាព។ ដូច្នេះ ដើម្បីសម្រេចគោលបំណងនេះ ការណែនាំប្រតិបត្តិមានគោលដៅ៖<br>• ជំរុញការអនុវត្តគោលនយោបាយ និងផែនការសកម្មភាព ស្តីពីកិច្ចការពារកុមារនៅសាលារៀន និងផែនការសកម្មភាពពាក់ព័ន្ធដ៏ទៃទៀតឱ្យមានប្រសិទ្ធភាព<br>• អភិវឌ្ឍប្រព័ន្ធ យន្តការ តួនាទី និងការទទួលខុសត្រូវក្នុងកិច្ចការពារកុមារនិង<br>• សុខុមាលភាពរបស់បុគ្គលិក គ្រូបង្រៀន សិស្សានុសិស្ស អាណាព្យាបាល និងអ្នកពាក់ព័ន្ធ ដោយធានាថាសាលារៀនជាទីកន្លែងដែលកុមារមានសុវត្ថិភាពពីគ្រប់ទម្រង់ នៃអំពើហិង្សា និងការកេងប្រវ័ញ្ចលើកុមារ ជាពិសេសកុមារមានពិការភាព កុមារកំព្រា កុមារមកពីគ្រួសារក្រីក្រ។ល។<br>• ផ្តល់ជាមគ្គុទេសក៍ដល់សាលារៀន ដើម្បីអនុវត្តប្រកបដោយប្រសិទ្ធភាព កិច្ចសហប្រត្តិការ និងសមត្ថភាព លើការបង្ការទប់ស្កាត់ ឆ្លើយតប និងបញ្ជូនកុមារដែលរងប៉ះពាល់ នូវអំពើហិង្សាគ្រប់ទម្រង់ និងការកេងប្រវ័ញ្ច ទៅទទួលសេវាគាំទ្រត្រឹមត្រូវពីយន្តការ កិច្ចការពារកុមារដែលមានស្រាប់នៅសហគមន៍<br>• ផ្សារភ្ជាប់ទំនាក់ទំនង និងកិច្ចសហការកាន់តែមានប្រសិទ្ធភាពនៃយន្តការកិច្ចការពារកុមារនៅក្នុងសាលារៀនជាមួយនឹងយន្តការកិច្ចការពារកុមារនៅក្នុងសហគមន៍។<br>ការណែនាំប្រតិបត្តិ ស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀន ផ្តោតលើចំណុចសំខាន់ៗ ដូចជា៖<br>• វិធីបង្ការអំពើហិង្សា និងការកេងប្រវ័ញ្ចលើកុមារនៅក្នុងសាលារៀន<br>• វិធីឆ្លើយតប និងបញ្ជូនករណីអំពើហិង្សានិងការកេងប្រវ័ញ្ច ដែលរួមមាន យន្តការរាយការណ៍ និងយន្តការឆ្លើយតបនិងបញ្ជូនទៅរកសេវាគាំទ្រ<br>• វិធីឆ្លើយតបបញ្ហាកិច្ចការពារកុមារនៅក្នុងស្ថានភាពគ្រោះមហន្តរាយ និងជំងឺឆ្លង<br>• យន្តការគាំទ្រ និងត្រួតពិនិត្យតាមដានការអនុវត្ត។<br>(សៀវភៅណែនាំប្រតិបត្តិ ស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀន) |
| លទ្ធផលរំពឹងទុក (លទ្ធផលរយៈពេលខ្លី/វែង) | សាលារៀនជាកន្លែងដែលមានសុវត្ថិភាពសម្រាប់កុមារ និងផ្តល់នូវបរិយាកាសរៀនសូត្រដែល គ្មានអំពើហិង្សាគ្រប់ទម្រង់ និងការកេងប្រវ័ញ្ច |
| វិធីសាស្រ្តគណនា | រាប់ចំនួនសាលារៀន និងចំនួនបុគ្គលគ្រប់រូបដែលបានទទួលការបំប៉ន |

| | |
|---|---|
| ប្រភពទិន្នន័យ | កំណត់ហេតុរដ្ឋបាល |
| កម្រិតភាពញឹកញាប់ | រៀងរាល់ឆ្នាំ |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ចំនួនសាលា, ចំនួននាយកសាលា គ្រូបង្រៀន គណៈកម្មការគ្រប់គ្រងសាលា ដោយបញ្ជាក់អំពីភេទផងដែរ បែងចែកតាមខេត្ត ស្រុក |
| ទីភ្នាក់ងារផ្តល់របាយការណ៍ | MoEYS |
| ឯកសារយោង | សូចនាករ 3.3a ស្តីពីកិច្ចការពារកុមាររបស់អង្គការយូនីសេហ្វ ,<br>ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ក្រសួងអប់រំ យុវជន និងកីឡា។ |
| កំណត់សម្គាល់ | សេចក្តីព្រាងសៀវភៅណែនាំប្រតិបត្តិត្រូវបានរៀបចំក្នុងឆ្នាំ២០២០, អនុវត្តសាកល្បងឆ្នាំ២០២១, និងចាប់ផ្តើមអនុវត្តចាប់ពីឆ្នាំ២០២២ |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | |

# វិស័យទី៤៖ សេវាឆ្លើយតប និងគាំទ្រចំពោះកិច្ចការពារកុមារ

| ឈ្មោះសូចនាករ | ៤.១. ភាគរយនៃកុមារអាយុចន្លោះពី ១៣-១៧ឆ្នាំ ដែលបានស្វែងរកជំនួយពីស្ថាប័ន ឬ ពីអ្នកវិជ្ជាជីវៈ សម្រាប់ការទទួលរងអំពើហិង្សាផ្លូវកាយ ឬផ្លូវភេទ (ឥរិយាបថស្វែងរកជំនួយក្នុងវ័យកុមារ)<br>(ទិន្នន័យមានក្នុងCDHS: ភាគរយនៃស្ត្រីអាយុចន្លោះពី ១៥-៤៩ឆ្នាំ ដែលធ្លាប់ទទួលរងអំពើហិង្សាផ្លូវកាយ ឬផ្លូវភេទ ទៅតាមឥរិយាបថស្វែងរកជំនួយ បែងចែកតាមប្រភេទអំពើហិង្សា និងសាវតា) |
|---|---|
| និយមន័យ | ប្រភេទស្ថាប័ន ឬ អ្នកប្រកបអាជីពវិជ្ជាជីវៈ គប្បីសម្របទៅតាមបរិបទរបស់ប្រទេស ប៉ុន្តែវាអាចរួមមាន៖ (១) នគរបាល (២) អ្នកវិជ្ជាជីវៈផ្នែកវេជ្ជសាស្ត្រ (៣) មេធាវី ឬ សេវាជំនួយផ្នែកច្បាប់ (៤) សេវាផ្តល់ប្រឹក្សា ឬ សេវាសង្គមដទៃទៀត (៥) មេដឹកនាំសាសនា (៦) បណ្តាញទូរស័ព្ទទាន់ហេតុការណ៍ និង (៧) ផ្សេងៗ (INSPIRE)។ |
| លទ្ធផលរំពឹងទុក (លទ្ធផលរយៈពេលវែង) | គុណភាព និងការគ្រប់ដណ្តប់នៃយន្តការរាយការណ៍ សេវាឆ្លើយតប និងការបង្ការអំពើហិង្សាលើកុមារក្នុងគ្រប់វិស័យ ត្រូវបានពង្រឹង។ ការបង្កើនឥរិយាបថស្វែងរកជំនួយគឺជាជំហានមួយនៅក្នុងកិច្ចខិតខំកែលម្អលទ្ធភាពទទួលបានសេវាសម្រាប់បញ្ហាអំពើហិង្សា និងប្រុកស៊ី (proxy) សម្រាប់ទំនុកចិត្តទៅលើគុណភាព និងការឆ្លើយតបរបស់សេវា ដែលជាលទ្ធផលរំពឹងទុកមួយនៃកញ្ចប់ INSPIRE។ |
| វិធីសាស្ត្រគណនា | ភាគយក៖ ចំនួនក្មេងជំទង់ស្រី និងប្រុស អាយុ ១៣-១៧ឆ្នាំ ដែលបានស្វែងរកជំនួយពីស្ថាប័ន ឬ អ្នកប្រកបអាជីពវិជ្ជាជីវៈ សម្រាប់បញ្ហាអំពើហិង្សាលើរាងកាយ ឬផ្លូវភេទ។<br>ភាគបែង៖ ចំនួនសរុបនៃក្មេងជំទង់ស្រី និងប្រុស អាយុ ១៣-១៧ឆ្នាំ ដែលបានរាយការណ៍ថាធ្លាប់ទទួលរងអំពើហិង្សាផ្លូវកាយ ឬផ្លូវភេទ។<br>មេគុណ៖ ១០០ |
| ប្រភពទិន្នន័យ | CDHS |
| កម្រិតភាពញឹកញាប់ | ៣-៥ឆ្នាំ |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ភេទ និងអាយុ |

| | |
|---|---|
| ទីភ្នាក់ងារទទួលខុសត្រូវរាយការណ៍អំពីទិន្នន័យ | MoP/NIS |
| ឯកសារយោង | សូចនាករ Inspire ៨.៤ (ការស្វែងរកជំនួយសម្រាប់អំពើហិង្សាផ្លូវកាយក្នុងវ័យកុមារនៅពេលណាមួយក្នុងជីវិត) |
| កំណត់សម្គាល់ | ទិន្នន័យមានក្នុងCDHS: ភាគរយនៃស្ត្រីអាយុចន្លោះពី ១៥-៤៩ឆ្នាំ ដែលធ្លាប់ទទួលរងអំពើហិង្សាផ្លូវកាយ ឬផ្លូវភេទ ទៅតាមឥរិយាបថស្វែងរកជំនួយ បែងចែកតាមប្រភេទអំពើហិង្សា និងសារវតា |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | ទិន្នន័យអំពីការស្វែងរកជំនួយសម្រាប់អំពើហិង្សាផ្លូវភេទ ដោយកុមារី និងកុមារា ពីជាង ៤០ប្រទេស អាចរកបានពីអង្គការយូនីសេហ្វ (https://data.unicef.org)។ ទិន្នន័យ VACS អំពីការស្វែងរកជំនួយសម្រាប់អំពើហិង្សាផ្លូវកាយ និងផ្លូវភេទ អាចរកបានពីជាង ៨ប្រទេស។ (www.cdc.gov/violenceprevention/childabuseandneglect/vacs/index.html). |

| ឈ្មោះសូចនាករ | ៤.២ ភាគរយ នៃចំនួនកុមារី និងកុមារាអាយុក្រោម១៨ឆ្នាំ ដែលមានទំនាក់ទំនងជាមួយប្រព័ន្ធយុត្តិធម៌ និងអាជ្ញាធររដ្ឋបាលក្នុងឆ្នាំកន្លងទៅ ដែលបានទទួល ក)កិច្ចគាំទ្រឯកទេស ខ)កិច្ចគាំទ្រពី ការបង្វែរការជាប់ឃុំ ឬស្តារឡើងវិញ ជំនួសឱ្យការឃុំខ្លួន |
|---|---|
| និយមន័យ | ចំនួនកុមារី និងកុមារាអាយុក្រោម១៨ឆ្នាំ ដែលមានទំនាក់ទំនងជាមួយប្រព័ន្ធយុត្តិធម៌ ក្នុងរយៈពេលមួយឆ្នាំប្រតិទិនចុងក្រោយ ដែលបានទទួលកិច្ចគាំទ្រឯកទេស ដោយបង្ហាញតាមរយៈភាគរយនៃកុមារគ្រប់រូបអាយុក្រោម១៨ឆ្នាំ ដែលមានទំនាក់ទំនងជាមួយប្រព័ន្ធយុត្តិធម៌ ក្នុងអំឡុងឆ្នាំដូចគ្នានេះ។<br>កុមារមានទំនាក់ទំនងជាមួយប្រព័ន្ធយុត្តិធម៌ រួមមានកុមារី និងកុមារា អាយុ ០-១៧ឆ្នាំ ដែលជាជនរងគ្រោះនៃអំពើឧក្រិដ្ឋកម្ម សាក្សីនៃឧក្រិដ្ឋកម្ម និង/ឬ មានទំនាស់នឹងច្បាប់។<br>សេវាគាំទ្រឯកទេសអាចរួមមាន ជំនួយផ្នែកច្បាប់ កិច្ចគាំទ្រផ្នែកចិត្ត និងសង្គម ដូចមានគូសបញ្ជាក់នៅក្នុងយុទ្ធសាស្ត្រគំរូរបស់អង្គការសហប្រជាជាតិ និងសេវាបង្វែរ ការស៊ើបអង្កេតបែបកុមារមេត្រី នីតិវិធីជំនុំជម្រះ និងកាត់ទោសដោយនគរបាល ព្រះរាជអាជ្ញា មេធាវីការពារ និងចៅក្រម រួមទាំងការប្រើប្រាស់តុលាការឯកទេស និង វិធានការការពារពិសេសសម្រាប់កុមាររងគ្រោះ និងសាក្សី។ |
| លទ្ធផលរំពឹងទុក (លទ្ធផលរយៈពេលវែង) | គុណភាព និងការគ្រប់ដណ្តប់នៃយន្តការរាយការណ៍ សេវាឆ្លើយតប និងការបង្ការអំពើហិង្សាលើកុមារក្នុងគ្រប់វិស័យ ត្រូវបានពង្រឹង។ បង្កើនលទ្ធភាពរបស់កុមារក្នុងការទទួលបានសេវាគាំទ្រក្នុងគ្រប់ស្ថានភាពទាំងអស់។ |
| វិធីសាស្ត្រគណនា | ភាគយក៖ ចំនួនកុមារដែលបានទទួលកិច្ចគាំទ្រឯកទេស ក្នុងឆ្នាំប្រតិទិនកន្លងទៅ (ការប្រើប្រាស់ការបង្វែរ ជំនួយផ្នែកច្បាប់ និងនីតិវិធីកុមារមេត្រីដទៃទៀត និងកិច្ចគាំទ្រសង្គម)<br>ភាគបែង៖ ចំនួនកុមារសរុបដែលមានទំនាក់ទំនងជាមួយប្រព័ន្ធយុត្តិធម៌ ក្នុងឆ្នាំប្រតិទិនកន្លងទៅ (ជនរងគ្រោះនៃឧក្រិដ្ឋកម្ម + សាក្សីនៃឧក្រិដ្ឋកម្ម + កុមារដែលត្រូវបានអះអាងចោទប្រកាន់ ឬ ត្រូវបានទទួលស្គាល់ថាបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ក្នុងឆ្នាំដដែលនេះ)<br>មេគុណ៖ ១០០<br>ឬអាចរាយការណ៍ជាចំនួនកុមារដែលបានទទួលកិច្ចគាំទ្រឯកទេស (ជាជាងការគិតជាភាគរយ) |
| ប្រភពទិន្នន័យ | កំណត់ហេតុរដ្ឋបាល<br>ប្រព័ន្ធទិន្នន័យតុលាការដែលកត់ត្រាបញ្ចូលចំនួនកុមារាកុមារីក្រោមអាយុ១៨ឆ្នាំ |
| កម្រិតភាពញឹកញាប់ | រៀងរាល់ឆ្នាំ |

| | |
|---|---|
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ទៅតាមភេទ អាយុ ប្រភេទនៃការមានទំនាក់ទំនងជាមួយច្បាប់ (ជនរងគ្រោះ សាក្សី មានទំនាស់នឹងច្បាប់) ប្រភេទសេវាឯកទេស (ជំនួយផ្នែកច្បាប់ កិច្ចគាំទ្រចិត្តសាស្ត្រ។ល។) |
| ទីភ្នាក់ងារទទួលខុសត្រូវរាយការណ៍អំពីទិន្នន័យ | MoJ (នាយកដ្ឋានកិច្ចការរដ្ឋបាលនៃសាលាជម្រះក្តី) |
| ឯកសារយោង | សូចនាករ Inspire ៨.៨<br>សូចនាករស្តីពីកិច្ចការពារកុមាររបស់អង្គការយូនីសេហ្វ ៣.៦a/b |
| កំណត់សម្គាល់ | |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | |

| ឈ្មោះសូចនាករ | ៤.៣ ចំនួនជនល្មើសដែលត្រូវបានចាប់ខ្លួន និងបញ្ជូនទៅតុលាការ ពីបទល្មើសលើកុមារ ( ពាក់ព័ន្ធករណីជួញដូរមនុស្ស អាជីវកម្មផ្លូវភេទ និងរំលោភសេពសន្ថវៈលើកុមារ ) |
|---|---|
| និយមន័យ | បទល្មើសរួមមានជួញដូរមនុស្ស អាជីវកម្មផ្លូវភេទ និងរំលោភសេពសន្ថវៈ លើកុមារ និងបទឧក្រិដ្ឋកម្មផ្សេងៗ ដូចជាឃាតកម្ម ឃាតកម្មដោយចេតនា រំលោភបំពានដោយចេតនា ការសំលាប់ ការរំលោភធ្ងន់ធ្ងរ និងអាសអាភាសកុមារ។ |
| លទ្ធផលរំពឹងទុក ( លទ្ធផលរយៈពេលវែង ) | គណនេយ្យភាពត្រូវបានពង្រឹង |
| វិធីសាស្ត្រគណនា | ចំនួនសរុប |
| ប្រភពទិន្នន័យ | ទិន្នន័យរបស់អគ្គស្នងការនគរបាលជាតិ នាយកដ្ឋានប្រឆាំង ការជួញដូរមនុស្ស និងការពារអនីតិជន |
| កម្រិតភាពញឹកញាប់ | រៀងរាល់ឆ្នាំ |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ទៅតាមភេទ អាយុ ប្រភេទបទល្មើស |
| ទីភ្នាក់ងារទទួលខុសត្រូវរាយការណ៍អំពីទិន្នន័យ | MoI-អគ្គស្នងការ នគរបាលជាតិ និងនាយកដ្ឋានព្រហ្មទណ្ឌ និងប្រព័ន្ធគ្រប់គ្រងទិន្នន័យនៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន( DAHTJPDBMS ) |
| ឯកសារយោង | |
| កំណត់សម្គាល់ | |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | មានកម្រិត |

| ឈ្មោះសូចនាករ | ៤.៤ ចំនួនបុគ្គលដែលត្រូវបានកាត់ទោសពីបទល្មើសលើកុមារ |
|---|---|
| និយមន័យ | ប្រភេទបទល្មើសដែលមានក្នុងរបាយការណ៍ក្រសួងយុត្តិធម៌មានដូចជា៖<br>• លក់ ដូរមនុស្ស<br>• ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច<br>• នាំយកចេញដោយមិនស្របច្បាប់<br>• រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ<br>• រំលោភសេពសន្ថវៈ<br>• ហិង្សាក្នុងគ្រួសារ<br>• បង្ករបួសស្នាម<br>• ឃាតកម្ម<br>• ប្រទូសកេរខ្មាស |
| លទ្ធផលរំពឹងទុក (លទ្ធផលរយៈពេលវែង) | គណនេយ្យភាពត្រូវបានពង្រឹង |
| វិធីសាស្ត្រគណនា | ចំនួនសរុប |
| ប្រភពទិន្នន័យ | កំណត់ហេតុរដ្ឋបាលក្រសួងយុត្តិធម៌ |
| កម្រិតភាពញឹកញាប់ | រៀងរាល់ឆ្នាំ |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ទៅតាមភេទ អាយុ ប្រភេទបទល្មើស |
| ទីភ្នាក់ងារទទួលខុសត្រូវរាយការណ៍អំពីទិន្នន័យ | MoJ (នាយកដ្ឋានកិច្ចការរដ្ឋបាលនៃសាលាជម្រះក្តី) |
| ឯកសារយោង | |
| កំណត់សម្គាល់ | |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | មានកម្រិត |

| ឈ្មោះសូចនាករ | ៤.៥. ចំនួនកុមារកំពុងរស់នៅកន្លែងថែទាំកុមារ |
|---|---|
| និយមន័យ | ចំនួនកុមារកំពុងរស់នៅក្នុងប្រភេទនៃការថែទាំដូចខាងក្រោម។<br>**កន្លែងថែទាំកុមារ**<br>• មណ្ឌលថែទាំកុមារ<br>• វត្តអារាម និងកន្លែងសាសនាដែលផ្តល់ការថែទាំ<br>• ផ្ទះស្នាក់នៅជាក្រុម<br>• ផ្ទះស្នាក់នៅបណ្តោះអាសន្ន/ផ្ទះសំចត<br>• អន្តេវាសិកដ្ឋាន |
| លទ្ធផលរំពឹងទុក ( លទ្ធផលរយៈពេលវែង ) | សេវាសម្រាប់កុមារដែលគ្មានការថែទាំពីឪពុកម្តាយត្រូវបានពង្រឹង |
| វិធីសាស្ត្រគណនា | ចំនួនសរុប |
| ប្រភពទិន្នន័យ | ប្រព័ន្ធអធិការកិច្ច កន្លែងថែទាំជំនួស |
| កម្រិតភាពញឹកញាប់ | រៀងរាល់ឆ្នាំ/ម្តងក្នុង១ឆ្នាំ |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ប្រភេទអ្នកផ្តល់សេវា ភេទ ពិការភាព ផ្ទុកមេរោគអេដស៍ ឬជំងឺអេដស៍ អាយុ ខេត្ត មានឪពុកឬម្តាយ ចំនួនកុមារដែលបានទទួលការគ្រប់គ្រងករណី កុមារដែលទើបចូលក្នុងឆ្នាំមុន កុមារសមាហរណកម្មទៅសហគមន៍ឬគ្រួសារ កុមារចេញពីមណ្ឌលដោយខ្លួនឯង កុមារមិនចុះឈ្មោះចូលរៀន ឬវគ្គបណ្តុះបណ្តាល |
| ទីភ្នាក់ងារផ្តល់របាយការណ៍ | MoSVY ( នាយកដ្ឋានសុខុមាលភាពកុមារ ) |
| ឯកសារយោង | របាយការណ៍អធិការកិច្ច |
| កំណត់សម្គាល់ | |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | |

| ឈ្មោះសូចនាករ | ៤.៦ ចំនួនកុមារស្ថិតក្រោមការថែទាំតាមគ្រួសារក្នុងប្រទេស (គ្រួសារសាច់ញាតិជាផ្លូវការ និងគ្រួសារធម៌) |
|---|---|
| និយមន័យ | ការថែទាំដោយសាច់ញាតិ ៖ ការថែទាំតាមគ្រួសារសាច់ញាតិរបស់កុមារមានលក្ខណៈផ្លូវការ។<br>ការថែទាំដោយឪពុកម្តាយធម៌ ៖ ស្ថានភាពដែលកុមារត្រូវបានអាជ្ញាធរមានសមត្ថកិច្ចមួយធ្វើការទុកដាក់ សម្រាប់គោលបំណងថែទាំជំនួសនៅក្នុងបរិយាកាសគ្រួសារមួយដែលមិនមែនជាគ្រួសារបង្កើតរបស់កុមារ ដោយគ្រួសារនោះត្រូវបានជ្រើសរើសមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ បានទទួលការអនុម័តយល់ព្រម និងស្ថិតក្រោមការត្រួតពិនិត្យសម្រាប់ការផ្តល់ការថែទាំបែបនេះ។ |
| លទ្ធផលរំពឹងទុក (លទ្ធផលរយៈពេលវែង) | សេវាសម្រាប់កុមារដែលគ្មានការថែទាំពីឪពុកម្តាយត្រូវបានពង្រឹង |
| វិធីសាស្ត្រគណនា | ចំនួនសរុប |
| ប្រភពទិន្នន័យ | កំណត់ហេតុរដ្ឋបាល |
| កម្រិតភាពញឹកញាប់ | ត្រីមាស ឆមាស ប្រចាំឆ្នាំ |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ប្រភេទអ្នកផ្តល់សេវា ទំហំនៃអ្នកផ្តល់សេវា រយៈពេលស្ថិតក្រោមការថែទាំ ភេទ ពិការភាពចំនួនកុមារដែលបានទទួលការគ្រប់គ្រងករណី |
| ទីភ្នាក់ងារផ្តល់របាយការណ៍ | MoSVY (នាយកដ្ឋានសុខុមាលភាពកុមារ) |
| ឯកសារយោង | |
| កំណត់សម្គាល់ | |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | |

| ឈ្មោះសូចនាករ | ៤.៧ ភាគរយនៃកុមារស្ថិតក្រោមការថែទាំពីគ្រួសារសាច់ញាតិជាផ្លូវការ និងក្រៅផ្លូវការ ឬគ្រួសារធម៌ ដែលរកឃើញតាមការអង្កេត |
|---|---|
| និយមន័យ | ការថែទាំដោយសាច់ញាតិ ៖ ការថែទាំតាមគ្រួសារសាច់ញាតិរបស់កុមារ ឬជាមួយមិត្តភក្តិជិតស្និទ្ធរបស់គ្រួសារដែលកុមារស្គាល់ មានលក្ខណៈផ្លូវការ។<br>ការថែទាំដោយឪពុកម្តាយធម៌ ៖ ស្ថានភាពដែលកុមារត្រូវបានអាជ្ញាធរមានសមត្ថកិច្ចមួយធ្វើការទុកដាក់ សម្រាប់គោលបំណងថែទាំជំនួសនៅក្នុងបរិយាកាសគ្រួសារមួយ ដែលមិនមែនជាគ្រួសារបង្កើតរបស់កុមារ ដោយគ្រួសារនោះត្រូវបានជ្រើសរើស មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ បានទទួលការអនុម័តយល់ព្រម និងស្ថិតក្រោមការត្រួតពិនិត្យសម្រាប់ការផ្តល់ការថែទាំបែបនេះ។ បរិបទកម្ពុជា រួមមានកុមារដែលរស់នៅជាមួយគ្រួសារសាច់ញាតិ ដោយមិនផ្លូវការ។ |
| លទ្ធផលរំពឹងទុក (លទ្ធផលរយៈពេលវែង) | សេវាសម្រាប់កុមារដែលគ្មានការថែទាំពីឪពុកម្តាយត្រូវបានពង្រឹង |
| វិធីសាស្រ្តគណនា | ភាគយក: ចំនួនកុមារស្ថិតក្រោមការថែទាំពីគ្រួសារសាច់ញាតិ និងជាផ្លូវការ<br>ភាគបែង: ចំនួនកុមារសរុប<br>មេគុណ: ១០០ |
| ប្រភពទិន្នន័យ | CDHS |
| កម្រិតភាពញឹកញាប់ | រៀងរាល់ឆ្នាំ |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ភេទ អាយុ ខេត្ត |
| ទីភ្នាក់ងារផ្តល់របាយការណ៍ | MoP/NIS |
| ឯកសារយោង | |
| កំណត់សម្គាល់ | និយមន័យការថែទាំតាមគ្រួសារធម៌ក្នុងCDHS មិនទាន់បន្ស៊ីគ្នាទៅនឹងនិយមន័យអន្តរជាតិនៅឡើយ |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | |

| ឈ្មោះសូចនាករ | ៤.៨ ចំនួនកុមារដែលបានបង្រួបបង្រួមគ្រួសារ ឬ ទុកដាក់ជាមួយគ្រួសារសាច់ញាតិ គ្រួសារធម៌ ឬសហគមន៍ |
|---|---|
| និយមន័យ | ចំនួនកុមាររស់នៅក្នុងមណ្ឌល (មណ្ឌលថែទាំកុមារ ផ្ទះស្នាក់នៅជាក្រុម វត្តអារាម និងកន្លែងសាសនាដទៃទៀតដែលផ្តល់ការថែទាំតាមមណ្ឌល និងផ្ទះសំចត) ដែលត្រូវបានផ្តល់ការបង្រួបបង្រួមគ្រួសារ ឬ ការទុកដាក់ថែទាំជំនួសប្រភេទដទៃទៀត ដូចជាការថែទាំដោយញាតិ ការថែទាំដោយឪពុកម្តាយធម៌ ការរស់នៅឯករាជ្យ។<br>ការបង្រួបបង្រួមគ្រួសារៈ ការបង្រួបបង្រួមកុមារជាមួយនឹងគ្រួសាររបស់កុមារ ឬ អ្នកថែទាំកុមារកាលពីមុន ក្នុងគោលបំណងធ្វើឱ្យការទុកដាក់នេះមានភាពអចិន្ត្រៃយ៍។ |
| លទ្ធផលរំពឹងទុក (លទ្ធផលរយៈពេលវែង) | កុមារបានរស់នៅជាមួយគ្រួសារបង្កើត ឬគ្រួសារសាច់ញាតិ |
| វិធីសាស្រ្តគណនា | ចំនួនសរុប |
| ប្រភពទិន្នន័យ | Primero , OSCaR |
| កម្រិតភាពញឹកញាប់ | រៀងរាល់ឆ្នាំ |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ភេទ អាយុ ប្រភេទនៃការទុកដាក់ ខេត្ត |
| ទីភ្នាក់ងារផ្តល់របាយការណ៍ | MoSVY (នាយកដ្ឋានសុខុមាលភាពកុមារ), Save the Children/FCF, React |
| ឯកសារយោង | |
| កំណត់សម្គាល់ | |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | |

| ឈ្មោះសូចនាករ | ៤.៩ ចំនួនកុមារដែលត្រូវបានស្វែងរកគ្រួសារល្អសម្រាប់សុំកូនក្នុងប្រទេស |
|---|---|
| និយមន័យ | ចំនួនកុមារទាំងអស់ដែលត្រូវបានទុកដាក់ជាមួយគ្រួសារចិញ្ចឹមក្នុងស្រុក សុំកូនជាទូទៅសំដៅលើការផ្ទេរសិទ្ធិនិងទំនួលខុសត្រូវជាអាណាព្យាបាលតាមផ្លូវច្បាប់ ជូនអ្នកទទួលយកកុមារទៅចិញ្ចឹម (IAG UASC, ២០០៤). |
| លទ្ធផលរំពឹងទុក (លទ្ធផល រយៈពេលវែង) | ទុកដាក់កុមារជាអចិន្ត្រៃយ៍ជាមួយគ្រួសារនៅក្នុងប្រទេស បន្ទាប់ពីការស្វែងរកអស់លទ្ធភាពនៃការទុកដាក់កុមារជាមួយគ្រួសារបង្កើត |
| វិធីសាស្ត្រគណនា | ចំនួនសរុបនៃកុមារដែលត្រូវបានទុកដាក់ជាមួយគ្រួសារចិញ្ចឹមក្នុងស្រុក |
| ប្រភពទិន្នន័យ | កំណត់ហេតុរដ្ឋបាល |
| កម្រិតភាពញឹកញាប់ | រៀងរាល់ឆ្នាំ |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ភេទ អាយុ ប្រភេទនៃកុមារ (មានគ្រួសារ ឬត្រូវបានបោះបង់ សុខភាព កុមារមានតម្រូវការពិសេស ស្ថានភាពកុមារ( សង្គម ច្បាប់ សុខភាព) បិទករណី( កុមារឈានចូល ១៨ឆ្នាំ ឬស្លាប់) |
| ទីភ្នាក់ងារផ្តល់របាយការណ៍ | MoSVY/នាយកដ្ឋានសុខុមាលភាពកុមារ |
| ឯកសារយោង | |
| កំណត់សម្គាល់ | |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | |

| ឈ្មោះសូចនាករ | ៤.១០. ចំនួនកុមារដែលត្រូវបានស្វែងរកគ្រួសារល្អសម្រាប់សុំកូនអន្តរប្រទេស |
|---|---|
| និយមន័យ | ចំនួនកុមារដែលត្រូវបានទុកដាក់ជាអចិន្ត្រៃយ៍នៅក្នុងប្រទេសមួយផ្សេងទៀត ដើម្បីយក ទៅចិញ្ចឹមជាកូនដែលទទួលស្គាល់ដោយច្បាប់នៃប្រទេសនោះ តាមរយៈសុំកូនអន្តរប្រទេស |
| លទ្ធផលរំពឹងទុក (លទ្ធផលរយៈពេលវែង) | កុមារទទួលបានគ្រួសារល្អជា អចិន្ត្រៃយ៍នៅក្រៅប្រទេស ក្រោយពីស្វែងរកអស់លទ្ធភាពផ្តល់ការឧបត្ថម្ភគាំទ្រក្នុងគ្រួសារកំណើត និងក្រោយពីបានធ្វើការពិចារណាអំពីសុំកូននៅក្នុងប្រទេស |
| វិធីសាស្ត្រគណនា | សរុបចំនួនកុមារដែលត្រូវបានទុកដាក់តាមរយៈសុំកូនអន្តរប្រទេស |
| ប្រភពទិន្នន័យ | កំណត់ហេតុរដ្ឋបាល |
| កម្រិតភាពញឹកញាប់ | រៀងរាល់ឆ្នាំ |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | តាមភេទ, អាយុ, ប្រភេទកុមារ(មានគ្រួសារ និងកុមារត្រូវបានបោះបង់), ប្រភេទនៃការសុំកូន(ធម្មតា សាច់ញាតិ និងតម្រូវការពិសេស), ស្ថានភាពកុមារ(សង្គម, ច្បាប់ និងសុខភាព), តាមប្រទេស, បិទករណី(កុមារឈានចូល១៨ឆ្នាំ ឬស្លាប់) |
| ទីភ្នាក់ងារផ្តល់របាយការណ៍ | ក្រសួងសអយ-រដ្ឋបាលសុំកូនអន្តរប្រទេស |
| ឯកសារយោង | គោលនយោបាយថែទាំជំនួស, ច្បាប់សុំកូនអន្តរប្រទេស |
| កំណត់សម្គាល់ | បញ្ជីឈ្មោះកុមារដែលត្រូវបានស្វែងរកគ្រួសារក្នុងស្រុកអស់លទ្ធផល |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | |

| ឈ្មោះសូចនាករ | ៤.១១ ចំនួនកុមារដែលមានទំនាក់ទំនងជាមួយប្រព័ន្ធកិច្ចការពារកុមារបានទទួលសេវាកិច្ចការពារកុមារ និង/ឬសេវាសង្គម |
|---|---|
| និយមន័យ | សំដៅដល់ចំនួនកុមារដែលមានបញ្ហាកិច្ចការពារកុមារទទួលបានសេវាផ្សេងៗ ពីសំណាក់ស្ថាប័នរដ្ឋ ឬអង្គការមិនមែនរដ្ឋាភិបាល។ កុមារទាំងនោះមានដូចជា៖<br>• កុមារទទួលបានសេវាគ្រប់គ្រងករណីនៅក្នុងកំណត់ត្រាប្រព័ន្ធ Primero<br>• កុមារអនាថាទទួលបានសេវាគាំពារ (សេវាប្រឹក្សា និងសេវាសមាហរណកម្ម)<br>• ចំនួនអនីតិជនទំនាស់នឹងច្បាប់ទទួលបានសេវា (ស្តារនីតិសម្បទា សមាហរណកម្មបង្វែរទៅសហគមន៍)<br>• កុមាររងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ទទួលបានសេវា<br>(សេវាគាំពារ សេវាស្តារនីតិសម្បទា សេវាសមាហរណកម្មទៅសហគមន៍)<br>• កុមារទទួលបានសេវាយុត្តិធម៌<br>• កុមាររស់រានមានជីវិតពីគ្រោះថ្នាក់ដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម ទទួលសេវាគាំទ្រ (សេវាថែទាំផ្នែកវេជ្ជសាស្ត្រ ផ្លូវចិត្ត និងស្តារលទ្ធភាពពលកម្មកាយសម្បទា)<br>• កុមាររងគ្រោះដោយអំពើហិង្សាទទួលបានសេវាព្យាបាល<br>• កុមារទទួលបានសេវាសង្គមពីបណ្តាញអង្គការ ៣PC<br>• កុមារទទួលបានសេវាតាមរយៈបណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា<br>• ចំនួនកុមារពិការទទួលបានសេវាស្តារ |

សេវារួមមាន៖

- ការស៊ើបអង្កេតករណី និងការអន្តរាគមន៍ ឬការផ្ទេរករណី
- ការគ្រប់គ្រងករណី៖ ដំណើរការជួយដល់កុមារ និង គ្រួសារនីមួយៗ តាមរយៈកិច្ចគាំទ្រការងារសង្គមកិច្ច និងការគ្រប់គ្រងព័ត៌មាន។ ការគ្រប់គ្រងករណី គឺជាវិធីមួយសម្រាប់រៀបចំ និងអនុវត្តការងារ ដើម្បីដោះស្រាយបញ្ហាសេចក្តីត្រូវការរបស់កុមារនីមួយៗ (និងគ្រួសាររបស់ពួកគេ) ក្នុងលក្ខណៈមួយដែលសមស្រប មានលក្ខណៈជាប្រព័ន្ធ និងទាន់ពេលវេលា តាមរយៈ កិច្ចគាំទ្រដោយផ្ទាល់ និង/ឬ ការបញ្ជូន និងស្របតាមគោលបំណងរបស់គម្រោង ឬ កម្មវិធីមួយ។ ដំណើរការនេះគប្បីផ្តោតលើសេចក្តីត្រូវការរបស់កុមារ និងគ្រួសាររបស់ពួកគេ ដោយធានាថាបញ្ហាកង្វល់នានាត្រូវបានដោះស្រាយជាប្រព័ន្ធ ដោយពិចារណាអំពី ឧត្តមប្រយោជន៍របស់កុមារ និងការបំពេញបន្ថែមទៅលើភាពធន់ (Resilience) ពីធម្មជាតិរបស់កុមារ និងគ្រួសារ។ ដំណើរការនេះគប្បីផ្តល់ជូនស្របតាមដំណើរការគ្រប់គ្រងករណីដែលត្រូវបានបង្កើតឡើង ដោយករណីនីមួយៗ មានការចូលរួមប្រកបដោយអត្ថន័យពីកុមារ តាមរយៈជំហានមួយចំនួន និងការផ្តល់អំណាចដល់គ្រួសារនៅក្នុងដំណើរការទាំងមូល។ សេវាគ្រប់គ្រងករណី ត្រូវបានផ្តល់ជូនដោយបុគ្គលិកម្នាក់ (ជាបុគ្គលិកទទួលបន្ទុកករណី ឬគ្រប់គ្រងករណី) ដែលទទួលខុសត្រូវចំពោះការធានាថាសេចក្តីសម្រេចចិត្ត ត្រូវបានធ្វើឡើងដើម្បីឧត្តមប្រយោជន៍របស់កុមារ ហើយករណីត្រូវបានគ្រប់គ្រងស្របតាមដំណើរការ និងតើនរណាជាអ្នកទទួលខុសត្រូវសម្របសម្រួលសកម្មភាពរបស់អ្នកពាក់ព័ន្ធទាំងអស់ (គោលការណ៍ណែនាំអន្តរទីភ្នាក់ងារសម្រាប់ការគ្រប់គ្រងករណី និងកិច្ចការពារកុមារ ឆ្នាំ២០១៤)។
- សេវាសុខាភិបាល៖ មានដូចជាការព្យាបាលរបួសសម្រាប់ជនរងគ្រោះដោយអំពើហិង្សា ការថែទាំវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់ សម្រាប់របួសទាក់ទងនឹង ការផ្តល់សេវាគាំទ្រផ្លូវចិត្ត និងសេវាផ្សេងៗ ព្យាបាលរបួសសម្រាប់ជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ ការព្យាបាលបង្ការមេរោគអេដស៍ និងកាមរោគក្រោយពេលប្រឈម ក្នុងករណីរំលោភផ្លូវភេទ នៅពេលមានការបញ្ជាក់យ៉ាងដូច្នេះ) ត្រូវតែមាន មុនពេលពិចារណាផ្តល់ប្រឹក្សាឯកទេស និងសេវាសង្គម។
- សេវាស្តារលទ្ធភាពពលកម្ម
- ការងារសង្គម (វិស័យសុខុមាលភាពសង្គម) ៖ កងកម្លាំងសេវាសង្គមនៅក្នុងកិច្ចការពារកុមារ ត្រូវបានកំណត់ថាជាបុគ្គលិកជាច្រើនប្រភេទផ្សេងៗគ្នា ទាំងផ្លូវការ និងមិនផ្លូវការ ទទួលបានបៀវត្សរ៍ និងមិនទទួលបានបៀវត្សរ៍ ជាអ្នកមានវិជ្ជាជីវៈ និងអ្នកមានពាក់កណ្តាលវិជ្ជាជីវៈ ពីខាងស្ថាប័នរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល ដែលធ្វើឱ្យប្រព័ន្ធសេវាសង្គមដំណើរការ និងរួមចំណែកដល់ការថែទាំ ការគាំទ្រ និងកិច្ចការពារកុមារ។ នៅកម្រិតមីក្រូ សមាជិកកម្លាំងការងារសេវាសង្គម ឧ. បុគ្គលិកថែទាំកុមារ និងយុវជន ឬ បុគ្គលិកសង្គមកិច្ច សេវាសង្គម (វិស័យសុខុមាលភាពសង្គម)៖ ផ្តល់កិច្ចគាំទ្រដោយផ្ទាល់ដល់

| | |
|---|---|
| | កុមាររងាយរងគ្រោះ និងរងគ្រោះ។ ការងារនេះគ្របដណ្តប់ទៅលើការកំណត់អត្តសញ្ញាណ ការគ្រប់គ្រងករណី ការផ្តល់ប្រឹក្សា ការបញ្ជូន ការសម្របសម្រួលផ្តល់សេវាសំខាន់ៗមួយចំនួន និងការតាមដានករណីអំពើហិង្សា ការរំលោភបំពាន និងការកេងប្រវ័ញ្ច។<br>• សេវាយុត្តិធម៌/ការអនុវត្តច្បាប់ (វិស័យយុត្តិធម៌)៖ អ្នកប្រកបអាជីពវិជ្ជាជីវៈនៅក្នុងវិស័យយុត្តិធម៌/ការអនុវត្តច្បាប់ ប្រកាន់ខ្ជាប់ចំពោះពិធីសារ គោលនយោបាយ និងក្រមប្រតិបត្តិទាក់ទងនឹងអំពើហិង្សាលើកុមារ (VAC) ដើម្បីផ្តល់ការថែទាំ និងការគាំទ្រដល់កុមាររងគ្រោះ ប្រើប្រាស់នីតិវិធីកុមារមេត្រី សម្រាប់ដោះស្រាយបញ្ហាយុត្តិធម៌សម្រាប់កុមារ ដោយយោងទៅតាមនិយាមបទដ្ឋានអន្តរជាតិ និងប្រើប្រាស់ បណ្តាញបញ្ជូន ដោយសហការជាមួយវិស័យដទៃទៀត រួមមានវិស័យសុខុមាលភាពសង្គម សុខាភិបាល និងអប់រំ។ |
| លទ្ធផលរំពឹងទុក (លទ្ធផល រយៈពេលវែង) | សេវាពាក់ព័ន្ធសម្រាប់កុមារដែលមានទំនាក់ទំនងជាមួយប្រព័ន្ធកិច្ចការពារកុមារ |
| វិធីសាស្រ្តគណនា | ចំនួនសរុប |
| ប្រភពទិន្នន័យ | របាយការណ៍កម្មវិធី ឧបករណ៍តាមដានកុមារ, Primero (និងបង្កើត) OSCaR |
| កម្រិតភាពញឹកញាប់ | រៀងរាល់ឆ្នាំ |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ភេទ អាយុ ប្រភេទមូលហេតុនៃការបើកករណី ប្រភេទសេវា ពិការភាព ខេត្ត |
| ទីភ្នាក់ងារផ្តល់របាយការណ៍ | MoSVY (នាយកដ្ឋានបច្ចេកទេសទាំងអស់), MoI, MoJ, NGOs, Save the Children/FCF, React, MoH, MoCR, MoEYS, មូលនិធិជនពិការ |
| ឯកសារយោង | សៀវភៅណែនាំស្តីពីការអនុវត្តសកម្មភាពសេវាសង្គមឃុំ សង្កាត់ (អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ)<br>សៀវភៅណែនាំស្តីពីការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ឃុំ សង្កាត់ (អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ)<br>សៀវភៅណែនាំស្តីពីកិច្ចការពារកុមារ សម្រាប់ឃុំ សង្កាត់ (អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ) |
| កំណត់សម្គាល់ | សេវាមួយអាចពិបាកនឹងរាប់ ប្រសិនបើគ្មានមូលដ្ឋានទិន្នន័យ។ មានន័យថាកុមារទទួលសេវាអាចត្រូវបានរាប់ស្ទួនគ្នា។ ដើម្បីដោះស្រាយបញ្ហានេះ គេអាចប្រើប្រាស់ "មេគុណកែតម្រូវ" សម្រាប់ការរាប់ស្ទួនគ្នា។ មេគុណកែតម្រូវ អាចត្រូវបានប៉ាន់ប្រមាណ ដោយផ្អែកលើគំរូមួយ ឬ បទពិសោធន៍កន្លងមក។ |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | |

# វិស័យទី៥៖ កម្រិតវិសាលភាពនៃបញ្ហា និងកត្តាហានិភ័យ

| ឈ្មោះសូចនាករ | ៥.១.ក ភាគរយនៃកុមារពិការ |
|---|---|
| និយមន័យ | ភាគរយនៃប្រជាជននៅក្នុងគ្រួសារ អាយុ ៥-១៤ឆ្នាំ ដែលបានរាយការណ៍ឱ្យដឹងថាមានការលំបាក, មានការលំបាកច្រើន ឬ មិនអាចបំពេញមុខងារណាមួយ យ៉ាងហោចណាស់នៅក្នុងវិស័យណាមួយក្នុងចំណោមវិស័យខាងក្រោម៖ ការមើលឃើញ ការស្តាប់លឺ ការដើរ ការផ្ចង់ស្មារតី ការថែទាំខ្លួនឯង ឬ ប្រាស្រ័យទាក់ទង ក្នុងអំឡុងពេលនៃការធ្វើអង្កេត។ ការអង្កេតជាក់លាក់របស់ក្រសួង ស.អ.យ តាមបណ្តាលខេត្ត ដែលរាប់ចំនួនជនពិការមានទាំងចំនួនកុមារពិការ |
| លទ្ធផលរំពឹងទុក (លទ្ធផលរយៈពេលខ្លី) | បញ្ចូលកុមារដែលមានការប្រឈមខ្ពស់ចំពោះគ្រោះថ្នាក់ ទៅក្នុងសេវាកិច្ចការពារកុមារ |
| វិធីសាស្ត្រគណនា | ភាគយក៖ ចំនួនកុមារដែលត្រូវបានរាយការណ៍ឱ្យដឹងថាមានការលំបាកណាមួយ ដូចមានបញ្ជាក់នៅក្នុងនិយមន័យ<br>ភាគបែង៖ ក្រុមប្រជាជនដែលមានអាយុ ៥-១៤ឆ្នាំ<br>មេគុណ៖ ១០០ |
| ប្រភពទិន្នន័យ | CDHS |
| កម្រិតភាពញឹកញាប់ | ៣-៥ឆ្នាំ |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ភេទ ខេត្ត ជនបទ-ទីក្រុង កម្រិតទ្រព្យសម្បត្តិប្រភេទពិការ កម្រិតពិការ |
| ទីភ្នាក់ងារផ្តល់របាយការណ៍ | MoP/NIS, MoSVY (នាយកដ្ឋានសុខុមាលភាពជនពិការ) |
| ឯកសារយោង | |
| កំណត់សម្គាល់ | អាចស្វែងរកទិន្នន័យនៃកុមារពិការដែលមានអាយុ ៥ដល់១៧ ឆ្នាំ និងអាយុក្រោម៥ឆ្នាំ |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | សម្រាប់ទិន្នន័យ CDHS - Statcompiler គឺជាឧបករណ៍មួយដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចកសាងតារាង និងផែនទីទៅតាមដែលខ្លួនចង់បាន ពីសូចនាកររាប់ពាន់នៃប្រទេសចំនួន៩០។ STATcompiler មានគោលបំណងជួយដល់អ្នកប្រើប្រាស់ធ្វើការប្រៀបធៀបទិន្នន័យ DHS ទូទាំងបណ្តាប្រទេសនានា និងទៅតាមពេលវេលាផ្សេងៗគ្នា។ https://www.statcompiler.com/en/ |

| ឈ្មោះសូចនាករ | ៥.១.ខ ចំនួនកុមារមានពិការភាពដែលបានកំណត់អត្តសញ្ញាណកម្ម ប្រភេទ និងកម្រិតពិការភាពនៅតាមមណ្ឌលរបស់រដ្ឋ និងអង្គការ |
|---|---|
| និយមន័យ | សំដៅលើកុមារដែលមានពិការភាពគ្រប់ប្រភេទដែលរស់នៅក្នុងមណ្ឌលថែទាំរដ្ឋ និងមណ្ឌលថែទាំអង្គការ ត្រូវបានកំណត់អត្តសញ្ញាណកម្ម ចន្លោះអាយុពី ០-១៧ឆ្នាំ។ |
| លទ្ធផលរំពឹងទុក (លទ្ធផលរយៈពេលខ្លី) | ងាយស្រួលក្នុងការធ្វើសមាហរណកម្មទៅសហគមន៍<br>ងាយស្រួលគ្រប់គ្រង និងផ្តល់សេវាផ្សេងៗ (ការអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ និងមុខរបរ -ល-។) |
| វិធីសាស្ត្រគណនា | រាប់ចំនួនកុមារមានពិការភាពជាក់ស្តែងដែលរស់នៅក្នុងមណ្ឌលថែទាំរដ្ឋ និងមណ្ឌលថែទាំអង្គការ |
| ប្រភពទិន្នន័យ | ទិន្នន័យដែលបានផ្តល់មកពីមណ្ឌលរដ្ឋ និងអង្គការ |
| កម្រិតភាពញឹកញាប់ | រៀងរាល់ឆ្នាំ |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ភេទ អាយុ កម្រិតពិការភាពដែលរស់នៅក្នុងមណ្ឌលថែទាំរដ្ឋ និងអង្គការ |
| ទីភ្នាក់ងារផ្តល់របាយការណ៍ | MoSVY (នាយកដ្ឋានសុខុមាលភាពជនពិការ) |
| ឯកសារយោង | ប្រើប្រាស់ទំរង់ដែលបង្កើតដោយនាយកដ្ឋានសុខុមាលភាពជនពិការ (ទំរង់សាកល្បងក្នុងការកំណត់អត្តសញ្ញាណ ប្រភេទ និងកម្រិតពិការភាពរបស់កុមារ) |
| កំណត់សម្គាល់ | |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | |

| ឈ្មោះសូចនាករ | ៥.២ ភាគរយនៃស្រ្តី និងបុរសអាយុចន្លោះពី ១៥-៤៩ឆ្នាំ ដែលយល់ស្របថា ការដែលប្តី/ដៃគូវាយដំប្រពន្ធរបស់ខ្លួន (ដៃគូរបស់ខ្លួន) គឺជារឿងត្រឹមត្រូវ |
|---|---|
| និយមន័យ | ចំនួនអ្នកផ្តល់ចម្លើយជាក្មេងជំទង់ ឬ មនុស្សពេញវ័យស្រី ឬ ប្រុស ដែលយល់ស្របថា ការវាយប្រពន្ធគឺជារឿងត្រឹមត្រូវ យ៉ាងហោចណាស់មានហេតុផលជាក់លាក់មួយ គិតត្រឹមពេលអង្កេត ដោយបង្ហាញតាមរយៈភាគរយនៃអ្នកផ្តល់ចម្លើយដែលត្រូវបានសួរថា តើការវាយដំប្រពន្ធក្រោមស្ថានភាពជាក់លាក់មួយគឺជារឿងត្រឹមត្រូវដែរឬទេ។ ចន្លោះអាយុរបស់អ្នកផ្តល់ចម្លើយ គឺអាស្រ័យលើអ្វីដែលមានភាពពាក់ព័ន្ធ មានក្រមសីលធម៌ និងលទ្ធភាពអាចទៅរួច/អ្វីដែលមាន សម្រាប់ប្រទេស។ ការអង្កេត DHS, MICS, VACS និង WHO MCS បានធ្វើឱ្យមានសុកដុមនីយកម្មវិធានការរបស់ពួកគេក្នុងការសាកសួរអ្នកផ្តល់ចម្លើយអំពីការទទួលយកការវាយដំប្រពន្ធនៅក្នុងស្ថានភាពចំនួន៥ |
| | (មានរាយនាមខាងក្រោម) ប៉ុន្តែជួនកាលការអង្កេតមានបញ្ចូលស្ថានភាពមួយចំនួនបន្ថែមទៀត ទៅតាមស្ថានភាពជាក់លាក់របស់ប្រទេស។<br>អ្នកផ្តល់ចម្លើយមានអាយុចាប់ពី១៥ឆ្នាំឡើងទៅ ត្រូវបានសួរ៖ បើតាមអ្នកយល់ តើការដែលប្តីវាយដំប្រពន្ធនៅក្នុងស្ថានភាពខាងក្រោម គឺជារឿងត្រឹមត្រូវដែរឬទេ៖ ក) ប្រសិនបើប្រពន្ធទៅក្រៅដោយមិនប្រាប់ប្តី? ខ) ប្រសិនបើប្រពន្ធមិនអើពើនឹងកូន? គ) ប្រសិនបើប្រពន្ធឈ្លោះប្រកែកជាមួយប្តី? ឃ) ប្រសិនបើប្រពន្ធមិនព្រមរួមភេទជាមួយប្តី? ង) ប្រសិនបើប្រពន្ធធ្វើឱ្យម្ហូបអាហារខ្លោច? |
| លទ្ធផលរំពឹងទុក | និយាម និងគុណតម្លៃរបស់ក្រុមសំខាន់ៗ គាំទ្រដល់ទំនាក់ទំនងបែបអហិង្សា ផ្តល់ការគោរព និងមានសមភាពយេនឌ័រ សម្រាប់កុមារ និងក្មេងជំទង់គ្រប់រូប។ (inspire) |
| វិធីសាស្រ្តគណនា | ភាគយក៖ ចំនួនអ្នកផ្តល់ចម្លើយជាស្រ្តី និងបុរស ដែលថ្លែងថាការដែលប្តីវាយប្រពន្ធគឺជារឿងត្រឹមត្រូវ យ៉ាងហោចណាស់នៅក្នុងស្ថានភាពជាក់លាក់ចំនួនមួយ។<br>ភាគបែង៖ ចំនួនអ្នកផ្តល់ចម្លើយសរុបជាស្រ្តី និងបុរស ដែលត្រូវបានសួរថា តើការវាយដំប្រពន្ធ គឺជារឿងត្រឹមត្រូវដែរឬទេ។<br>មេគុណ៖ ១០០ |
| ប្រភពទិន្នន័យ | CDHS |
| កម្រិតភាពញឹកញាប់ | ៥ឆ្នាំ |

| | |
|---|---|
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ទៅតាមភេទរបស់អ្នកផ្តល់ចម្លើយ ចន្លោះអាយុ លំនៅដ្ឋាន (ជនបទ/ទីក្រុង) ទ្រព្យសម្បត្តិគ្រួសារ និងស្ថានភាពដែលអ្នកផ្តល់ចម្លើយជឿថាការវាយដំប្រពន្ធគឺជារឿងត្រឹមត្រូវ។ |
| ទីភ្នាក់ងារផ្តល់របាយការណ៍ | MoP |
| ឯកសារយោង | Inspire (និយាម និងគុណតម្លៃ) សូចនាករ Inspire ៤.៣ អំពីការទទួលយកការវាយដំប្រពន្ធ (ភាគរយនៃស្ត្រី និងបុរស អាយុ ១៣-៤៩ឆ្នាំ ដែលយល់ស្របថាប្តី (បុរស) វាយដំប្រពន្ធ (ដៃគូ) គឺជារឿងត្រឹមត្រូវ ក្រោមហេតុផលជាក់លាក់យ៉ាងហោចណាស់ចំនួនមួយ ដោយបែងចែកទៅតាមភេទ និងអាយុ)។ |
| កំណត់សម្គាល់ | |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | សម្រាប់ទិន្នន័យ CDHS - Statcompiler គឺជាឧបករណ៍មួយដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចកសាងតារាង និងផែនទីទៅតាមដែលខ្លួនចង់បាន ពីសូចនាកររាប់ពាន់នៃប្រទេសចំនួន៩០។ STATcompiler មានគោលបំណងជួយដល់អ្នកប្រើប្រាស់ធ្វើការប្រៀបធៀបទិន្នន័យ DHS ទូទាំងបណ្តាប្រទេសនានា និងទៅតាមពេលវេលាផ្សេងៗគ្នា។ https://www.statcompiler.com/en/<br>មូលដ្ឋានទិន្នន័យសកលរបស់អង្គការយូនីសេហ្វ ត្រួតពិនិត្យទិន្នន័យ DHS និងទិន្នន័យ MICS សម្រាប់សូចនាករនេះ ចំពោះស្ត្រី និងកុមារី អាយុ ១៥-៤៩ឆ្នាំ នៅក្នុងជាង ១០០ប្រទេស និងសម្រាប់កុមារា និងបុរស អាយុ ១៥-៤៩ឆ្នាំ នៅក្នុងជាង ៧០ប្រទេស (https://data.unicef.org/topic/child-protection/violence/attitudes-and-social-norms-on-violence)។ ទិន្នន័យ VACS អាចរកបានពីជាង៨ប្រទេស តាមរយៈ CDC (www.cdc.gov/violenceprevention/childabuseandneglect/vacs/index.html). |

| ឈ្មោះសូចនាករ | ៥.៣ កុមារដែលរស់នៅក្នុងគ្រួសារស្ថិតនៅក្រោមបន្ទាត់ភាពក្រីក្ររបស់ជាតិ |
|---|---|
| និយមន័យ | ភាគរយនៃកុមារី និងកុមារា អាយុ ០-១៧ឆ្នាំ កំពុងរស់នៅក្នុងគ្រួសារដែលស្ថិតក្រោមខ្សែបន្ទាត់នៃភាពក្រីក្រជាតិ។ ចំនួនកុមារី និងកុមារាកំពុងរស់នៅក្នុងគ្រួសារដែលមានប្រាក់ចំណូល និង/ឬ កម្រិតនៃការប្រើប្រាស់/ទទួលទាន ក្រោមខ្សែបន្ទាត់នៃភាពក្រីក្រជាតិ ដោយបង្ហាញក្នុងលក្ខណៈជាភាគរយនៃចំនួនកុមារសរុប។ **ខ្សែបន្ទាត់នៃភាពក្រីក្រជាតិ** ជាផ្លូវការ គឺជាកម្រិតនៃការប្រើប្រាស់/ទទួលទានប្រចាំឆ្នាំរបស់គ្រួសារ ចែកនឹងចំនួនមនុស្សពេញវ័យ និងកុមារនៅក្នុងគ្រួសារ ដោយគ្រួសារដែលស្ថិតនៅក្រោមខ្សែបន្ទាត់នេះ ត្រូវបានចាត់ទុកថាក្រីក្រ ផ្អែកលើកម្រិតដែលកំណត់ដោយរដ្ឋាភិបាល។ ប្រទេសមួយចំនួនមានខ្សែបន្ទាត់នៃភាពក្រីក្រដាច់ដោយឡែកពីគ្នា សម្រាប់តំបន់ទីក្រុង និងតំបន់ជនបទដើម្បីពិចារណាទៅលើភាពខុសគ្នានៃលទ្ធភាពក្នុងការទិញទំនិញ។ ជាទូទៅ ការប្រើប្រាស់/ទទួលទាននៅក្នុងគ្រួសារ រួមមានការចំណាយទៅលើអាហារ និងទំនិញចាំបាច់នានា ព្រមទាំងអាហារដែលបានទទួលទានតាមរយៈការដែលគ្រួសារផលិតដោយខ្លួនឯង។ ប្រទេសដែលមានទ្រព្យធនខ្ពស់ ហាក់មាននិន្នាការកំណត់យកបទដ្ឋានខ្ពស់ជាងប្រទេសក្រីក្រ។ ប្រទេសមួយចំនួន វាស់ស្ទង់ទៅលើភាពក្រីក្រ ដោយផ្អែកលើប្រាក់ចំណូលតែមួយមុខប៉ុណ្ណោះ ដោយឡែកប្រទេសដទៃទៀតបញ្ចូលទាំងប្រាក់ចំណូល និងការប្រើប្រាស់/ការទទួលទាន។ ប្រទេសមួយចំនួនប្រើប្រាស់**ខ្សែបន្ទាត់ដាច់ខាត** ដោយផ្អែកលើប្រាក់ចំណូល ឬ ចំណាយអប្បបរមា ដែលត្រូវការសម្រាប់ការទទួលទានកាឡូរីកម្រិតមូលដ្ឋាន និងទំនិញចាំបាច់នានា ប៉ុន្តែ ប្រទេសដទៃទៀតប្រើប្រាស់ចំណុចដៅ**ទាក់ទងនឹង** ប្រាក់ចំណូល និងការប្រើប្រាស់/ការទទួលទាន នៅក្នុងប្រទេសនោះ។<br><br>( Inspire ) |
| លទ្ធផលរំពឹងទុក | ដើម្បីវាស់វែងទៅលើការប្រែប្រួលនៅក្នុងសមាមាត្រនៃកុមារកំពុងរស់នៅក្នុងភាពក្រីក្រ ( ត្រូវបានកំណត់ទូទាំងប្រទេស ) អាស្រ័យដោយមានភស្តុតាងបញ្ជាក់ថាភាពទីទ័លក្រត្រូវបានកំណត់ថាជាកត្តាហានិភ័យមួយសម្រាប់ប្រភេទជាក់លាក់នៃអំពើហិង្សាលើកុមារ។<br>( Inspire ) |
| វិធីសាស្ត្រគណនា | ភាគយក៖ កុមារី និងកុមារា ០-១៧ឆ្នាំ កំពុងរស់នៅក្នុងគ្រួសារដែលត្រូវបានកំណត់ថាស្ថិតនៅក្រោមខ្សែបន្ទាត់នៃភាពក្រីក្រ<br><br>ភាគបែង៖ ចំនួនកុមារសរុប អាយុ ០-១៧ឆ្នាំ<br><br>មេគុណ៖ ១០០<br><br>ខ្សែបន្ទាត់នៃភាពក្រីក្រ៖ ខ្សែបន្ទាត់នៃភាពក្រីក្រជាតិ ដូចមានកំណត់ដោយក្រសួងផែនការ គិតត្រឹមពេលធ្វើការអង្កេត |

| | |
|---|---|
| ប្រភពទិន្នន័យ | CSES/Child Poverty Profile |
| កម្រិតភាពញឹកញាប់ | ២ឆ្នាំ |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ភេទ អាយុ ខេត្ត ជនបទ-ទីក្រុង |
| ទីភ្នាក់ងារទទួលខុសត្រូវរាយការណ៍អំពីទិន្នន័យ | MoP/NIS/GDP |
| ឯកសារយោង | សូចនាករ SDG ១.២.១ កុមារដែលស្ថិតនៅក្រោមខ្សែបន្ទាត់នៃភាពក្រីក្រជាតិ<br>Inspire ៧.១ (ការពង្រឹងប្រាក់ចំណូល និងសេដ្ឋកិច្ច) |
| កំណត់សម្គាល់ | |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | អង្គការសហប្រតិបត្តិការ និងអភិវឌ្ឍសេដ្ឋកិច្ច (OECD) មូលដ្ឋានទិន្នន័យគ្រួសារ តាមដានអត្រាភាពក្រីក្រកុមារថ្នាក់ជាតិ ក្នុងប្រទេស OECD ចំនួន៣៥ និងជាង៧ប្រទេសដទៃទៀត (www.oecd.org/els/family/database.htm)។ មូលដ្ឋានទិន្នន័យសកលកម្រិតមីក្រូរបស់ធនាគារពិភពលោក រួមមានកម្រងទិន្នន័យនៅអំពីភាពក្រីក្ររបស់កុមារសម្រាប់ជាង៨៩ប្រទេស (inspire) |

| ឈ្មោះសូចនាករ | ៥.៤ ការប៉ាន់ប្រមាណចំនួនកុមារកំពុងរស់នៅក្នុងគ្រួសារក្នុងចំណាត់ថ្នាក់ក្រីក្រកម្រិត១ និង ក្រីក្រកម្រិត២ |
|---|---|
| និយមន័យ | ក្រសួងផែនការបានអនុវត្តនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ចាប់ពីឆ្នាំ២០០៦ មក។ ការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ គឺជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីចូលរួមការកាត់បន្ថយភាពក្រីក្រ និងគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ចនៅក្នុងប្រទេសកម្ពុជា។ យោងតាមអនុក្រឹត្យលេខ ២៩១ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១ ស្តីពីអត្តសញ្ញាណកម្ម គ្រួសារក្រីក្រ មានគោលបំណងធានាបាននូវប្រសិទ្ធភាព និងតម្លាភាព នៃការគ្រប់គ្រងលើដំណើរការអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងការប្រើប្រាស់ទិន្នន័យគ្រួសារក្រីក្រ។ ទិន្នន័យគ្រួសារក្រីក្រត្រូវបានក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលនានា យកទៅប្រើប្រាស់យ៉ាងទូលំទូលាយដើម្បីផ្តល់សេវា និងផ្តល់ជំនួយដល់គ្រួសារក្រីក្រប្រកបដោយប្រសិទ្ធភាព។ “ការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ” ឬ “IDPOOR” បានប្រើប្រាស់កម្រងបញ្ជីសំណួរមួយដែលមានលក្ខណៈច្របាច់បញ្ចូលគ្នានូវទិដ្ឋភាពជាក់ស្តែងនៃឧបករណ៍វាស់វែងពីកម្រិតជីវភាព (proxy means test) ជាមួយនឹងភាពត្រឹមត្រូវ ដោយមានការចូលរួមពីសហគមន៍ និងអនុវត្តដោយប្រជាពលរដ្ឋតាមភូមិនីមួយៗ។<br>ចំណាត់ថ្នាក់ភាពក្រីក្របែងចែកជា២កម្រិត ៖ ក្រកម្រិត១ (ក្រីក្របំផុត ឬ ទីទ័លក្រ) និងក្រកម្រិត២ (ក្រ)។ ការដាក់ចំណាត់ថ្នាក់ភាពក្រីក្រនេះ ធ្វើឡើងដោយប្រើប្រាស់ពិន្ទុដែលបានពីបញ្ជីសំណួរ និងមានការពិចារណាពីស្ថានភាពពិសេសរបស់គ្រួសារ។ |
| លទ្ធផលរំពឹងទុក | សម្រាប់រៀបចំផែនការកម្មវិធីពង្រឹងសេដ្ឋកិច្ចគ្រួសារ និងការត្រួតពិនិត្យហានិភ័យទាក់ទងនឹងកិច្ចការពារកុមារ |
| វិធីសាស្ត្រគណនា | ចំនួនកុមារសរុបដែលត្រូវបានរាយការណ៍ |
| ប្រភពទិន្នន័យ | មូលដ្ឋានទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ |
| កម្រិតភាពញឹកញាប់ | ៣ឆ្នាំ |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ជនបទ ទីប្រជុំជន ជុំប្រមូលទិន្នន័យ/ឆ្នាំ អាយុ ភេទ ក្រីក្រកម្រិត១ ក្រីក្រកម្រិត២ |
| ទីភ្នាក់ងារផ្តល់របាយការណ៍ | MoP/GDP |

| | |
|---|---|
| ឯកសារយោង | |
| កំណត់សម្គាល់ | |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | ទិន្នន័យ IDPoor អាចស្វែងរកបានពីគេហទំព័រ www.idpoor.gov.kh |

| ឈ្មោះសូចនាករ | ៥.៥. ចំនួនកុមារដែលត្រូវបានជួញដូរទៅក្នុងទម្រង់ផ្សេងៗគ្នា (សូចនាករ SDG ១៦.២.២ ចំនួនជនរងគ្រោះដោយសារការជួញដូរមនុស្ស ក្នុងប្រជាជន ១០០.០០០នាក់ បែងចែកតាមភេទ និងអាយុ និងទម្រង់នៃការកេងប្រវ័ញ្ច) |
|---|---|
| និយមន័យ | ការជួញដូរកុមារត្រូវបានកំណត់ថាជាការជ្រើសរើសការដឹកជញ្ជូនការផ្ទេរការថែរក្សា ឬការទទួលកូនក្មេងសម្រាប់គោលបំណងធ្វើអាជីវកម្ម (ពិធីការបង្ការទប់ស្កាត់ និងដាក់ទោសដល់ការជួញដូរមនុស្សជាពិសេសស្ត្រីនិងកុមារឆ្នាំ ២០០០) |
| លទ្ធផលរំពឹងទុក | សម្រាប់សេវាឆ្លើយតបទៅនឹងកិច្ចការពារកុមារ |
| វិធីសាស្ត្រគណនា | ភាគយក៖ កុមារី និងកុមារា អាយុ ០-១៧ឆ្នាំ ដែលត្រូវបានរាយការណ៍ថាត្រូវបានជួញដូរក្នុងឆ្នាំកន្លងទៅ<br>ភាគបែង៖ ចំនួនកុមារី និងកុមារាសរុប អាយុ ០-១៧ឆ្នាំ<br>មេគុណ៖ ១០០.០០០ |
| ប្រភពទិន្នន័យ | កំណត់ហេតុរដ្ឋបាល |
| កម្រិតភាពញឹកញាប់ | រៀងរាល់ឆ្នាំ |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ទៅតាមភេទ អាយុ និងទម្រង់នៃការកេងប្រវ័ញ្ច ក្នុងនិងក្រៅប្រទេស |
| ទីភ្នាក់ងារទទួលខុសត្រូវរាយការណ៍អំពីទិន្នន័យ | MoI(នាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន) |
| ឯកសារយោង | SDG Indicator ១៦.២.២ |
| កំណត់សម្គាល់ | |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | |

| ឈ្មោះសូចនាករ | ៥.៦ ភាគរយនៃកុមារអាយុក្រោម១៨ឆ្នាំ ដែលមិនរស់នៅជាមួយឪពុកម្តាយបង្កើតរបស់ពួកគេ បើទោះបីយ៉ាងហោចណាស់មានឪពុក ឬ ម្តាយម្នាក់ដែលនៅរស់ក៏ដោយ |
|---|---|
| និយមន័យ | ភាគរយនៃកុមារអាយុ០-១៧ឆ្នាំ ដែលមិនរស់នៅជាមួយឪពុកម្តាយបង្កើតរបស់ពួកគេ បើទោះបីជាយ៉ាងហោចណាស់ពួកគេនៅមានឪពុក ឬ ម្តាយម្នាក់ដែលនៅរស់ក៏ដោយ |
| លទ្ធផលរំពឹងទុក | ដើម្បីរៀបចំផែនការថែទាំតាមគ្រួសារសម្រាប់កុមារគ្រប់រូបដែលគ្មានការថែទាំពីឪពុកម្តាយ |
| វិធីសាស្រ្តគណនា | ភាគយក៖ កុមារី និងកុមារា អាយុ ០-១៧ឆ្នាំ ដែលត្រូវបានរាយការណ៍ឱ្យដឹងថាយ៉ាងហោចណាស់មានឪពុក ឬម្តាយម្នាក់ដែលនៅរស់ ប៉ុន្តែមិនរស់នៅជាមួយឪពុកម្តាយ<br>ភាគបែង៖ ចំនួនកុមារី និងកុមារាសរុប អាយុ ០-១៧ឆ្នាំ<br>មេគុណ៖ ១០០ |
| ប្រភពទិន្នន័យ | CDHS |
| កម្រិតភាពញឹកញាប់ | ៥ឆ្នាំ |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ទៅតាមភេទ អាយុ ខេត្ត |
| ទីភ្នាក់ងារទទួលខុសត្រូវរាយការណ៍អំពីទិន្នន័យ | MoP/NIS |
| ឯកសារយោង | |
| កំណត់សម្គាល់ | |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | សម្រាប់ទិន្នន័យ CDHS - Statcompiler គឺជាឧបករណ៍មួយដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចកសាងតារាង និងផែនទីទៅតាមដែលខ្លួនចង់បាន ពីសូចនាកររាប់ពាន់នៃប្រទេសចំនួន៩០។ STATcompiler មានគោលបំណងជួយដល់អ្នកប្រើប្រាស់ធ្វើការប្រៀបធៀបទិន្នន័យ DHS ទូទាំងបណ្តាប្រទេសនានា និងទៅតាមពេលវេលាផ្សេងៗគ្នា។ https://www.statcompiler.com/en/ |

| ឈ្មោះសូចនាករ | ៥.៧ ចំនួនកុមារកំពុងរស់នៅ ឬ ធ្វើការតាមចិញ្ចើមថ្នល់ |
|---|---|
| និយមន័យ | កុមារកំពុងរស់នៅ ឬ ធ្វើការងារតាមចិញ្ចើមថ្នល់ ត្រូវបានកំណត់និយមន័យក្រោមប្រភេទចំនួនបី ៖<br><br>១) "កុមាររស់នៅតាមចិញ្ចើមថ្នល់" (កុមារដែលបានផ្តាច់ចំណងពីគ្រួសាររបស់ពួកគេ និងរស់នៅម្នាក់ឯងតាមចិញ្ចើមថ្នល់)<br><br>២) "កុមារធ្វើការងារតាមចិញ្ចើមថ្នល់" (កុមារដែលចំណាយពេលវេលារបស់ពួកគេទាំងអស់ ឬ ពេលវេលារបស់ពួកគេភាគច្រើន ធ្វើការងាតាមចិញ្ចើមថ្នល់ ដើម្បីផ្តល់ប្រាក់ចំណូលជូនគ្រួសាររបស់ពួកគេ និង/ឬ សម្រាប់ខ្លួនឯង ប៉ុន្តែពួកគេវិលត្រឡប់ទៅផ្ទះរបស់អ្នកថែទាំរបស់ពួកគេវិញនៅពេលយប់) និង<br><br>៣) "កុមារនៃគ្រួសារដែលរស់នៅតាមចិញ្ចើមថ្នល់" (កុមារដែលរស់នៅជាមួយគ្រួសាររបស់ពួកគេតាមចិញ្ចើមថ្នល់)។ |
| លទ្ធផលរំពឹងទុក | ដើម្បីរៀបចំផែនការថែទាំតាមគ្រួសារសម្រាប់កុមារគ្រប់រូបដែលគ្មានការថែទាំពីឪពុកម្តាយ |
| វិធីសាស្ត្រគណនា | ចំនួនកុមារសរុបដែលត្រូវបានរាប់ទៅតាមនិយមន័យកំណត់ខាងលើ |
| ប្រភពទិន្នន័យ | ការអង្កេតជាក់លាក់ |
| កម្រិតភាពញឹកញាប់ | រៀងរាល់ឆ្នាំ |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ទៅតាមភេទ អាយុ ខេត្ត |
| ទីភ្នាក់ងារទទួលខុសត្រូវរាយការណ៍អំពីទិន្នន័យ | MoSVY (នាយកដ្ឋានសុខុមាលភាពសង្គម), Friends International,សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការងារជាមួយកុមារតាមចិញ្ចើមផ្លូវ |
| ឯកសារយោង | |
| កំណត់សម្គាល់ | |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | |

| ឈ្មោះសូចនាករ | ៥.៨ ភាគរយនៃកុមារដែលទទួលរងអំពើហិង្សាផ្លូវកាយ និង/ឬ ផ្លូវចិត្ត ពីសំណាក់អ្នកថែទាំក្នុងរយៈពេល១ខែចុងក្រោយ<br>(សូចនាករ SDG ១៦.២.១: ភាគរយនៃកុមារអាយុ១-១៧ឆ្នាំដែលទទួលរងអំពើហិង្សាផ្លូវកាយ និងឬ ផ្លូវចិត្ត ពីសំណាក់អ្នកថែទាំក្នុងរយៈពេល១ខែចុងក្រោយ<br>ទិន្នន័យមានក្នុងCDHS: ភាគរយនៃស្ត្រីអាយុចន្លោះពី ១៥-៤៩ឆ្នាំ ដែលធ្លាប់ទទួលរងអំពើហិង្សាផ្លូវកាយ ចាប់ពីអាយុ១៥ឆ្នាំ និងភាគរយនៃស្ត្រីអាយុចន្លោះពី ១៥-៤៩ឆ្នាំ ដែលធ្លាប់ទទួលរងអំពើហិង្សាផ្លូវកាយក្នុងរយៈពេល១២ខែចុងក្រោយ) |
|---|---|
| និយមន័យ | ភាគរយនៃកុមារី និងកុមារា អាយុ ១៣-១៧ឆ្នាំ ដែលបានទទួលរងអំពើហិង្សាផ្លូវកាយ និង/ឬ ផ្លូវចិត្តពីអ្នកថែទាំ ក្នុងរយៈពេលមួយខែកន្លងមក។<br>អំពើហិង្សាផ្លូវកាយ ត្រូវបានកំណត់និយមន័យថាជាសកម្មភាពណាមួយដូចខាងក្រោម៖ ១. ការទះកំផ្លៀង ឬ ការច្រាន ២. ការដាល់ ទាត់ធាក់ វាយនឹងរំពត់ ឬវាយនឹងវត្ថុអ្វីមួយ ៣. ការធ្វើឱ្យស្លាក់ ថប់ដង្ហើម ព្យាយាមធ្វើឱ្យលង់ទឹក ឬ ធ្វើឱ្យរលាកដោយចេតនា ៤. ការប្រើប្រាស់ ឬគំរាមប្រើប្រាស់កាំបិត ឬ អាវុធដទៃទៀត (ដូចមានកំណត់នៅក្នុងការអង្កេតស្តីពីអំពើហិង្សាលើកុមារដែលត្រូវបានធ្វើឡើងជាទៀងទាត់ដោយវិទ្យាស្ថានជាតិស្ថិតិ ក្នុងឆ្នាំ២០១៧)។ |
| | អំពើហិង្សាផ្លូវចិត្ត ត្រូវបានកំណត់ថាជាសកម្មភាពណាមួយដូចខាងក្រោម៖ ១. និយាយ ឬ ធ្វើអ្វីម៉្យាងដើម្បីធ្វើឱ្យអ្នកអាប់ឱននៅចំពោះមុខអ្នកដទៃ ២. គំរាមបង្កការឈឺចាប់ ឬ គ្រោះថ្នាក់មកលើអ្នក ឬ នរណាម្នាក់ដែលជិតស្និទ្ធជាមួយអ្នក ៣. តិះដៀលអ្នក ឬ ធ្វើឱ្យអ្នកមានអារម្មណ៍មិនល្អចំពោះខ្លួនអ្នក (ដូចមានកំណត់នៅក្នុងការអង្កេតស្តីពីអំពើហិង្សាលើកុមារដែលត្រូវបានធ្វើឡើងជាទៀងទាត់ដោយវិទ្យាស្ថានជាតិស្ថិតិ ក្នុងឆ្នាំ២០១៧)។ |
| លទ្ធផលរំពឹងទុក (ផលប៉ះពាល់/គោលដៅ) | ដើម្បីវាស់វែងការប្រែប្រួលចំពោះប្រេវ៉ាឡង់នៃអំពើហិង្សាផ្លូវកាយ និងផ្លូវចិត្ត ដែលប្រព្រឹត្តដោយអ្នកថែទាំ។ |
| វិធីសាស្ត្រគណនា | ភាគយក៖ ចំនួនកុមារ អាយុ ១៣-១៧ឆ្នាំ ដែលត្រូវបានរាយការណ៍ថាបានទទួលរងអំពើហិង្សាផ្លូវកាយ/ផ្លូវចិត្ត ពីអ្នកថែទាំក្នុងរយៈពេលមួយខែកន្លងទៅ។<br>ភាគបែង៖ ចំនួនសរុបនៃកុមារ អាយុ ១៣-១៧ឆ្នាំ<br>មេគុណ៖ ១០០ |
| ប្រភពទិន្នន័យ | CDHS, ការអង្កេតជាក់លាក់ របាយការណ៍កម្មវិធី |

| | |
|---|---|
| កម្រិតភាពញឹកញាប់ | CDHS: រៀងរាល់៥ឆ្នាំម្តង<br>NIS: រៀងរាល់ឆ្នាំ<br>របាយការណ៍កម្មវិធី<br>( សម្គាល់៖ អនុសាសន៍របស់ Inspire គឺត្រូវធ្វើរៀងរាល់ ៣-៥ ឆ្នាំម្តង ) |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ទៅតាមភេទ និងអាយុរបស់កុមារ ទ្រព្យសម្បត្តិគ្រួសារ លំនៅដ្ឋាន ( ជនបទ/ទីក្រុង ) ពិការភាព ( ប្រសិនបើមាន ) ប្រភេទនៃការអនុវត្តដាក់ពិន័យបែបហិង្សា ( ផ្លូវកាយ/ផ្លូវចិត្ត ) កម្រិតនៃភាពធ្ងន់ធ្ងរ ( មានការអនុវត្តដាក់ពិន័យធ្ងន់ធ្ងរដែរឬទេ )។ ទៅតាមប្រភេទចារី។ |
| ទីភ្នាក់ងារផ្តល់របាយការណ៍ | MoP/NIS, Save the Children/FCF, UNICEF |
| ឯកសារយោង | សូចនាករ INSPIRE ១.១ និង SDG ១៦.២.១ |
| កំណត់សម្គាល់ | ក្របខ័ណ្ឌ Inspire និង SDG មានលក្ខណៈខុសគ្នាបន្តិចបន្តួច៖<br>ភាគរយនៃកុមារី និងកុមារា អាយុ ១-១៧ ឆ្នាំ ដែលបានទទួលរងទណ្ឌកម្មលើរាងកាយណាមួយ និង/ឬ ហិង្សាផ្លូវចិត្ត ពីអ្នកថែទាំក្នុងខែកន្លងទៅ ដោយបែងចែកទៅតាមភេទ និងអាយុ ( សូចនាករ **SDG ១៦.២.១**និង សូចនាករInspire )<br>Inspire: ការអនុវត្តវិន័យបែបហិង្សាពីអ្នកថែទាំក្នុងខែកន្លងមក៖ ភាគរយនៃកុមារី និង កុមារា អាយុ ១-១៧ឆ្នាំ ដែលបានទទួលរងទណ្ឌកម្មផ្លូវកាយ និង/ឬ ហិង្សាផ្លូវចិត្តពីអ្នកថែទាំក្នុងខែកន្លងមក ដោយបែងចែកទៅតាមភេទ និងអាយុ ( inspire ១.១ ) |
| | សម្គាល់៖ បច្ចុប្បន្ន ការអង្កេតជាទៀងទាត់ដែលធ្វើឡើងដោយ NIS សួរសំនួរនេះ ប៉ុន្តែចំពោះតែកុមារអាយុ ១៣-១៧ឆ្នាំ និង នៅក្នុងរាជធានីខេត្តចំនួន៥ប៉ុណ្ណោះ។ CDHS ក៏មានសំនួរអំពីហិង្សាផ្លូវកាយផងដែរ ប៉ុន្តែផ្តោតលើរយៈពេល១២ខែចុងក្រោយ មិនមែនរយៈពេល១ខែកន្លងមកនោះទេ។ បន្ថែមពីនេះទៀត ក៏មានការពិនិត្យថា តើអ្នកផ្តល់ចម្លើយជានរណាផងដែរ។ |

| ឈ្មោះសូចនាករ | ៥.៩ ករណីទណ្ឌកម្មលើរាងកាយ ដែលប្រព្រឹត្តដោយគ្រូបង្រៀនក្នុងរយៈពេល១ឆ្នាំកន្លងមក |
|---|---|
| និយមន័យ | ភាគរយនៃកុមារ និងក្មេងជំទង់ស្រីប្រុស ដែលបច្ចុប្បន្នកំពុងរៀននៅឯសាលា និងរាយការណ៍ថាបានទទួលរងទណ្ឌកម្មលើរាងកាយពីគ្រូបង្រៀន ក្នុងរយៈពេល១២ខែចុងក្រោយ។<br><br>ចំនួនកុមារី និងកុមារា ដែលរាយការណ៍ឱ្យដឹងថាបានទទួលរង**ទណ្ឌកម្មលើរាងកាយ**ពីគ្រូបង្រៀនក្នុងរយៈពេល១២ខែចុងក្រោយ ដោយបង្ហាញតាមរយៈភាគរយនៃកុមារ និង/ឬ ក្មេងជំទង់ដែលកំពុងរៀនសូត្រនៅឯសាលា។ **ទណ្ឌកម្មលើរាងកាយ** ត្រូវបានកំណត់ថាជាសកម្មភាពផ្លូវកាយទាំងឡាយណាដែលមានគោលបំណងបង្កការឈឺចាប់ ឬ ភាពមិនស្រណុកស្រួល បើទោះបីជាមានកម្រិតស្រាលយ៉ាងណាក៏ដោយ។ សូចនាករនេះក៏អាចធ្វើការវាស់វែងសម្រាប់រយៈពេល១ខែចុងក្រោយ ឬ ១សប្តាហ៍ចុងក្រោយផងដែរ។ ចន្លោះអាយុ និងរយៈពេលនៃអំពើហិង្សា គឺអាស្រ័យលើអ្វីដែលមានភាពពាក់ព័ន្ធ ក្រមសីលធម៌ លទ្ធភាពអាចទៅរួច/អ្វីដែលមាន សម្រាប់ប្រទេស។ ការអង្កេតរមែងតែងប្រើប្រាស់និយមន័យប្រតិបត្តិផ្សេងៗគ្នានៃអំពើហិង្សាដែលប្រព្រឹត្តដោយគ្រូបង្រៀន ដែលមានលក្ខណៈខុសគ្នាចំពោះចំនួន និងប្រភេទនៃសកម្មភាពដែលបានវាស់វែង ពេលវេលា ចារី និងពាក្យពេជន៍ដែលប្រើប្រាស់សម្រាប់សួរសំនួរ។ ទាំង GSHS ( សូមមើលខាងក្រោម ) និង VACS ( សូមមើលទំព័រ៣១ ) ប្រើប្រាស់ឧបករណ៍ទោលតែមួយ ដើម្បីវាស់វែងទៅលើអំពើហិង្សាដែលប្រព្រឹត្តដោយគ្រូបង្រៀនក្នុងរយៈពេល១២ខែចុងក្រោយ។ ICAST សួរអំពីបញ្ជីលម្អិតនៃសកម្មភាពដែលប្រព្រឹត្តដោយគ្រូបង្រៀន ឬ បុគ្គលិកដទៃទៀតនៅក្នុងសាលារៀន ក្នុងរយៈពេល១សប្តាហ៍ចុងក្រោយ និងឆ្នាំសិក្សាចុងក្រោយ។<br><br>សម្រាប់ប្រទេសកម្ពុជា គប្បីប្រើប្រាស់និយមន័យខាងក្រោម៖ អំពើហិង្សាផ្លូវកាយត្រូវបានកំណត់និយមន័យថាជាសកម្មភាពណាមួយក្នុងចំណោមសកម្មភាពខាងក្រោម៖ ១. ការទះកំផ្លៀង ឬ ការច្រាន ២. ការដាល់ ទាត់ធាក់ វាយនឹងរំពត់ ឬវាយនឹងវត្ថុអ្វីមួយ ៣. ការធ្វើឱ្យស្លាក់ ថប់ដង្ហើម ព្យាយាមធ្វើឱ្យលង់ទឹក ឬ ធ្វើឱ្យរលាកដោយចេតនា ៤. ការប្រើប្រាស់ ឬគំរាមប្រើប្រាស់កាំបិត ឬ អាវុធដទៃទៀត ( ដូចមានកំណត់នៅក្នុងការអង្កេតស្តីពីអំពើហិង្សាលើកុមារដែលត្រូវបានធ្វើឡើងជាទៀងទាត់ដោយវិទ្យាស្ថានជាតិស្ថិតិ ក្នុងឆ្នាំ២០១៧ )។ |
| លទ្ធផលរំពឹងទុក ( ផលប៉ះពាល់/គោលដៅ ) | កុមារគ្រប់រូប រួមទាំងក្មេងជំទង់ ចម្រើនវ័យឡើងជាមួយនឹងការរួចផុតកាន់តែច្រើនឡើងពីអំពើហិង្សាគ្រប់ទម្រង់ , ដើម្បីវាស់វែងទៅលើការប្រែប្រួលប្រេវ៉ាឡង់នៃទណ្ឌកម្មលើរាងកាយដែលប្រព្រឹត្តដោយគ្រូបង្រៀន។ |

| | |
|---|---|
| វិធីសាស្ត្រគណនា | ភាគយក៖ ចំនួនកុមារ ឬ ក្មេងជំទង់ ដែលរាយការណ៍ឱ្យដឹងអំពីទណ្ឌកម្មលើរាងកាយប្រព្រឹត្តដោយគ្រូបង្រៀន ក្នុងរយៈពេល១២ខែចុងក្រោយ<br>ភាគបែង៖ ចំនួនកុមារ ឬ ក្មេងជំទង់សរុប ដែលត្រូវបានសួរអំពីទណ្ឌកម្មលើរាងកាយប្រព្រឹត្តដោយគ្រូបង្រៀន ឬ អ្នកគ្រប់គ្រងសាលារៀន<br>មេគុណ៖ ១០០ |
| ប្រភពទិន្នន័យ | កំណត់ហេតុរដ្ឋបាល ការអង្កេតជាក់លាក់ |
| កម្រិតភាពញឹកញាប់ | CDHS: រៀងរាល់៥ឆ្នាំម្តង<br>NIS: រៀងរាល់ឆ្នាំ<br>( សម្គាល់៖ អនុសាសន៍របស់ Inspire គឺត្រូវធ្វើសកម្មភាពនេះរៀងរាល់ ៣-៥ ឆ្នាំម្តង ) |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ទៅតាមភេទ កម្រិតថ្នាក់រៀន (ឬអាយុ) ប្រភេទសាលារៀន និងលក្ខណៈសង្គមប្រជាសាស្ត្រដទៃទៀត ដែលពាក់ព័ន្ធទៅនឹងបរិបទ ដូចជាទ្រព្យសម្បត្តិគ្រួសារ លំនៅដ្ឋាន ( ទីក្រុង/ជនបទ ) ជាតិពន្ធុ។ល។ |
| ទីភ្នាក់ងារទទួលខុសត្រូវរាយការណ៍អំពីទិន្នន័យ | MoP/NIS, MoEYS |
| ឯកសារយោង | សូចនាករ INSPIRE ១.២ |
| កំណត់សម្គាល់ | សូមមើលកំណត់សម្គាល់ខាងលើស្តីពីអំពើហិង្សាផ្លូវកាយ |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | ទិន្នន័យ GSHS អាចរកបានតាមអនឡាញពី WHO ( www.who.int/chp/gshs/en )។ ទិន្នន័យ VACS ពីប្រទេសជាង៨ អាចរកបានពី CDC (www.cdc.gov/violenceprevention/childabuseandneglect/vacs/index.html )។ ទិន្នន័យពីការសិក្សាអំពីជីវិតរស់នៅរបស់មនុស្សវ័យក្មេង ( Young Lives Study ) ពីប្រទេសចំនួន៤ អាចរកបានពី Innocenti ( www.unicef-irc.org/publications/pdf/CORPORAL%២០PUNISHMENT%២០IDP២finalrev.pdf ). |

| ឈ្មោះសូចនាករ | ៥.១០ ភាគរយនៃស្ត្រី និងកុមារីអាយុចាប់ពី១៥ឆ្នាំឡើងទៅ ដែលធ្លាប់មានដៃគូ បានទទួលរងអំពើហិង្សាផ្លូវភេទ ពីសំណាក់មនុស្សផ្សេងទៀតដែលមិនមែនជាដៃគូស្និទ្ធស្នាល ក្នុងរយៈពេល១២ខែចុងក្រោយ បែងចែកតាមអាយុ និងកន្លែងដែលអំពើហិង្សាកើតមានឡើង<br>( សូចនាករ SDG ៥.២.២ ; ទិន្នន័យមានក្នុងCDHS កុមារី និងស្ត្រីអាយុ១៥-៤៩ឆ្នាំ ) |
|---|---|
| និយមន័យ | ភាគរយនៃក្មេងជំទង់ស្រីប្រុស អាយុ ១៣-១៧ឆ្នាំ ដែលបានទទួលរងអំពើហិង្សាផ្លូវភេទ ក្នុងរយៈពេល១២ខែចុងក្រោយ។<br>សម្រាប់គោលបំណងនៃការបំបែកទិន្នន័យ ការផ្តល់យោបល់អំពីប្រភេទនៃអំពើហិង្សាផ្លូវភេទ (ដែលមិនចាំបាច់ត្រូវដាច់ដោយឡែកពីគ្នាទាំងស្រុង) អាចរួមមាន៖ (១) ការរួមភេទដោយបង្ខំ (បានសម្រេច) (២) ការរួមភេទក្រោមសម្ពាធ ឬ ការគំរាម (បានសម្រេច) (៣) ការប៉ុនប៉ងបង្ខំ គំរាម ឬ ដាក់សម្ពាធឱ្យរួមភេទ (ប៉ុន្តែមិនបានសម្រេច) (៤) ការប៉ះពាល់ផ្លូវភេទដែលគេមិនចង់ និងគ្មានការយល់ព្រមឱ្យប៉ះពាល់ (៥) សកម្មភាពគ្មានការប៉ះពាល់ដោយផ្ទាល់ ដូចជាការបៀតបៀនផ្លូវភេទដោយពាក្យសម្តី ការបង្ខំឱ្យដោះសម្លៀកបំពាក់ បង្ហាញរាងកាយ។ល។ (៦) ការលោភបំពានតាមអ៊ិនធឺណែត និង (៧) ការកេងប្រវ័ញ្ចផ្លូវភេទ (និយមន័យកំពុងត្រូវបានពិនិត្យសម្រេចក្នុងលក្ខណៈជាផ្នែកមួយនៃសូចនាករ SDG)។ |
| លទ្ធផលរំពឹងទុក (ផលប៉ះពាល់/គោលដៅ) | កុមារគ្រប់រូប រួមទាំងក្មេងជំទង់ ចម្រើនវ័យឡើងជាមួយនឹងការរួចផុតកាន់តែច្រើនឡើងពីអំពើហិង្សាគ្រប់ទម្រង់។ |
| វិធីសាស្ត្រគណនា | ភាគយក៖ ចំនួនកុមារី និងកុមារា អាយុ ១៣-១៧ឆ្នាំ ដែលរាយការណ៍ឱ្យដឹងថាធ្លាប់ទទួលរងអំពើហិង្សាផ្លូវភេទណាមួយ ក្នុងរយៈពេល១២ខែចុងក្រោយ<br>ភាគបែង៖ ចំនួនសរុបនៃអ្នកផ្តល់ចម្លើយ អាយុ ១៣-១៧ឆ្នាំ ដែលត្រូវបានសួរអំពីអំពើហិង្សាផ្លូវភេទ។<br>មេគុណ៖ ១០០ |
| ប្រភពទិន្នន័យ | CDHS |
| កម្រិតភាពញឹកញាប់ | CDHS: រៀងរាល់៥ឆ្នាំម្តង |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ទៅតាមភេទ និងអាយុរបស់កុមារ ទ្រព្យសម្បត្តិរបស់គ្រួសារ ប្រភេទ ចារី |
| ទីភ្នាក់ងារផ្តល់របាយការណ៍ | MoP/NIS |

| | |
|---|---|
| ឯកសារយោង | សូចនាករ INSPIRE ១.៤ |
| កំណត់សម្គាល់ | ត្រូវពិនិត្យផ្ទៀងផ្ទាត់ ថាតើគេអាចគណនាទិន្នន័យតាមរយៈកម្រងសំនួរ CDHS បច្ចុប្បន្នដែរឬទេ។<br>សូមមើលព័ត៌មានបន្ថែមនៅក្នុង INSPIRE ( សូចនាករ ១.៤ ) |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | សម្រាប់ទិន្នន័យ CDHS - Statcompiler គឺជាឧបករណ៍មួយដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចកសាងតារាង និងផែនទីទៅតាមដែលខ្លួនចង់បាន ពីសូចនាកររាប់ពាន់នៃប្រទេសចំនួន៩០។ STATcompiler មានគោលបំណងជួយដល់អ្នកប្រើប្រាស់ធ្វើការប្រៀបធៀបទិន្នន័យ DHS ទូទាំងបណ្តាប្រទេសនានា និងទៅតាមពេលវេលាផ្សេងៗគ្នា។ https://www.statcompiler.com/en/<br>ទិន្នន័យ DHS និងទិន្នន័យពីការអង្កេតស្រដៀងគ្នាដទៃទៀតពីជាង ៤០ប្រទេសសម្រាប់កុមារី និងពីជាង៧ប្រទេសសម្រាប់កុមារា អាចរកបានពីមូលដ្ឋានទិន្នន័យសកលរបស់អង្គការយូនីសេហ្វ ( https://data.unicef.org/topic/child-protection/violence/sexual-violence )។ ការប៉ាន់ប្រមាណថ្នាក់ជាតិ អាចរកបានពីមូលដ្ឋានទិន្នន័យ SDG ( https://unstats.un.org/sdgs/indicators/database )។ ទិន្នន័យ VACS ពីជាង៨ប្រទេស អាចរកបានពី CDC (www.cdc.gov/violenceprevention/childabuseandneglect/vacs/index.html )។ |

| ឈ្មោះសូចនាករ | ៥.១១ ភាគរយនៃស្ត្រី អាយុ១៨ ទៅ២៩ឆ្នាំដែលទទួលរងអំពើហិង្សាផ្លូវភេទត្រឹមអាយុ១៨ឆ្នាំ<br>( សូចនាករ SDG ១៦.២.៣ ភាគរយនៃស្ត្រី និងបុរសវ័យក្មេងអាយុ១៨ ទៅ២៩ឆ្នាំ ដែលទទួលរងអំពើហិង្សាផ្លូវភេទត្រឹមអាយុ១៨ឆ្នាំ; ទិន្នន័យមានក្នុង CDHS ស្ត្រីអាយុ១៨-២៩ឆ្នាំ ) |
|---|---|
| និយមន័យ | ភាគរយនៃស្ត្រី អាយុ ១៨-២៩ឆ្នាំ ដែលធ្លាប់ទទួលរងអំពើហិង្សាផ្លូវភេទមុន អាយុ ១៨ឆ្នាំ។<br>សម្រាប់គោលបំណងនៃការបំបែកទិន្នន័យ ការផ្តល់យោបល់អំពីប្រភេទនៃអំពើហិង្សាផ្លូវភេទ (ដែលមិនចាំបាច់ត្រូវដាច់ដោយឡែកពីគ្នាទាំងស្រុង ) អាចរួមមាន៖ ( ១ ) ការរួមភេទដោយបង្ខំ ( បានសម្រេច ) ( ២ ) ការរួមភេទក្រោមសម្ពាធ ឬ ការគំរាម ( បានសម្រេច ) ( ៣ ) ការប៉ុនប៉ងបង្ខំ គំរាម ឬ ដាក់សម្ពាធឱ្យរួមភេទ (ប៉ុន្តែមិនបានសម្រេច ) ( ៤ ) ការប៉ះពាល់ផ្លូវភេទដែលគេមិនចង់ និងគ្មានការយល់ព្រមឱ្យប៉ះពាល់ ( ៥ ) សកម្មភាពគ្មានការប៉ះពាល់ដោយផ្ទាល់ ដូចជាការបៀតបៀនផ្លូវភេទដោយពាក្យសម្តី ការបង្ខំឱ្យដោះសម្លៀកបំពាក់ បង្ហាញរាងកាយ។ល។ ( ៦ ) ការលោភបំពាន តាមអ៊ិនធឺណែត និង ( ៧ ) ការកេងប្រវ័ញ្ចផ្លូវភេទ ( និយមន័យកំពុងត្រូវបានពិនិត្យសម្រេច ក្នុងលក្ខណៈជាផ្នែកមួយនៃសូចនាករ SDG )។ |
| លទ្ធផលរំពឹងទុក<br>( ផលប៉ះពាល់/គោលដៅ ) | កុមារគ្រប់រូប រួមទាំងក្មេងជំទង់ ចម្រើនវ័យឡើងជាមួយនឹងការរួចផុតកាន់តែច្រើនឡើងពីអំពើហិង្សាគ្រប់ទម្រង់។ |
| វិធីសាស្ត្រគណនា | ភាគយក៖ ចំនួនស្ត្រី អាយុ ១៨-២៩ឆ្នាំ ដែលរាយការណ៍ឱ្យដឹងថាធ្លាប់ទទួលរងអំពើហិង្សាផ្លូវភេទណាមួយ កាលពីកុមារភាព មុនអាយុ១៨ឆ្នាំ<br>ភាគបែង៖ចំនួនសរុបនៃអ្នកផ្តល់ចម្លើយ អាយុ ១៨-២៩ឆ្នាំ ដែលត្រូវបានសួរអំពីអំពើហិង្សាផ្លូវភេទ។<br>មេគុណ៖ ១០០ |
| ប្រភពទិន្នន័យ | CDHS |
| កម្រិតភាពញឹកញាប់ | CDHS: រៀងរាល់៥ឆ្នាំ |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ភេទ អាយុ កម្រិតទ្រព្យសម្បត្តិ ប្រភេទ |
| ទីភ្នាក់ងារផ្តល់របាយការណ៍ | MoP/NIS |

| | |
|---|---|
| ឯកសារយោង | សមាមាត្រនៃស្ត្រី និងបុរសវ័យក្មេង អាយុ ១៨-២៩ឆ្នាំ ដែលធ្លាប់ទទួលរងអំពើហិង្សាផ្លូវភេទ មុនអាយុ១៨ឆ្នាំ ( សូចនាករ SDG ១៦.២.៣ )<br>សូចនាករស្នូលរបស់ Inspire ១.៣ – អំពើហិង្សាផ្លូវភេទក្នុងជីវិត កាលពីកុមារភាព |
| កំណត់សម្គាល់ | បច្ចុប្បន្ន CDHS មានទិន្នន័យនេះសម្រាប់ស្ត្រីអាយុ១៨-២៩ឆ្នាំ។ |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | សម្រាប់ទិន្នន័យ CDHS - Statcompiler គឺជាឧបករណ៍មួយដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចកសាងតារាង និងផែនទីទៅតាមដែលខ្លួនចង់បាន ពីសូចនាកររាប់ពាន់នៃប្រទេសចំនួន៩០។ STATcompiler មានគោលបំណងជួយដល់អ្នកប្រើប្រាស់ធ្វើការប្រៀបធៀបទិន្នន័យ DHS ទូទាំងបណ្តាប្រទេសនានា និងទៅតាមពេលវេលាផ្សេងៗគ្នា។ https://www.statcompiler.com/en/<br>ទិន្នន័យ DHS និងទិន្នន័យពីការអង្កេតស្រដៀងគ្នាដទៃទៀតពីជាង ៤០ប្រទេសសម្រាប់កុមារី និងពីជាង៧ប្រទេសសម្រាប់កុមារា អាចរកបានពីមូលដ្ឋានទិន្នន័យសកលរបស់អង្គការយូនីសេហ្វ ( https://data.unicef.org/topic/child-protection/violence/sexual-violence )។ ការប៉ាន់ប្រមាណថ្នាក់ជាតិ អាចរកបានពីមូលដ្ឋានទិន្នន័យ SDG ( https://unstats.un.org/sdgs/indicators/database )។ ទិន្នន័យ VACS ពីជាង៨ប្រទេស អាចរកបានពី CDC ( www.cdc.gov/violenceprevention/childabuseandneglect/vacs/index.html )។ |

| ឈ្មោះសូចនាករ | **៥.១២ ភាគរយនៃស្ត្រី និងកុមារីអាយុចាប់ពី១៥ឆ្នាំឡើងទៅ ដែលធ្លាប់មានដៃគូ បានទទួលរងអំពើហិង្សាផ្លូវកាយ និង/ឬ ផ្លូវភេទ ពីសំណាក់ដៃគូបច្ចុប្បន្ន ឬ ដៃគូអតីតក្នុងរយៈពេល១២ខែចុងក្រោយ**<br>(**សូចនាករ** SDG **៥.២.១ ; ទិន្នន័យមានក្នុង**CDHS **ស្ត្រី និងកុមារីអាយុ១៥-៤៩ឆ្នាំ ដែលរៀបការហើយ ធ្លាប់ទទួលរងអំពើហិង្សាផ្លូវកាយ ផ្លូវភេទ និងផ្លូវចិត្ត កន្លងមក និងក្នុងរយៈពេល១២ខែចុងក្រោយ**) |
|---|---|
| និយមន័យ | ភាគរយនៃក្មេងស្រីជំទង់ធ្លាប់មានដៃគូ អាយុ ១៥-១៩ឆ្នាំ ដែលបានទទួលរងអំពើហិង្សាផ្លូវកាយ និង/ឬ ផ្លូវភេទ ដោយដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬ អតីត ក្នុងរយៈពេល១២ខែកន្លងមក។<br>ចំនួនក្មេងស្រីជំទង់ធ្លាប់មានដៃគូ អាយុ ១៥-១៩ឆ្នាំ ដែលរាយការណ៍ឱ្យដឹងថាបានទទួលរងអំពើហិង្សាផ្លូវកាយ និង/ឬ ផ្លូវភេទ ដោយដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬ អតីតក្នុងរយៈពេល១២ខែកន្លងមក ដោយបង្ហាញជាភាគរយនៃក្មេងស្រីជំទង់ធ្លាប់មានដៃគូ អាយុ ១៥-១៩ឆ្នាំទាំងអស់ ដែលត្រូវបានសួរអំពីបញ្ហាអំពើហិង្សាពីដៃគូ។ ចន្លោះអាយុគឺអាស្រ័យលើអ្វីដែលមានភាពពាក់ព័ន្ធ ក្រមសីលធម៌ លទ្ធភាពអាចទៅរួច/អ្វីដែលមានសម្រាប់ប្រទេស។ គិតត្រឹមដើមឆ្នាំ ២០១៨ និយមន័យប្រតិបត្តិរបស់ SDG មិនទាន់ត្រូវបានពិនិត្យសម្រេចនៅឡើយ ប៉ុន្តែវាទំនងនឹងអនុវត្តតាមនិយមន័យដែលត្រូវបានប្រើប្រាស់នៅក្នុងការអង្កេត DHS និងការអង្កេត MCS របស់ WHO។ ការអង្កេតទាំងនេះ កំណត់និយមន័យពាក្យ **ដៃគូស្និទ្ធស្នាល** ថាជាប្តី ឬ ដៃគូរស់នៅជាមួយគ្នា លើកលែងតែក្នុងបរិបទដែលដៃគូរួមភេទដែលមានលក្ខណៈ "ជាប់លាប់" យូរអង្វែង និងរស់នៅជាមួយគ្នាដូចជាប្តីប្រពន្ធ គឺជារឿងទូទៅ និងមានភាពពាក់ព័ន្ធផ្នែកវប្បធម៌។ ក្មេងស្រីជំទង់**ដែលធ្លាប់មានដៃគូ** សំដៅចំពោះក្មេងស្រីដែលធ្លាប់មានដៃគូបែបនេះ។ DHS និង WHO MCS វាស់វែងទៅលើអំពើហិង្សាពីដៃគូ ដោយប្រើប្រាស់សំនួរដែលចារី (ដៃគូ) និងលក្ខណៈជាក់លាក់នៃការប្រព្រឹត្ត រួមទាំងសកម្មភាពនៃអំពើហិង្សាផ្លូវកាយ ដែលត្រូវបានកែសម្រួលយកលំនាំតាមពី ជម្លោះ តាក់ទិច វិសាលភាព (Conflicts Tactics Scale), និងសកម្មភាពនៃអំពើហិង្សាផ្លូវភេទ ដូចជាការរួមភេទដោយបង្ខំ និងក្រោមការគំរាម ព្រមទាំងសកម្មភាពផ្លូវភេទដទៃទៀត ប៉ុន្តែ មិនមែនជាការប៉ុនប៉ងធ្វើសកម្មភាពផ្លូវភេទ (មិនបានសម្រេច) ឬ ការប៉ះពាល់ផ្លូវភេទដែលគេមិនចង់ឱ្យប៉ះពាល់នោះទេ។ សូចនាករនេះ ផ្តោតចំពោះតែអំពើហិង្សាផ្លូវកាយ និង/ឬ ផ្លូវភេទប៉ុណ្ណោះ (សូចនាកររងទី ៤) ដោយសារតែកង្វះវិធានការ និងនិយមន័យនៃអំពើហិង្សាផ្លូវចិត្តពីដៃគូស្និទ្ធស្នាលដែលអាចយកមកធ្វើការប្រៀបធៀបគ្នាបាននៅកម្រិតអន្តរជាតិ។ (inspire) |

| | |
|---|---|
| លទ្ធផលរំពឹងទុក (ផលប៉ះពាល់/គោលដៅ) | កុមារគ្រប់រូប រួមទាំងក្មេងជំទង់ ចម្រើនវ័យឡើងជាមួយនឹងការរួចផុតកាន់តែច្រើនឡើងពីអំពើហិង្សាគ្រប់ទម្រង់។ |
| វិធីសាស្រ្តគណនា | ភាគយក៖ ចំនួនក្មេងស្រីជំទង់ធ្លាប់មានដៃគូ អាយុ ១៥-១៩ឆ្នាំ ដែលរាយការណ៍ឱ្យដឹងថាធ្លាប់ទទួលរងអំពើហិង្សាផ្លូវកាយ ឬ ផ្លូវភេទ ពីដៃគូស្និទ្ធស្នាល ក្នុងរយៈពេល ១២ខែចុងក្រោយ<br>ភាគបែង៖ចំនួនសរុបនៃក្មេងជំទង់ធ្លាប់មានដៃគូ អាយុ ១៥-១៩ឆ្នាំ ដែលត្រូវបានសួរអំពីអំពើហិង្សាពីដៃគូស្និទ្ធស្នាល។<br>មេគុណ៖ ១០០ |
| ប្រភពទិន្នន័យ | CDHS |
| កម្រិតភាពញឹកញាប់ | CDHS: រៀងរាល់៥ឆ្នាំ |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ទៅតាមភេទ និងអាយុ កម្រិតទ្រព្យសម្បត្តិ ប្រភេទ ចារី |
| ទីភ្នាក់ងារផ្តល់របាយការណ៍ | MoP/NIS |
| ឯកសារយោង | សូចនាករ SDG ៥.២.១ (សម្រាប់អាយុ ១៥ឆ្នាំឡើងទៅ)<br>សូចនាករស្នូលរបស់ Inspire ១.៥ |
| កំណត់សម្គាល់ | បច្ចុប្បន្នCDHS មានទិន្នន័យនេះ ស្ត្រី និងកុមារីអាយុ១៥-៤៩ឆ្នាំដែលរៀបការហើយធ្លាប់ទទួលរងអំពើហិង្សាផ្លូវកាយ ផ្លូវភេទ និងផ្លូវចិត្ត កន្លងមក និងក្នុងរយៈពេល១២ខែចុងក្រោយ) |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | សម្រាប់ទិន្នន័យ CDHS - Statcompiler គឺជាឧបករណ៍មួយដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចកសាងតារាង និងផែនទីទៅតាមដែលខ្លួនចង់បាន ពីសូចនាកររាប់ពាន់នៃប្រទេសចំនួន៩០។ STATcompiler មានគោលបំណងជួយដល់អ្នកប្រើប្រាស់ធ្វើការប្រៀបធៀបទិន្នន័យ DHS ទូទាំងបណ្តាប្រទេសនានា និងទៅតាមពេលវេលាផ្សេងៗគ្នា។ https://www.statcompiler.com/en/<br>ការប៉ាន់ប្រមាណដែលតំណាងឱ្យទូទាំងប្រទេស អាចរកបានសម្រាប់ជាង៥៤ប្រទេស ពីមូលដ្ឋានទិន្នន័យសកលរបស់អង្គការយូនីសេហ្វ (https://data.unicef.org/topic/child-protection/violence/violent-unions/#) |

| ឈ្មោះសូចនាករ | ៥.១៣ ភាគរយនៃស្ត្រីដែលបានរៀបអាពាហ៍ពិពាហ៍ក្នុងវ័យកុមារ<br>ក) ភាគរយនៃស្ត្រីអាយុចន្លោះពី២០-២៥ឆ្នាំ ដែលបានរៀបការដំបូង ឬរួមរស់ជាមួយដៃគូ មុនអាយុ ១៨ឆ្នាំ និង<br>ខ) ភាគរយនៃស្ត្រីអាយុចន្លោះពី២០-២៥ឆ្នាំ ដែលបានរៀបការដំបូង ឬរួមរស់ជាមួយដៃគូ មុនអាយុ ១៥ឆ្នាំ |
|---|---|
| និយមន័យ | ភាគរយនៃស្ត្រីអាយុ ២០-២៤ ឆ្នាំ ដែលបានរៀបអាពាហ៍ពិពាហ៍ ឬ រួមរស់ជាមួយគ្នាលើកដំបូង មុនអាយុ ១៨ឆ្នាំ និង ១៥ឆ្នាំ។<br>ចំនួនស្ត្រីអាយុ ២០-២៤ ឆ្នាំ ដែលបានចាប់ផ្តើមរួមរស់ជាមួយស្វាមី ឬ ដៃគូរួមរស់របស់ពួកគេលើកដំបូង មុនអាយុ ១៥ឆ្នាំ និង ១៨ឆ្នាំ ដោយបង្ហាញជាភាគរយនៃស្ត្រីគ្រប់រូបអាយុ ២០-២៤ ឆ្នាំ។ យោងតាមនិយមន័យនៃសូចនាករ SDG អាពាហ៍ពិពាហ៍ (ក៏ត្រូវបានសំដៅហៅផងដែរថាជា "ការរួមរស់ជាមួយគ្នា") ត្រូវបានកំណត់និយមន័យថាជាអាពាហ៍ពិពាហ៍ផ្លូវការ និងមិនផ្លូវការ (ការរួមរស់ជាមួយគ្នា) ដែលគូស្វាមីភរិយារស់នៅជាមួយគ្នាក្នុងទំនាក់ទំនងស្និទ្ធស្នាល សម្រាប់រយៈពេលណាមួយ និងមានបំណងចង់មានទំនាក់ទំនងយូរអង្វែង ប៉ុន្តែមិនទាន់មានពិធីចុះបញ្ជីអត្រានុកូលដ្ឋាន ឬ ពិធីតាមបែបសាសនាជាផ្លូវការណាមួយនៅឡើយ។ ព័ត៌មានបន្ថែមទៀតអំពីនិយមន័យប្រតិបត្តិរបស់ SDG អាចរកបានពីកន្លែងតម្កល់កម្រងទិន្នន័យរបស់ SDG (https://unstats.un.org/sdgs/metadata)។ |
| លទ្ធផលរំពឹងទុក (ផលប៉ះពាល់/គោលដៅ) | វត្តមាន និងលទ្ធផលរៀនសូត្ររបស់កុមារ និងក្មេងជំទង់នៅឯសាលា មានការកើនឡើងពន្យារពេលរៀបអាពាហ៍ពិពាហ៍ក្នុងវ័យកុមារ និងការឆាប់មានកូនក្នុងវ័យក្មេង កសាងឱ្យមានទំនាក់ទំនងប្រកបដោយសមធម៌យេនឌ័រ និងអហិង្សា និងកាត់បន្ថយការប្រព្រឹត្តប្រកបដោយហានិភ័យ ដូចជាការប្រើប្រាស់បំពានគ្រឿងញៀន។ មានភស្តុតាងដែលមានទំនាក់ទំនងទៅនឹងការឆាប់មានផ្ទៃពោះក្នុងវ័យក្មេង ការរស់នៅដាច់ដោយឡែកពីសង្គម ការកាត់សង្វាក់ការរៀនសូត្រនៅឯសាលារៀន ឱកាសការងារមានកម្រិត និងហានិភ័យនៃអំពើហិង្សាពីដៃគូស្និទ្ធស្នាលមានការកើនឡើង (Inspire) |

| | |
|---|---|
| វិធីសាស្ត្រគណនា | អាពាហ៍ពិពាហ៍មុនអាយុ ១៥ឆ្នាំ<br>ភាគយក៖ ចំនួនស្ត្រី អាយុ ២០-២៤ឆ្នាំ ដែលបានរៀបអាពាហ៍ពិពាហ៍ ឬរួមរស់ជាមួយគ្នា មុនអាយុ១៥ឆ្នាំ<br>ភាគបែង៖ ចំនួនស្ត្រីសរុប អាយុ ២០-២៤ឆ្នាំ<br>មេគុណ៖ ១០០<br>អាពាហ៍ពិពាហ៍មុនអាយុ ១៨ឆ្នាំ<br>ភាគយក៖ ចំនួនស្ត្រី អាយុ ២០-២៤ឆ្នាំ ដែលបានរៀបអាពាហ៍ពិពាហ៍ ឬរួមរស់ជាមួយគ្នា មុនអាយុ១៨ឆ្នាំ<br>ភាគបែង៖ ចំនួនស្ត្រីសរុប អាយុ ២០-២៤ឆ្នាំ<br>មេគុណ៖ ១០០ |
| ប្រភពទិន្នន័យ | CDHS |
| កម្រិតភាពញឹកញាប់ | CDHS: រៀងរាល់៥ឆ្នាំ |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ទៅតាមភេទ និងអាយុ |
| ទីភ្នាក់ងារផ្តល់របាយការណ៍ | MoP/NIS |
| ឯកសារយោង | សូចនាករស្នូល Inspire ៩.៥ |
| កំណត់សម្គាល់ | |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | មូលដ្ឋានទិន្នន័យរបស់អង្គការយូនីសេហ្វ តាមដានទិន្នន័យសម្រាប់សូចនាករនេះ ចំពោះប្រទេសដែលមានប្រាក់ចំណូលទាប និងមធ្យម ជាង១២០ប្រទេស (https://data.unicef.org/topic/child-protection/child-marriage)<br>សម្រាប់ទិន្នន័យ CDHS - Statcompiler គឺជាឧបករណ៍មួយដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចកសាងតារាង និងផែនទីទៅតាមដែលខ្លួនចង់បាន ពីសូចនាកររាប់ពាន់នៃប្រទេសចំនួន៩០។ STATcompiler មានគោលបំណងជួយដល់អ្នកប្រើប្រាស់ធ្វើការប្រៀបធៀបទិន្នន័យ DHS ទូទាំងបណ្តាប្រទេសនានា និងទៅតាមពេលវេលាផ្សេងៗគ្នា។ https://www.statcompiler.com/en/ |

| ឈ្មោះសូចនាករ | ៥.១៤ ភាគរយនៃកុមារអាយុចន្លោះពី ៥-១៧ឆ្នាំ ដែលកំពុងធ្វើពលកម្មកុមាររាប់បញ្ចូលពលកម្មក្នុងទម្រង់គ្រោះថ្នាក់ផងដែរ (សូចនាករ SDG ៨.៧.១) |
|---|---|
| និយមន័យ | ពលកម្មកុមារ គឺជាការងារទាំងឡាយណា ដែលកុមារចូលរួមធ្វើក្នុងសកម្មភាពសេដ្ឋកិច្ច ទោះបីបានកម្រៃ ឬមិនបានកម្រៃ អោយតែការងារនោះអាចបណ្តាលប៉ះពាល់ដល់សុខភាព រាងកាយ ស្មារតី ចិត្តគំនិត សិលធ៌ម និងការអប់រំរបស់កុមារ។ គួរកត់សម្គាល់ថា គ្រប់ការងារដែលកុមារធ្វើមិនមែនសុទ្ធតែជាពលកម្មកុមារនោះទេ។<br><br>យោងច្បាប់ស្តីពីការងារ(១៩៩៧) មាត្រា១៧៧ កថាខណ្ឌទី៤ ក្មេងមានអាយុ១២ដល់ ១៥ឆ្នាំ អាចអនុញ្ញាតអោយធ្វើតែការងារស្រាលៗ មិនប៉ះពាល់ដល់សុខភាព។ អាយុអប្បបរមាអាចចូលធ្វើការជាកម្មករនិយោជិត ត្រូវកំណត់ត្រឹម១៥ឆ្នាំ។ ចំពោះការងារប្រកបដោយគ្រោះថ្នាក់ត្រូវកំណត់ត្រឹម១៨ឆ្នាំ។ អនុសញ្ញាលេខ១៣៨ ស្តីពីការកំរិតអាយុអប្បបរមាសំរាប់ការចូលធ្វើការងារ ត្រង់មាត្រា៣បានចែងអំពី ប្រភេទ និងលក្ខណ្ឌការងារដែលកុមារធ្វើ។<br><br>បើទោះជាដូច្នេះក្តី អាទិភាពគឺសំដៅលុបបំបាត់ដោយគ្មានការពន្យារពេលនូវទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ដូចមានកំណត់ចែងនៅក្នុងមាត្រា ៣ នៃអនុសញ្ញាអង្គការ ILO លេខ ១៨៖ "ពលកម្មដែលបង្កឱ្យមានគ្រោះថ្នាក់ដល់សុខុមាលភាពផ្លូវកាយ ផ្លូវចិត្ត និងសីលធម៌របស់កុមារ ដោយសារតែចរិកលក្ខណៈនៃការងារពលកម្មនោះ ឬ ដោយសារលក្ខខណ្ឌនៃការធ្វើការងារពលកម្មនោះ" (ត្រូវបានគេហៅថា "ការងារប្រកបដោយគ្រោះថ្នាក់" ផងដែរ)។ |
| លទ្ធផលរំពឹងទុក (ផលប៉ះពាល់/គោលដៅ) | • កុមារ និងយុវជនវ័យក្មេងទទួលបានសិទ្ធិជាមូលដ្ឋាន<br>• សក្តានុពលនៃការអភិវឌ្ឍរបស់កុមារនាពេលអនាគត និងការផ្តល់ឱកាសការងារសមរម្យសម្រាប់ពួកគេ។ |
| វិធីសាស្រ្តគណនា | ភាគយក៖ ចំនួនកុមារអាយុ ៥-១៧ឆ្នាំ ដែលត្រូវបានរាយការណ៍ឱ្យដឹងថាជាពលករកុមារ<br>ភាគបែង៖ ចំនួនកុមារសរុប អាយុ ៥-១៧ឆ្នាំ<br>មេគុណ៖ ១០០ |
| ប្រភពទិន្នន័យ | CSES, កំណត់ហេតុរដ្ឋបាល |
| កម្រិតភាពញឹកញាប់ | រៀងរាល់២ឆ្នាំម្តង |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ទៅតាមភេទ និងអាយុ ទម្រង់នៃការងារពលកម្ម ខេត្ត |
| ទីភ្នាក់ងារផ្តល់របាយការណ៍ | MoP/NIS , Ministry of Labour and Vocational Training |
| ឯកសារយោង | សូចនាករ SDG ៨.៧.១ |
| កំណត់សម្គាល់ | |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | |

| ឈ្មោះសូចនាករ | ៥.១៥ ចំនួនកុមារកំពុងជាប់ឃុំក្នុងពន្ធនាគារ ក្នុងចំណោមកុមារ ១០០.០០០នាក់ រាប់បញ្ចូលទាំងកុមារជាប់ឃុំបណ្តោះអាសន្នផងដែរ |
|---|---|
| និយមន័យ | ចំនួនកុមារី និងកុមារាអាយុក្រោម១៨ឆ្នាំ ដែលកំពុងជាប់ឃុំ ក្នុងចំណោមកុមារ ១០០.០០០នាក់។<br>សូចនាករនេះផ្តល់ព័ត៌មានអំពីចំនួនកុមារជាប់ឃុំ ធៀបនឹងចំនួនកុមារជារួម។ ក្នុងនោះ រួមមានកុមារជាប់ឃុំបណ្តោះអាសន្នមុនពេលជំនុំជម្រះ មុនពេលកាត់ទោស និងក្រោយពេលកាត់ទោស នៅក្នុងគ្រប់ប្រភេទកន្លែងឃុំឃាំងទាំងអស់ (រាប់បញ្ចូលទាំងកន្លែងឃុំឃាំងរបស់នគរបាល) (អង្គការ UNODC)។ ប្រភពព័ត៌មានបឋម ទំនងជាកន្លែងឃុំឃាំង។ កន្លែងឃុំឃាំង គប្បីរក្សាកំណត់ហេតុកុមារគ្រប់រូបដែលបាត់បង់សេរីភាពនៅក្នុងកន្លែងឃុំឃាំងនោះ។ សកម្មភាពនេះគប្បីអនុវត្តចំពោះកន្លែងឃុំឃាំងទាំងអស់ រួមទាំងប៉ុស្តិ៍នគរបាល ដែលមានបន្ទប់ឃុំឃាំង មណ្ឌលឃុំឃាំងបណ្តោះអាសន្ន ពន្ធនាគារ និងមណ្ឌលស្តារនីតិសម្បទាដែលមានសន្តិសុខសុវត្ថិភាព។ (UNODC)<br>**អាជ្ញាធរមានសមត្ថកិច្ច** គឺជាផ្នែកមួយនៃយុត្តិធម៌អនីតិជន ឬ ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ដែលទទួលខុសត្រូវក្នុងការធ្វើសេចក្តីសម្រេចចិត្តខាងនីតិវិធី ឬ ការរៀបចំទុកដាក់ទាក់ទងនឹងសំណុំរឿងរបស់កុមារ។ (UNODC) |
| លទ្ធផលរំពឹងទុក (ផលប៉ះពាល់/គោលដៅ) | ដើម្បីវាស់វែងការប្រែប្រួលចំនួនកុមារជាប់ឃុំ។ បទដ្ឋានអន្តរជាតិចែងច្បាស់ថា ការឃុំខ្លួនកុមារត្រូវប្រើប្រាស់ជាវិធានការចុងក្រោយប៉ុណ្ណោះ និងមានភស្តុតាងឱ្យដឹងថា កុមារជាប់ឃុំមានភាពងាយរងគ្រោះកាន់តែខ្ពស់ទៅនឹងការរំលោភបំពាន។ ដូច្នេះការកាត់បន្ថយចំនួនកុមារជាប់ឃុំ គឺជាលទ្ធផលរំពឹងទុកមួយនៃយុទ្ធសាស្ត្រ INSPIRE។ |
| វិធីសាស្ត្រគណនា | ភាគយក៖ ចំនួនកុមារី និងកុមារាអាយុក្រោម១៨ឆ្នាំ ជាប់ឃុំនៅកាលបរិច្ឆេទជាក់លាក់មួយ<br>ភាគបែង៖ ចំនួនកុមារី និងកុមារាសរុប ដែលមានអាយុក្រោម១៨ឆ្នាំ គិតត្រឹមកាលបរិច្ឆេទជាក់លាក់មួយ<br>មេគុណ៖ ១០០.០០០ |
| ប្រភពទិន្នន័យ | ប្រព័ន្ធទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធនាគារ |
| កម្រិតភាពញឹកញាប់ | រៀងរាល់ឆ្នាំ |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ទៅតាមភេទ ក្រុមអាយុ មុនពេល និងក្រោយពេលកាត់ទោស ជាតិពន្ធុ ប្រភេទនៃបទល្មើស ប្រភេទកន្លែងឃុំឃាំង។ |

| | |
|---|---|
| ទីភ្នាក់ងារផ្ដល់របាយការណ៍ | MoI/អគ្គនាយកដ្ឋានពន្ធនាគារ |
| ឯកសារយោង | សូចនាករ INSPIRE ៨.៩<br>ការអង្កេតរបស់អង្គការសហប្រជាជាតិស្តីពីនិន្នាការឧក្រិដ្ឋកម្ម និងប្រតិបត្តិការរបស់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ (UN-CTS) (www.unodc.org/unodc/en/data-and-analysis/United-Nations-Surveys-on-Crime-Trends-and-the-Operations-of-Criminal-Justice-Systems.html)<br>UNODC ប្រមូលទិន្នន័យជាតិអំពីចំនួនកុមារដែលជាប់ឃុំនៅក្នុងពន្ធនាគារ មណ្ឌលឃុំឃាំង និងមណ្ឌលកែប្រែ ដោយបែងចែកទៅតាមភេទ។ |
| កំណត់សម្គាល់ | |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | អង្គការ UNODC ត្រួតពិនិត្យចំនួនកុមារជាប់ឃុំ ដោយបែងចែកទៅតាមភេទ នៅក្នុងប្រទេសជាង១៣០ (https://data.unodc.org). អង្គការយូនីសេហ្វ ក៏កំពុងចងក្រងទិន្នន័យទាំងនេះទៅក្នុងមូលដ្ឋានទិន្នន័យសកលផងដែរ។ |

| ឈ្មោះសូចនាករ | ៥.១៦ ចំនួនកូននៅជាមួយឪពុកម្ដាយក្នុងពន្ធនាគារ |
|---|---|
| និយមន័យ | ចំនួនកុមារដែលបានតាមឪពុកម្ដាយ ជាពិសេសម្ដាយដែលជាប់ឃុំនៅក្នុងពន្ធនាគារ ដោយកុមារគ្មានអ្នកមើលថែនៅខាងក្រៅ |
| លទ្ធផលរំពឹងទុក | តាមដានកុមារដែលលូតលាស់នៅក្នុងបរិស្ថានដែលមិនអំណោយផលដល់ការលូតលាស់របស់ពួកគេនិងដើម្បីផ្ដល់សេវាកម្ម |
| វិធីសាស្ត្រគណនា | រាប់ចំនួនកុមារទាំងអស់ដែលស្ថិតក្នុងពន្ធនាគារដោយសារស្ថានភាពរបស់ឪពុកម្ដាយ / អ្នកថែទាំ |
| ប្រភពទិន្នន័យ | ប្រព័ន្ធទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធនាគារ |
| កម្រិតភាពញឹកញាប់ | រៀងរាល់ឆ្នាំ |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ទៅតាមភេទ ក្រុមអាយុ |
| ទីភ្នាក់ងារទទួលខុសត្រូវរាយការណ៍អំពីទិន្នន័យ | MoI ( អគ្គនាយកដ្ឋានពន្ធនាគារ ) |
| ឯកសារយោង | |
| កំណត់សម្គាល់ | |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | |

| ឈ្មោះសូចនាករ | ៥.១៧ ចំនួនកុមារដែលរងរបួស ពិការ ឬ ស្លាប់ដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម(ERW) |
|---|---|
| និយមន័យ | ចំនួនកុមារអាយុពី០-១៧ ឆ្នាំដែលរងរបួស ពិការ ឬ ស្លាប់ដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម(ERW) |
| លទ្ធផលរំពឹងទុក | ដើម្បីតាមដានផលប៉ះពាល់នៃមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម(ERW) ដើម្បីអភិវឌ្ឍកម្មវិធីបង្ការភាពរងគ្រោះ |
| វិធីសាស្រ្តគណនា | ចំនួនកុមារសរុបដែលបានរងរបួស ពិការ ឬ ស្លាប់ដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម(ERW) |
| ប្រភពទិន្នន័យ | ទិន្នន័យអាជ្ញាធរមីន (CMAA-CMVIS) |
| កម្រិតភាពញឹកញាប់ | រៀងរាល់ឆ្នាំ |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ទៅតាមភេទ អាយុ ខេត្ត ពិការភាព មូលហេតុនៃគ្រោះថ្នាក់ |
| ទីភ្នាក់ងារទទួលខុសត្រូវរាយការណ៍អំពីទិន្នន័យ | អាជ្ញាធរមីន (CMAA) |
| ឯកសារយោង | របាយការណ៍ប្រចាំខែ/ឆ្នាំរបស់ CMVIS |
| កំណត់សម្គាល់ | |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | |

| ឈ្មោះសូចនាករ | **៥.១៨ ចំនួនកុមាររងគ្រោះដោយមនុស្សឃាតដោយចេតនា ក្នុងចំណោមកុមារ ១០០.០០០នាក់ (អត្រាមនុស្សឃាត)** <br> **(ទាក់ទងនឹងសូចនាករ SDG ១៦.១.១ ចំនួនជនរងគ្រោះដោយសារការធ្វើឃាតដោយចេតនា ក្នុងចំណោមប្រជាជន ១០០.០០០នាក់ បែងចែកតាម ភេទ និងអាយុ; មានទិន្នន័យកុមារ និងក្មេងជំទង់០-១៩ ឆ្នាំ WHO,២០១៦/CP Profile)** |
|---|---|
| និយមន័យ | ចំនួនជនរងគ្រោះនៃករណីមនុស្សឃាតដោយចេតនា ដែលត្រូវបានកត់ត្រានៅក្នុងឆ្នាំប្រតិទិនមួយដែល ក្នុងចំណោមប្រជាជនចំនួន ១០០.០០០នាក់ ក្នុងឆ្នាំដដែលនោះ។ និយមន័យយុត្តិធម៌ព្រហ្មទណ្ឌ នៃមនុស្សឃាតដោយចេតនាគឺជា "មរណភាពដោយខុសច្បាប់ដែលបង្កឡើងទៅលើមនុស្សម្នាក់ [ដោយចារីម្នាក់] ក្នុងចេតនាបង្កការស្លាប់ ឬ របួសធ្ងន់ធ្ងរ"។ ករណីដែលចារីគ្រាន់តែធ្វេសប្រហែស ឬ មិនបានប្រយ័ត្ន មិនត្រូវបានរាប់បញ្ចូលទេឡើយ និងដូចគ្នាផងដែរទៅនឹងករណីការពារខ្លួន។ មនុស្សឃាតក៏រួមមានផងដែរនូវករណីដែលត្រូវបានកំណត់នៅក្នុងប្រព័ន្ធសុខភាពសាធារណៈ ឬ |
| | ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន ថាជា "ការស្លាប់ដោយការបំពារបំពាន" ដូចមានកំណត់និយមន័យ ដោយការចាត់ចំណាត់ថ្នាក់ជំងឺអន្តរជាតិ (International Classification of Diseases) (ICD-១០)។ សម្រាប់ព័ត៌មានបន្ថែម សូមមើលកម្រងទិន្នន័យ SDG (https://unstats.un.org/sdgs/metadata)។ (សូចនាករ INSPIRE ៥.២) |
| លទ្ធផលរំពឹងទុក | លំហរសុវត្ថិភាពសម្រាប់កុមារ |
| វិធីសាស្ត្រគណនា | ចំនួនកុមាររងគ្រោះនៃករណីមនុស្សឃាតដោយចេតនា ដែលត្រូវបានកត់ត្រានៅក្នុងឆ្នាំណាមួយ ដោយចែកទៅនឹងចំនួនកុមារសរុបនៅក្នុងឆ្នាំដដែលនោះ គុណនឹង ១០០.០០០។ |
| ប្រភពទិន្នន័យ | ប្រព័ន្ធទិន្នន័យអគ្គស្នងការនគរបាលជាតិ នាយកដ្ឋានព្រហ្មទណ្ឌ |
| កម្រិតភាពញឹកញាប់ | រៀងរាល់ឆ្នាំ |

| | |
|---|---|
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ទៅតាមភេទរបស់ជនរងគ្រោះ ក្រុមអាយុ ប្រភេទនៃទំនាក់ទំនងរវាងចារី និងជនរងគ្រោះ |
| ទីភ្នាក់ងារផ្ដល់របាយការណ៍ | MoI/នាយកដ្ឋានព្រហ្មទណ្ឌ |
| ឯកសារយោង | សូចនាករ SDG ១៦.១.១; សូចនាករ Inspire ៥.១<br>ចំនួនជនរងគ្រោះ នៃករណីមនុស្សឃាតដោយចេតនា ក្នុងចំណោមប្រជាជន ១00.000នាក់ ដោយបែងចែកទៅតាមភេទ និងអាយុ។ |
| កំណត់សម្គាល់ | មានទិន្នន័យកុមារ និងក្មេងជំទង់0-១៩ ឆ្នាំ WHO,២០១៦/CP Profile<br>បច្ចុប្បន្ន CPU មានទិន្នន័យមួយចំនួនអំពីបញ្ហានេះ។ |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | ទិន្នន័យអំពីមូលហេតុនាំការស្លាប់ ដោយបែងចែកទៅតាមភេទ និងអាយុ អាចរកបានពីមូលដ្ឋានទិន្នន័យស្ដីពីមរណភាពរបស់ WHO (www.who.int/healthinfo/mortality_data/en)។ ការប៉ាន់ប្រមាណជាតិអំពីករណីមនុស្សឃាត (គ្រប់វ័យ) សម្រាប់ជាង ១៧០ប្រទេស អាចរកបានពីអង្គការ UNODC (https://data.unodc.org/?lf=១&lng=en) និងមូលដ្ឋានទិន្នន័យសកលរបស់ SDG (https://unstats.un.org/sdgs/indicators/database)។ |

| ឈ្មោះសូចនាករ | ៥.១៩ ភាគរយនៃស្ត្រី និងកុមារីមានកូនក្នុងវ័យកុមារ<br>ក ) ភាគរយនៃស្ត្រីនិងកុមារីអាយុចន្លោះ១៥-១៩ឆ្នាំដែលបានសំរាលកូន<br>ខ ) ភាគរយនៃស្ត្រីអាយុចន្លោះ២០-២៤ឆ្នាំដែលបានសំរាលកូនមុនអាយុ ១៨ឆ្នាំ |
|---|---|
| និយមន័យ | ចំនួនក្មេងស្រីជំទង់ អាយុ ១៥-១៩ឆ្នាំ ដែលធ្លាប់បានផ្តល់កំណើតរស់ ដោយបង្ហាញជាភាគរយនៃក្មេងស្រីជំទង់ទាំងអស់ អាយុ ១៥-១៩ឆ្នាំ។<br>ចំនួនស្ត្រី អាយុ ២០-២៤ឆ្នាំ ដែលធ្លាប់បានផ្តល់កំណើតរស់ចំនួន១ មុនអាយុ១៨ឆ្នាំ ដោយបង្ហាញជាភាគរយនៃក្មេងស្រីជំទង់ទាំងអស់ អាយុ ២០-២៤ឆ្នាំ។ |
| លទ្ធផលរំពឹងទុក ( លទ្ធផលរយៈពេលមធ្យម ) | វត្តមាន និងលទ្ធផលរៀនសូត្ររបស់កុមារ និងក្មេងជំទង់នៅឯសាលា មានការកើនឡើង ពន្យារពេលរៀបអាពាហ៍ពិពាហ៍ក្នុងវ័យកុមារ និង ការឆាប់មានកូនក្នុងវ័យក្មេង កសាងឱ្យមានទំនាក់ទំនងប្រកបដោយសមធម៌យេនឌ័រ និងអហិង្សា, និងកាត់បន្ថយការប្រព្រឹត្តប្រកបដោយហានិភ័យ ដូចជាការប្រើប្រាស់បំពានគ្រឿងញៀន។ ( inspire ) |
| វិធីសាស្ត្រគណនា | ភាគយក៖ ចំនួនក្មេងស្រីជំទង់ អាយុ ១៥-១៩ឆ្នាំ ដែលយ៉ាងហោចណាស់ធ្លាប់បានផ្តល់កំណើតរស់ចំនួន១<br>ភាគបែង៖ ចំនួនក្មេងស្រីជំទង់សរុប អាយុ ១៥-១៩ឆ្នាំ<br>មេគុណ៖ ១០០<br>ផ្តល់កំណើតមុនអាយុ ១៨ឆ្នាំ<br>ភាគយក៖ ចំនួនស្ត្រី អាយុ ២០-២៤ឆ្នាំ ដែលយ៉ាងហោចណាស់ធ្លាប់បានផ្តល់កំណើតរស់ចំនួន១ មុនអាយុ១៨ឆ្នាំ<br>ភាគបែង៖ ចំនួនក្មេងស្រីជំទង់សរុប អាយុ ២០-២៤ឆ្នាំ<br>មេគុណ៖ ១០០ |
| ប្រភពទិន្នន័យ | CDHS |
| កម្រិតភាពញឹកញាប់ | ៥ឆ្នាំ |
| កម្រិតនៃការប៉ាន់ប្រមាណ/ការបំបែកទិន្នន័យ | ទៅតាមលំនៅដ្ឋាន ( ជនបទ/ទីក្រុង ) ទ្រព្យសម្បត្តិគ្រួសារ ការអប់រំ ជាតិពន្ធ ( ក្នុងករណីពាក់ព័ន្ធ ) និងលក្ខណៈសង្គមប្រជាសាស្ត្រដទៃទៀត ដែលពាក់ព័ន្ធទៅនឹងបរិបទ។ |

| | |
|---|---|
| ទីភ្នាក់ងារទទួលខុសត្រូវរាយការណ៍អំពីទិន្នន័យ | MoP |
| ឯកសារយោង | សូចនាករ Inspire ៩.៤ |
| កំណត់សម្គាល់ | |
| តំណភ្ជាប់ទៅនឹងទិន្នន័យពាក់ព័ន្ធ | សម្រាប់ទិន្នន័យ CDHS - Statcompiler គឺជាឧបករណ៍មួយដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចកសាងតារាង និងផែនទីទៅតាមដែលខ្លួនចង់បាន ពីសូចនាកររាប់ពាន់នៃប្រទេសចំនួន៩០។ STATcompiler មានគោលបំណងជួយដល់អ្នកប្រើប្រាស់ធ្វើការប្រៀបធៀបទិន្នន័យ DHS ទូទាំងបណ្តាប្រទេសនានា និងទៅតាមពេលវេលាផ្សេងៗគ្នា។ https://www.statcompiler.com/en/<br>មូលដ្ឋានទិន្នន័យសកលរបស់អង្គការយូនីសេហ្វ ត្រួតពិនិត្យទៅលើភាគរយនៃស្ត្រីវ័យក្មេងដែលបានផ្តល់កំណើតមុនអាយុ១៨ឆ្នាំ ក្នុងប្រទេសជាង១០០ ( https://data.unicef.org/topic/maternal-health/adolescent-health)<br>ទិន្នន័យអំពីភាគរយនៃក្មេងស្រីជំទង់ ដែលបានផ្តល់កំណើតមុនអាយុ១៥ឆ្នាំ និងអាចរកបានពី ការអង្កេត DHS និង MICS ក្នុងប្រទេសជាង៩០។ ( inspire ) |

USAID
FROM THE AMERICAN PEOPLE

unicef
for every child